សុភមង្គល

HAPPINESS SERIES

# កូនល្អពិត
## របស់ឪពុកម្តាយ



សម្រាប់ :

◎ កូនគ្រប់រូប ត្រូវអានដាច់ខាត ដើម្បីធ្វើខ្លួនទៅជាកូនល្អពិត

◎ ឪពុកម្តាយ ត្រូវអានដាច់ខាត ដើម្បីអប់រំកូនឱ្យរស់នៅត្រូវ

សម្បត្តិមនុស្ស រមែងកើតមានចំពោះកូនល្អពិត

អំណោយរបស់លោក សៀង វិត /2011
306.874
វិត
ជ.2

HAPPINESS SERIES

# កូនល្អពិត
## របស់ឪពុកម្តាយ

សម្រាប់ :

◎ កូនគ្រប់រូប ត្រូវអានដាច់ខាត ដើម្បីធ្វើខ្លួនទៅជាកូនល្អពិត

◎ ឪពុកម្តាយ ត្រូវអានដាច់ខាត ដើម្បីអប់រំកូនឱ្យរស់នៅត្រូវ

| សម្បត្តិមនុស្ស រមែងកើតមានចំពោះកូនល្អពិត |
|---|

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

All rights reserved by:
SEAN VIT
រក្សាសិទ្ធិគ្រប់យ៉ាងដោយអ្នកនិពន្ធ

00021609

សៀន វិត

ដើម្បីអ្នកមាននូវជំនាញអង់គ្លេសនិងការងារ
ដើម្បីអ្នកក្លាយជាអ្នកមានទ្រព្យសម្បត្តិច្រើន
ដើម្បីអ្នករស់ដោយសេចក្តីសុខ-សុភមង្គល

WISDOM – VIRTUE – LIFE SKILLS

# កម្មវិធីអប់រំពិសេស

## សម្រាប់ មនុស្សពេញវ័យ

- ✔ អប់រំនិងដឹកនាំសិស្សឱ្យមាន "បញ្ញា និង កាយល្អ វាចាល្អ ចិត្តល្អ"
- ✔ បង្រៀនសិស្សឱ្យមាន "ជំនាញភាសាអង់គ្លេស"
- ✔ លត់ដំសិស្សឱ្យមាន "ជំនាញជោគជ័យ"

**សម្តីពិត ជាដួងចិត្តនៃយើងខ្ញុំ**

## សម្រាប់ កុមារក្រោម១២ឆ្នាំ

- ✔ អប់រំនិងដឹកនាំកុមារឱ្យមាន "ប្រាជ្ញា និង អត្តចរិតល្អ"
- ✔ បង្រៀនកុមារឱ្យចេះ "ភាសាអង់គ្លេសបានល្អ និង ជំនាញកុំព្យូទ័រ"
- ✔ បង្រៀនកុមារឱ្យចេះ "អានភាសាខ្មែរ និង ចូលចិត្តអានសៀវភៅ"

<u>សូមអញ្ជើញទំនាក់ទំនង:</u>

**សាលារៀន សុខៈ** (អិស.យូ.ខេ)

តាមទូរស័ព្ទលេខ: **023 6354001 / 023 6354002 / 023 6354003**

# សាលារៀន សុខៈ

# SCHOOL FOR SUKKHAK

WISDOM – VIRTUE – LIFE SKILLS

## SPECIAL EDUCATIONS FOR ADULTS

## កម្មវិធីអប់រំពិសេសសម្រាប់មនុស្សពេញវ័យ

- ✔ កម្មវិធីអប់រំល្អពិសេសគ្មានពីរ សម្រាប់សិស្សពេញវ័យ
- ✔ សម្រាប់សិស្សដែលចង់មានសមត្ថភាពពេញលេញ ដើម្បីក្លាយជាអ្នកមាន :

១. បញ្ញា និង គុណធម៌ ២. ជំនាញអង់គ្លេស ៣. ជំនាញជោគជ័យ

- ✔ សម្រាប់ឪពុកម្ដាយដែលចង់ឱ្យកូនគោរពពួកគាត់ដោយ :

១. គោរពដោយកាយ ២. គោរពដោយវាចា ៣. គោរពដោយចិត្ត

## SPECIAL EDUCATIONS FOR CHILDREN

## កម្មវិធីអប់រំពិសេសសម្រាប់កុមារក្រោម១២ឆ្នាំ

- ✔ កម្មវិធីអប់រំល្អពិសេសគ្មានពីរ សម្រាប់កុមារ
- ✔ សម្រាប់សិស្សជាកុមារ នឹងមានសមត្ថភាពតាំងពីវ័យកុមារ :

១. ប្រាជ្ញា និងចរិតល្អ ២. ចេះនិយាយអង់គ្លេស ៣. ចេះកុំព្យូទ័រនិងខ្មែរ

- ✔ សម្រាប់ឪពុកម្ដាយដែលចង់ឱ្យកូនមាន :

១. សមត្ថភាព ៣ ខាងលើ ២. ចេះគោរពស្ដាប់បង្គាប់ឪពុកម្ដាយ

# មាតិកា

**ចំណងជើង** **ទំព័រ**

អារម្ភកថា ..... vii

សេចក្ដីថ្លែងអំណរគុណ ..... x

ដោយទឹកចិត្តមេត្តា-ករុណារបស់ខ្ញុំ ..... xii

**ផ្នែកទី១: សេចក្ដីផ្ដើម** ..... ១

ក. តើជីវិតជាអ្វី? ..... ៣

ខ. តើគួររស់នៅបែបណា ដើម្បីបានសេចក្ដីសុខ-សេចក្ដីចម្រើន? ..... ១៣

គ. តើហេតុនៃកំណើតរបស់កូនយ៉ាងដូចម្ដេច? ..... ១៦

ឃ. តើឪពុកម្ដាយជាព្រះរស់ មានន័យដូចម្ដេច? ..... ១៨

ង. តើកូនមាន ៣ ពួក អ្វីខ្លះ? ..... ១៩

ច. តើមនុស្សមាន ៤ ពួក អ្វីខ្លះ? ..... ៣០

**ផ្នែកទី២: កិច្ចការរបស់កូនល្អពិត** ..... ៣១

ក. កូនល្អពិត រក្សាកល្យាណធម៌ ៥ ..... ៣៣

ខ. កូនល្អពិត រក្សាសីល ៥ ឬ សីល ៨ ..... ៥៧

គ. កូនល្អពិត រក្សាអរិយកិច្ច ៣ យ៉ាង ..... ៦០

ផ្នែកទី៣៖ សមត្ថភាព ៣ យ៉ាងនៃកូនល្អពិតដើម្បីសម្រេចបំណងពិតរបស់ឪពុកម្តាយ ..... ៩៩
ក. កូនល្អមានសមត្ថភាពបំពេញ "តួនាទីជាកូនល្អពិត" ..... ១០២
ខ. កូនល្អមានសមត្ថភាពកសាង "អនាគតល្អពិត" ..... ១២២
គ. កូនល្អមានសមត្ថភាពធ្វើជា "មនុស្សល្អពិត" ..... ១២៣

ដំណោះស្រាយសម្រាប់កូនដែលចង់កែខ្លួនឱ្យល្អពិត ..... ១២៤

# អារម្ភកថា

ខ្ញុំបាទ បានសរសេរសៀវភៅ "កូនល្អពិត របស់ឪពុកម្តាយ" នេះឡើង ព្រោះខ្ញុំបាទមានបំណងចង់ឃើញ គ្រួសារខ្មែរ ជាគ្រួសារសុភមង្គល ដែលសមាជិកគ្រួសារម្នាក់ៗ សុទ្ធតែដើរតួយ៉ាងសំខាន់ក្នុងការរួមចំណែកបង្កើតសុភមង្គលឡើង ។ បន្ទាប់អំពីកោសិកាមេគឺ ឪពុកម្តាយ ដែលជាមេទ័ពនៃគ្រួសារ ក៏វិបុលសុខក្នុងគ្រួសារអាស្រ័យជាសំខាន់បំផុតលើកោសិកាកូន គឺកូនម្នាក់ៗ ដែលជាគោលដៅស្រួចរបស់ឪពុកម្តាយផង ជាកោសិកាបន្តពូជផង ។ បើកូនៗ មិនបានបំពេញកាតព្វកិច្ចជាកូនល្អបានទេនោះ ពួកគេមិនត្រឹមតែមិនបានរួមចំណែកធ្វើឱ្យគ្រួសារមានសុភមង្គលប៉ុណ្ណោះទេ ថែមទាំងនឹងមិនអាចក្លាយជាឪពុកម្តាយល្អពិតបានដែរនៅថ្ងៃអនាគត ។

សៀវភៅនេះ នឹងជាទ្រព្យទុនដ៏ចាំបាច់ ជាពិសេសសំរាប់កូនៗគ្រប់រូបត្រូវតែយល់ដឹងឱ្យជាក់អំពីកិច្ចការត្រូវបំពេញដើម្បីបង្កើតគ្រួសារសុភមង្គល ។ អ្វីៗក្នុងលោកនេះ មិនមែនកើតឡើងដោយឯកឯងនោះទេ ហើយក៏មិនកើតមានឡើងដោយងាយៗដែរ ជាក់ស្តែងគឺ សុភមង្គល ដែលមនុស្សគ្រប់រូបរស់នៅប្រាថ្នាឱ្យមានឱ្យជួបគ្រប់ៗគ្នា ។ ហេតុគឺជាមេ បង្កើតនូវផលទាំងឡាយក្នុងលោកិយនេះ ចុះតើហេតុនៃសុភមង្គលគឺអ្វី ?

មិនមានមនុស្សណា ឬ កូនណាម្នាក់ អាចបង្កើតអ្វី១ល្អ ដោយអវិជ្ជា (ភាពល្ងង់ខ្លៅ) បាននោះឡើយ ដូចព្រះពុទ្ធ បានសម្តែងថា "ម្នាលភិក្ខុទាំងឡាយ **អវិជ្ជា** ជាប្រធាននៃអកុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅដើម្បីញ៉ាំងសេចក្តីមិនខ្មាសបាប និង មិនខ្លាចបាប ឱ្យកើតឡើងជាលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ **សេចក្តីយល់ឃើញខុស** រមែងកើតឡើងដល់បុគ្គលល្ងង់ខ្លៅ ប្រកបដោយអវិជ្ជា, **សេចក្តីត្រិះរិះខុស** កើតឡើងដល់បុគ្គលមានសេចក្តីយល់ឃើញខុស, **វាចាខុស** កើតឡើងដល់បុគ្គលមានសេចក្តីត្រិះរិះខុស, **ការងារ**(ទង្វើ) **ខុស** កើតឡើងដល់បុគ្គលមានវាចាខុស, **ការចិញ្ចឹមជីវិតខុស** កើតឡើងដល់បុគ្គលមានការងារ(ទង្វើ)ខុស, **ការព្យាយាមខុស** កើតឡើងដល់បុគ្គលមានការចិញ្ចឹមជីវិតខុស, **ការរឭកខុស** កើតឡើងដល់បុគ្គលមានការព្យាយាមខុស, **ការតាំងចិត្តមាំខុស** កើតឡើងដល់បុគ្គលមានការរឭកខុស ។

តាមព្រះពុទ្ធដីកា អវិជ្ជា (សេចក្តីល្ងង់ខ្លៅ) គឺការចេះដឹងមិនច្បាស់ ឬ ការយល់ដឹងខុស ឬ ការយល់ដឹងនិងចេះដឹងមិនគ្រប់គ្រាន់ មិនអាចនាំឱ្យកើតមាន សេចក្តីសុខ សេចក្តីចម្រើន សុភមង្គល បានឡើយ ។ ដើម្បីឱ្យផលល្អ ឬ កុសលវិបាក ឬ សេចក្តីសុខ កើតមានឡើងបាន លុះត្រាតែមនុស្សយើង ចាប់ផ្តើមឡើងដោយមាន បញ្ញាគឺ **សេចក្តីយល់ឃើញត្រូវ** (សម្មាទិដ្ឋិ) ជាអរិយមគ្គទី១នៃអរិយមគ្គអង្គ៨ដែលព្រះពុទ្ធ ត្រាស់សម្តែងថា ជាផ្លូវតែ

១ គត់ នាំមនុស្សលោកឱ្យធ្វើដំណើរទៅដល់ វិបុលសុខ ពោលគឺ ជីវិតជួបតែសេចក្តីសុខ សេចក្តីចម្រើន នោះគឺសម្រេចបាននូវសម្បត្តិ ៣ មាន សម្បត្តិមនុស្ស សម្បត្តិទេវតា និងសម្បត្តិព្រះនិព្វាន តាមការប្រាថ្នា ។ ដូច្នេះ បានជាខ្ញុំបាទសរសេរសៀវភៅ "កូនល្អពិត របស់ឪពុកម្តាយ" នេះ គ្មានអ្វីក្រៅអំពី ធ្វើឱ្យលោកអ្នកទាំងឡាយដែលជាកូនចង់ក្លាយជាកូនល្អពិត ជៀសវាងចង់ធ្វើជាកូនល្អតែមាត់ ព្រោះល្ងង់ ដោយមិនដឹងថាធ្វើម្តេចខ្លះ តាមរយៈសៀវភៅនេះ លោកអ្នកនឹងដឹងច្បាស់ ពោលគឺ **សេចក្តីយល់ឃើញត្រូវ** នូវអ្វីខ្លះដែលត្រូវបំពេញ ដើម្បីក្លាយជាកូនល្អពិតដោយបញ្ញា នោះទើបសុភមង្គលគ្រួសារជាសម្បត្តិមនុស្ស នឹងកើតឡើងជាប្រាកដ។ បន្ទាប់ពីលោកអ្នកមានសេចក្តីយល់ឃើញត្រូវរួចហើយ គប្បីបដិបត្តិតាមអរិយមគ្គអង្គទី ២ និងអង្គជាបន្តបន្ទាប់រហូតដល់ អង្គទី ៨ គឺ ការតាំងចិត្តមាំត្រូវ (សម្មាសមាធិ) ។

ភ្នំពេញ ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១១

ពីខ្ញុំបាទ អ្នកនិពន្ធ

**ស៊ាន វិត**

ទំនាក់ទំនង: **077 333 666**

Email: **3sambath@gmail.com**

# សេចក្តីថ្លែងអំណរគុណ

សៀវភៅ "កូនល្អពិត របស់ឪពុកម្តាយ" នេះ ជាស្នាដៃទី ៤ របស់ខ្ញុំបាទ ដែលកើតចេញមកអំពីទឹកចិត្តមេត្តា បានពីបារមីនិងមហាគុណ របស់ព្រះទាំងទ្វេ របស់ខ្ញុំបាទឈ្មោះ លោកឪពុក **ហ៊ូ ស៊ាន** និងអ្នកម្តាយ **មាស និន** ជាមួយនឹងគុណនៃព្រះរតនត្រៃមាន ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលជាសារណគមន៍នៃខ្ញុំបាទ និងគុណគ្រូទាំងឡាយ រួមទាំងគុណនៃសប្បុរសញ្ញាតិសន្តាន សិស្សានុសិស្ស មិត្តរួមការងារ និងសារធារណជន ។

ខ្ញុំបាទ . សូមថ្លែងអំណរគុណនិងដឹងគុណដល់លោកអ្នកដែលបានជាវសៀវភៅនេះ ដើម្បីអភិវឌ្ឍន៍បញ្ញា គឺការយល់ឃើញត្រូវ ជាជំហានទី១ឆ្ពោះទៅដល់ការសម្រេចបានជោគជ័យនានាក្នុងជីវិត ។ ខ្ញុំបាទ ក៏មិនភ្លេចគុណរបស់លោកគ្រូ-អ្នកគ្រូនៃ **សាលារៀន សុខៈ** មានឈ្មោះដូចខាងក្រោម :

១. អ្នកគ្រូ **ឆន ដារីណែត**
២. លោកគ្រូ **យូ សុវុទ្រា**
៣. អ្នកគ្រូ **ប៊ុល វ៉ាន់ឌី**
៤. លោកគ្រូ **ពៅ ចំរើន**
៥. អ្នកគ្រូ **អ៊ុន ទិត្យធារី**
៦. លោកគ្រូ **ចយ វុទ្ធី**

១២. អ្នកគ្រូ **អ៊ាន គីមស្រួន**
១៣. លោកគ្រូ **សួស ស៊ុនឌី**
១៤. អ្នកគ្រូ **អ៊ឹម ស្រីយ៉ាន**
១៥. លោកគ្រូ **ម៉ក់ ចំរុង**
១៦. អ្នកគ្រូ **វ៉ន លីដា**
១៧. លោកគ្រូ **ផុន ដាណែត**

៧. អ្នកគ្រូ ស៊ិន វ៉ាន់ណែត
៨. លោកគ្រូ ស៊ឹង លីហួរ
៩. អ្នកគ្រូ យិន ស្រីនាង
១០. លោកគ្រូ ម៉ក់ រដ្ឋា
១១. អ្នកគ្រូ ហ៊ាង បូរី
១៨. អ្នកគ្រូ វ៉ាត សម្ផស្ស
១៩. លោកគ្រូ ហាស់ ចាន់រឿន
២០. លោកគ្រូ ពៅ លីហុង
២១. លោកគ្រូ អ៊ុន រស្មី
២២. លោកគ្រូ ប៉ុង ពេញ
២៣. លោកគ្រូ ស៊ុម សូនី

សូមព្រះពុទ្ធសាសនារុងរឿងពាសពេញសកលលោក និង សូមបួងសួងដល់ទេវតារក្សាលោក និងបារមីនៃគុណព្រះពុទ្ធ គុណព្រះធម៌ គុណព្រះសង្ឃ គុណមាតាបិតា និងគុណគ្រូ ញុំាងឱ្យមនុស្សលោកទាំងឡាយទម្លាក់អាវុធសាហាវជាងគេបំផុតក្នុងលោកគឺ លោភៈ ទោសៈ និងមោហៈចេញពី កាយ វាចា ចិត្ត ដើម្បីបាននូវ វិបុលសុខ និង សេចក្តីសុខស្ងប់ ។ ជាក់ស្តែង សូមមេដឹកនាំទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា រក្សាសីល ៨ និង រក្សាសីល ៥ គ្រប់ៗគ្នា ដើម្បីជាម្លប់សុខ ម្លប់សន្តិភាពដល់ប្រជាជន និង សូមឧទ្ទិសបុណ្យកុសលជូនដល់សព្វសត្វលោក និងមេដឹកនាំគ្រប់រូប ។

ភ្នំពេញ, ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០១១

**ស៊ាន វ៉ិត**

**ដោយទឹកចិត្ត**

**មេត្តា-ករុណា របស់ខ្ញុំ**

សៀវភៅ "កូនល្អពិត របស់ឪពុកម្ដាយ" នេះ

**ជាអំណោយដ៏ស្មោះបំផុត**

ក្នុងឱកាស

______________________________

**ជូន**

**ចំពោះឈ្មោះ:** ______________________

**ពីខ្ញុំឈ្មោះ:** ______________________

មេត្តា មានន័យថា ការរាប់អាន ការមានបំណងល្អ ឱ្យអ្នកដទៃទទួលបានប្រយោជន៍ គឺសេចក្ដីសុខ និង សេចក្ដីចម្រើន

ករុណា មានន័យថា សេចក្ដីអាណិតអាសូរ ការជួយដល់អ្នកដទៃ ឱ្យទទួលបានប្រយោជន៍ គឺសេចក្ដីសុខ និង សេចក្ដីចម្រើន

**"បើមនុស្សយើងមានមេត្តា-ករុណាឱ្យដល់គ្នា នោះជីវិតនឹងមានសេចក្ដីសុខ សេចក្ដីចម្រើន និង សន្តិភាព ។"**

នៅពេលដែលលោកអ្នក ទិញសៀវភៅដែលជាស្នាដៃរបស់ខ្ញុំ នោះលោកអ្នកផ្តល់តម្លៃដល់ខ្ញុំ។ នៅពេលដែលលោកអ្នកអានសៀវភៅនេះ នោះលោកអ្នកផ្តល់តម្លៃដល់ខ្លួនឯង ។ នៅពេលដែលលោកអ្នក ទទួលបានផលប្រយោជន៍អំពីការអាននេះ នោះលោកអ្នកផ្តល់តម្លៃដល់ខ្លួនឯងផង ដល់ខ្ញុំបាទផង ។ នៅពេលដែលលោកអ្នក ណែនាំញាតិមិត្ត ឱ្យទិញសៀវភៅនេះអានផង នោះលោកអ្នកផ្តល់តម្លៃដល់សង្គម ។ ដូចនេះ លោកអ្នកពិតជាមនុស្សល្អ ព្រោះចេះលើកតម្កើង និងចេះផ្តល់តម្លៃដល់ខ្លួនឯងផង ដល់អ្នកដទៃទាំងពួងផង ។

- បើលោកអ្នក បរិច្ចាគសៀវភៅនេះ ១ ក្បាល ដល់បុរស ឬ នារីណាម្នាក់ដែលជាកូន មានន័យថា លោកអ្នកមានមេត្តា-ករុណាជួយគេនោះ ឱ្យក្លាយទៅជា កូនល្អពិត ។

- បើលោកអ្នក បរិច្ចាគសៀវភៅនេះ ១ ក្បាល ដល់ឪពុក ឬ ម្តាយណាម្នាក់ មានន័យថា លោកអ្នកមានមេត្តា-ករុណាជួយដល់គាត់ ឱ្យក្លាយជាឪពុក ឬម្តាយដែលយល់ដឹងច្បាស់អំពីកិច្ចការរបស់កូនល្អពិតគប្បីបំពេញ រួចលោកទាំង២នឹងដឹកនាំ ចង្អុលបង្ហាញ និងបង្រៀនកូនឱ្យធ្វើតែកិច្ចការត្រូវ គឺរស់នៅត្រូវ ។

- បើលោកអ្នក បរិច្ចាគសៀវភៅព្រះធម៌ ( ធម៌ គឺធម្មជាត ដែលជាព្រះឱវាទរបស់ព្រះពុទ្ធ) ដោយមេត្តា-ករុណា ដល់មនុស្សដែលមានសេចក្តីត្រូវការ មានន័យថា លោកអ្នកបានកប់កំណប់បញ្ញាទុក ។ ព្រះពុទ្ធ បានត្រាស់សម្តែងថា ពន្លឺប្រាជ្ញា( បញ្ញា)ភ្លឺជាងពន្លឺព្រះអាទិត្យ ពន្លឺព្រះច័ន្ទ និងពន្លឺចង្កៀង ។

*ស៊ាន វិត*

ចូរ

# អាន ច្រើនដង

ហើយ

# គិត ច្រើនដង

ហើយ

# ធ្វើ ច្រើនដង

*ស៊ាន វិត*

ផ្នែកទី

១

# សេចក្ដីផ្ដើម

"ជោគជ័យគ្រប់យ៉ាង កើតឡើងដោយមាន ៣ ដំណាក់កាល ៖

ទី១ គឺការចាប់ផ្ដើម

ទី២ គឺការបញ្ជោខ្លួនឯងឱ្យបោះជំហានទៅមុខជានិច្ច

ទី៣ គឺការធ្វើឱ្យសម្រេចគោលដៅនិងគោលបំណង ។"

*ស៊ាន រ៉ិត*



ខំ- ជា កូនល្អ ពិត

# ផ្នែកទី១៖ សេចក្តីផ្តើម

## ក. តើជីវិតជាអ្វី?

មនុស្សម្នាក់ៗ មានការយល់ឃើញផ្សេងៗពីគ្នា អំពីនិយមន័យនៃជីវិត ទៅតាមបទពិសោធន៍សិក្សារៀនសូត្រ និងបទពិសោធន៍ផ្ទាល់នៅក្នុងជីវិត ដោយឡែក ខ្ញុំបាទ សូមជូននូវនិយមន័យដ៏គួរឱ្យពិចារណាបំផុត ថែមទាំងមានសារប្រយោជន៍ជាពិសេសផងនោះ ចំនួន ២ សំរាប់កូនៗគ្រប់រូបទាញប្រយោជន៍ពីន័យទាំងនេះ ។

- ជីវិត ជាកិរិយារស់នៅ ។
- ជីវិត ជាខន្ធ ៥ ។

**តើជីវិត ជាកិរិយារស់នៅមានន័យដូចម្តេច?** កិរិយារស់នៅ ជាចលនានៃជីវិត បើមនុស្សណាគ្មានចលនា ហៅថា បុគ្គលបានបាត់បង់ជីវិត ឬ ស្លាប់ ។ ចលនានៃជីវិត ឬ កិរិយារស់នៅ មាន ៣ បែបគឺ *(១)កិរិយាតាមផ្លូវកាយ* បានដល់ ការប្រព្រឹត្តដោយឥរិយាបថទាំង ៤ ដេក ដើរ ឈរ អង្គុយ ការស្លៀកពាក់ ការសម្តែងកាយវិការ ការទំនាក់ទំនង ហើយកិរិយាតាមផ្លូវកាយ ចែកចេញជា ២ ទៀតគឺ *កិរិយាតាមផ្លូវកាយដោយសុចរិត* ឬ *កិរិយានៃកាយសុចរិត* ហៅថា កិរិយារស់នៅដោយសេចក្តីគោរព និង *កិរិយាតាមផ្លូវកាយទុច្ចរិតឬ* *កិរិយានៃកាយទុច្ចរិត* ហៅថា កិរិយារស់នៅ

ខ្ញុំ-ជា កូនល្អ ពិត

ដោយសេចក្តីមិនគោរព ដែលកិរិយាទាំងពីរនេះ មាន ៣ យ៉ាងទៀត ។ *(២) កិរិយាតាមផ្លូវវាចា* បានដល់ ការនិយាយ ដែលចែកចេញជា ២ គឺ *កិរិយាតាមផ្លូវវាចាដោយសុចរិត* ឬ *កិរិយានៃវាចាសុចរិត* ហៅថា កិរិយារស់នៅដោយសេចក្តីគោរព និង *កិរិយាតាមផ្លូវវាចាដោយទុច្ចរិត* ឬ *កិរិយានៃវាចាទុច្ចរិត* ហៅថា កិរិយារស់នៅដោយសេចក្តីមិនគោរព ហើយ កិរិយាទាំង ២ នេះ មាន ៤ យ៉ាងទៀត ។ *(៣) កិរិយាតាមផ្លូវចិត្ត* បានដល់ ការគិត ការនឹករឭក ការចងចាំ ការសំគាល់ ដែលចែកចេញជា ២ គឺ *កិរិយាតាមផ្លូវចិត្តដោយសុចរិត* ឬ *កិរិយានៃចិត្តសុចរិត* ហៅថា កិរិយារស់នៅដោយសេចក្តីគោរព និង *កិយាតាមផ្លូវចិត្តដោយទុច្ចរិត* ឬ *កិរិយានៃចិត្តទុច្ចរិត* ហៅថា កិរិយារស់នៅដោយសេចក្តីមិនគោរព ហើយ កិរិយាតាមផ្លូវចិត្តនេះ មាន ៣ យ៉ាង ។

ជារួម កិរិយារស់នៅ មាន ២ ប្រភេទ គឺ កិរិយារស់នៅដោយសេចក្តីគោរព តាមផ្លូវកាយ ៣ តាមផ្លូវវាចា ៤ តាមផ្លូវចិត្ត ៣ និង កិរិយារស់នៅដោយសេចក្តីមិនគោរព គឺប្រមាទនិងប្រមាថ តាមផ្លូវកាយ ៣ តាមផ្លូវវាចា ៤ តាមផ្លូវចិត្ត ៣ ។ កិរិយារស់នៅ មានសកម្មភាពឬទង្វើតូច-ធំ, សកម្មភាពឬទង្វើប្រើពេលខ្លី-វែង ដែលកិរិយារស់នៅទាំងឡាយណា ជាកិរិយាគោរព នាំមកនូវវិបុលសុខ គឺសេចក្តីសុខ សេចក្តីចម្រើន ការចំណេញ សេចក្តីថ្លៃថ្នូរ ការសរសើរ ដែលត្រូវប្រកបដោយការព្យាយាម

តស៊ូ អត់ធ្មត់ រឹង កិរិយារស់នៅទាំងឡាយណា ជាកិរិយាប្រមាទនិង ប្រមាថ ហុចផលដល់អ្នកប្រព្រឹត្តនូវសេចក្ដីវិនាស គឺ ទុក្ខ សេចក្ដីមិនចម្រើនរុងរឿង ការខាតបង់ប្រយោជន៍ សេចក្ដីថោកទាប ការត្មះតិះដៀល ការជាប់ទោសទារុណ ជាដើម ។ **កិរិយាប្រមាទ នាំឱ្យមាន សេចក្ដីវិនាស កិរិយាគោរព នាំឱ្យមាន សេចក្ដីចម្រើន** ។ ប្រមាទដល់កិរិយារស់នៅ គឺជាការប្រមាទដល់ជីវិត, គោរពដល់កិរិយារស់នៅ គឺជាការគោរពដល់ជីវិត។ ប្រមាទដល់ជីវិតអ្នកដទៃ គឺជាការប្រមាទដល់ជីវិតខ្លួនឯង ហើយប្រមាទដល់ជីវិតខ្លួនឯង ក៏ជាការប្រមាទដល់ជីវិតអ្នកដទៃ, គោរពដល់ជីវិតអ្នកដទៃ គឺជាការគោរពដល់ជីវិតខ្លួនឯង ហើយគោរពដល់ជីវិតខ្លួនឯង ក៏ជាការគោរពដល់ជីវិតអ្នកដទៃ ។

## ជីវិត ជាជម្រើសនិងជាឱកាស តាមច្បាប់កម្មផល ។

ថ្លៃថ្នូរ ឬ ថោកទាប ជាជម្រើសនៃអំពើរបស់អ្នក !

មាន ឬ ក្រ ជាជម្រើសនៃអំពើរបស់អ្នក !

ប្រាជ្ញ ឬ ល្ងង់ ជាជម្រើសនៃអំពើរបស់អ្នក !

សុខ ឬ ទុក្ខ ជាជម្រើសនៃអំពើរបស់អ្នក !

**ជីវិតកំណត់ដោយកម្ម មិនមែនកំណត់ដោយព្រហ្មលិខិតទេ ។**

ប្រមាថ ប្រែថា ការបៀតបៀនគេ, ការញាំញីគេ, ការធ្វើទុក្ខបុកម្នេញឱ្យគេលំបាក, ការមើលងាយគេ ។

ប្រមាទ ប្រែថា ការភ្លេចស្មារតី, ធ្វេសស្មារតី, សេចក្ដីប្រហែស, ការប្រហែសធ្វេស ។

**តើជីវិត ជាខន្ធ៥ មានន័យដូចម្ដេច?** ខន្ធ ប្រែថា គំនរ, កង, បណ្ដុំ ដូចនេះ ខន្ធ៥ (ឬបញ្ចក្ខន្ធ) ប្រែថា គំនរ៥ ឬ កង៥ ឬ បណ្ដុំ៥ ដែលរួមបញ្ចូលគ្នា បង្កើតបានជាជីវិត មានកាយ និងចិត្ត នេះឯង ។ គំនរ៥នោះមាន :

**១. រូបខន្ធ** (គំនរនៃរូប) : ជាបណ្ដុំនៃមេធម្មជាតិ ៤ យ៉ាង មានធាតុ ដី ទឹក ភ្លើង ខ្យល់ ប្រជុំគ្នាតាក់តែងបង្កើតបានជារូប ហៅថា **កាយ** ដែលយើងអាចមើលឃើញនឹងភ្នែក ។ ក្នុងកាយដែលតាក់តែងឡើងដោយធាតុ ដី ទឹក ភ្លើង ខ្យល់ មានធាតុផ្សំសរុបចំនួន ៤២ យ៉ាង ។

- **បឋវីធាតុ** (ធាតុដី) : ធាតុរឹង និង ទន់ទាំងឡាយ នៅក្នុងខ្លួនមនុស្ស ដែលអាច រលត់ រលេះ រលួយ រលាយក្លាយទៅជាធាតុដីបាន មាន ២០ យ៉ាង គឺ : *សក់, រោម, ក្រចក, ធ្មេញ, ស្បែក, សាច់, សរសៃ, ឆ្អឹង, ខួរក្នុងឆ្អឹង, ទាច (តម្រងទឹកមូត្រ ឬ ប្លោក), បេះដូង, ថ្លើម, វាវ, ក្រពះ, សួត, ពោះវៀនធំ, ពោះវៀនតូច, អាហារថ្មី, អាហារចាស់, និង ខួរក្នុងក្បាល* ។

- **អាបោធាតុ** (ធាតុទឹក) : វត្ថុ និង ធាតុរាវទាំងឡាយ នៅក្នុងខ្លួនមនុស្ស ដែលអាចរលាយក្លាយទៅជាទឹក មានចំនួន ១២ យ៉ាង គឺ : *ទឹកប្រមាត់, ស្លេស្ម, ខ្ទុះ, ឈាម, ញើស, ខ្លាញ់ខាប់, ខ្លាញ់រាវ, ទឹកភ្នែក, ទឹកមាត់, ទឹកសម្បោរ, ទឹករំអិល, និង ទឹកមូត្រ* ។

- **តេជោធាតុ** (ធាតុភ្លើង)៖ ធាតុមានចំហាយ មានកម្តៅសម្រាប់កំដៅសរីរៈឱ្យក្តៅ មាន ៤ យ៉ាង គឺ ៖ *ភ្លើងធាតុដែលញ៉ាំងកាយឱ្យក្តៅជាប្រក្រតី, ភ្លើងធាតុដែលញ៉ាំងកាយឱ្យជរាទ្រុឌទ្រោម, ភ្លើងធាតុដែលញ៉ាំងកាយឱ្យក្តៅរោលរាល, និង ភ្លើងធាតុដែលសម្រាប់កិនរំលាយអាហារ* ។

- **វាយោធាតុ** (ធាតុខ្យល់)៖ ធាតុដែលបក់ទៅមក ផ្សព្វផ្សាយទៅមក មានវិញ្ញាណចូលទៅអាស្រ័យនៅ មាន ៦ យ៉ាង គឺ ៖ *ខ្យល់ដែលបក់ពីចុងជើងឡើងទៅដល់ក្បាល, ខ្យល់ដែលបក់ពីក្បាលចុះទៅដល់ចុងជើង, ខ្យល់ដែលបក់វិលវល់ខាំងនៅក្នុងពោះ, ខ្យល់ដែលបក់វិលវល់ខាំងនៅក្នុងក្រពះពោះវៀន, ខ្យល់ដែលបក់ចុះឡើងសព្វសព៌ាង្គកាយ, និង ខ្យល់ដែលសម្រាប់ដកដង្ហើមចេញចូល* ។

**២. វេទនាខន្ធ** (គំនរនៃវេទនា)៖ ជាការសោយ ឬ ការទទួលនូវអារម្មណ៍ទាំងឡាយ ដោយចិត្តរំភើបញាប់ញ័រ ចិត្តជាប់ជំពាក់ ហៅថាកិលេសចិត្ត ឬធូលីចិត្ត ដែលវេទនាទាំងឡាយកើតឡើងដោយ **ផស្សៈ** (ការប៉ះទង្គិច) រវាងឥន្ទ្រិយ៦ (អាយតនៈក្នុង៦) ជាមួយ វត្ថុអារម្មណ៍៦ (អាយតនៈក្រៅ៦) បង្កើតបានជា ឥន្ទ្រិយរម្មណ៍៦ គឺវេទនាខន្ធ ឬ គំនរ ៦ យ៉ាងនៃវេទនា ហ្នឹងឯង។ គំនរ៦នៃវេទនានេះ មានលក្ខណៈជាវេទនា ៥

យ៉ាងគឺ សុខវេទនា (ការទទួលអារម្មណ៍ជាសុខ), ទុក្ខវេទនា (ការទទួលអារម្មណ៍ជាទុក្ខ), ឧបេក្ខាវេទនា ឬ អទុក្ខមសុខវេទនា ឬ អព្យាកតវេទនា (ការទទួលអារម្មណ៍ជាកណ្តាល), សោមនស្សវេទនា (ការទទួលអារម្មណ៍ជារីករាយចិត្ត), និង ទោមនស្សវេទនា (ការទទួលអារម្មណ៍ជាថ្នាំងថ្នាក់ចិត្ត) ។

| ឥន្ទ្រិយ | + | វត្ថុអារម្មណ៍ | ⇨ | ឥន្ទ្រិយរម្មណ៍ |
|---|---|---|---|---|
| (អាយតនៈក្នុង៦) | | (អាយតនៈក្រៅ៦) | | (អាយតនៈក្នុងបូកក្រៅ) |
| ភ្នែក | | រូប | | រូបារម្មណ៍ |
| ត្រចៀក | | សម្លេង | | សទ្ទារម្មណ៍ |
| ច្រមុះ | | ក្លិន | | គន្ធារម្មណ៍ |
| អណ្តាត | | រស | | រសារម្មណ៍ |
| កាយ | | ផោដ្ឋព្វៈ | | ផោដ្ឋព្វារម្មណ៍ |
| ចិត្ត | | ធម្មៈ | | ធម្មារម្មណ៍ |

ដូចនេះ វេទនាកើតចេញពីទ្វារទាំង ៦ គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និង ចិត្ត ។

**៣. សញ្ញាខន្ធ** (គំនរនៃសញ្ញា)៖ ជាការកំណត់ដឹង, សម្គាល់, ឬការចំណាំ នូវវេទនា (ឥន្ទ្រិយរម្មណ៍) ទាំងឡាយដែលកើតឡើងតាមទ្វារទាំង៦ ឧទាហរណ៍ ដឹងថា ឬ សំគាល់ថា ឬ ចងចាំថា នេះជាអារម្មណ៍

រីករាយ សោកសង្រេង សុខ ទុក្ខ ព្យាបាទ ខឹងក្រោធ បៀតបៀន ... ។ ការកំណត់ដឹង ឬ ការសំគាល់ ឬ ការចងចាំ (សញ្ញាខន្ធ) ចែកជា ៣ កំរិត គឺ ការចងចាំរយៈពេលខ្លី ការចងចាំរយៈពេលមធ្យម និង ការចងចាំរយៈពេលយូរអង្វែង ។ សញ្ញាមាន ៥ ប្រការគឺ:

(ក).អាហារសញ្ញា : គឺការចំណាំ ឬ សំគាល់ថា អាហារណាសម្រាប់កាយ និង អាហារណាសម្រាប់ចិត្ត ។ សំគាល់ដឹងថា នេះជាអាហារអាចទទួលទានបាន ឬ នោះជាអាហារមិនអាចទទួលទានបាន ឬ អាហារនេះឆ្ងាញ់ ឬ អាហារនោះល្វីង ជូរ ចត់ ហិរ ប្រៃ ឬ ចងចាំថា អាហារណាទ្រទ្រង់កាយឱ្យមាំទាំ ហើយ អាហារណាប៉ះពាល់ដល់សុខភាពកាយ ។ អាហាររបស់ចិត្ត ហៅថា ចំណីអារម្មណ៍ មានន័យថា កំណត់ដឹងថា នេះជាអារម្មណ៍រីករាយ អារម្មណ៍កើតទុក្ខ អារម្មណ៍ស្រើបស្រាល អារម្មណ៍តក់ស្លុត អារម្មណ៍រវើរវាយ អារម្មណ៍ខឹងក្រោធ អារម្មណ៍បៀតបៀនព្យាបាទ ។

(ខ). ជីវិតសញ្ញា : គឺការចំណាំ ឬ ការសំគាល់ថា នេះជាហេតុការណ៍ បញ្ហា រឿងរ៉ាវ ដំណោះស្រាយ ឧបាយកល សុខ ទុក្ខ សេចក្ដីវិនាស សេចក្ដីចម្រើន ដែលកើតមាននៅក្នុងជីវិតមនុស្សសត្វ ឬ នៅក្នុងសង្គមខ្មែរ សង្គមបរទេស ។

(គ). កាមសញ្ញា : គឺការចំណាំ ឬ ការកំណត់ដឹង ឬ ការសំគាល់ថា នេះជាចំណង់ របស់មនុស្សសត្វ ។ ឧទាហរណ៍ សំគាល់ដឹងថា ខ្លួនឯងចង់បានសុខស្រួលក្នុងកាយចិត្តបែបនេះឬបែបនោះ, សត្វក្របីមានចំណង់ដេកនៅក្នុងភក់, សត្វឃ្មុំមានចំណង់ក្រេបលម្អងផ្កា, សត្វរុយចង់ស៊ីចំណីស្មោគគ្រោគ, មនុស្សមានចំណង់ក្នុងរូប ក្លិន សម្លេង រស សម្រស់ ។

(ឃ). ធម្មសញ្ញា : គឺការចំណាំ ឬ ការសំគាល់ដឹងអំពីធម្មៈ គឺធម្មជាតិ គឺសច្ចៈ ត្រូវ-ខុស ស-ខ្មៅ បុណ្យ-បាប គុណ-ទោស មានប្រយោជន៍-ឥតប្រយោជន៍ កុសលកម្ម-អកុសលកម្ម សុខ-ទុក្ខ ។



៤. **សង្ខារខន្ធ** (គំនរនៃសង្ខារ): ជាការផ្សំ ការប្រមូលផ្តុំ ការប្រជុំតាក់តែងនៃមេធម្មជាតិទាំង ៤ មាន ដី ទឹក ភ្លើង ខ្យល់ ឱ្យកើតជាសារពាង្គកាយ ជាជីវិត ជាគំនិត ជាកំណើតនៃសត្វលោក ក្រោមអំណាចនៃកម្ម ដែលក្រោមអំណាចនៃចេតនា ។ ធម្មជាតិនៃសង្ខារ កើតហើយរលត់ទៅវិញៗ ។ សង្ខារខន្ធ មាន ៣ ផ្នែកគឺ:

(ក). កុសលសង្ខារ : ធម្មជាតិផ្សំ ប្រមូលផ្តុំ តាក់តែង ឱ្យ ...ម្ម

**បន្ថែមចំនុចខ្វះ**

(ង). រូបសញ្ញា : គឺការចំណាំ ឬ ការសំគាល់ ឬ ការកំណត់ដឹងថា នេះជារូបតាងឱ្យនាមធម៌(ឈ្មោះ)អ្វី១ នោះជារូបតាងឱ្យឈ្មោះអ្វី១ផ្សេងទៀត ។

(ខ). អកុសលសង្ខារ : ធម្មជាតិផ្សំ ប្រមូលផ្ដុំ តាក់តែងឱ្យកើតមាន សារពាង្គកាយ ជីវិត គំនិត កំណើតសត្វលោក ដោយអកុសលកម្ម ដែលក្រោមអំណាចនៃអកុសលចេតនា ហើយនឹងរលត់កើតៗ ។

(គ). អព្យាកតសង្ខារ : ធម្មជាតិផ្សំ ប្រមូលផ្ដុំ តាក់តែងឱ្យកើតមាន សារពាង្គកាយ ជីវិត គំនិត កំណើតសត្វលោក មិនដោយកុសលកម្មផង និង មិនដោយអកុសលកម្មផង ហើយនឹងរលត់កើតៗ ។

៥. **វិញ្ញាណខន្ធ** (គំនរនៃវិញ្ញាណ): ជាការប្រជុំនៃវិញ្ញាណទាំង ៥ មាន ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និង កាយវិញ្ញាណ។ វិញ្ញាណខន្ធ ជាធម្មជាតិដែលដឹងនូវ លោកខាងក្រៅ (ព្រឹត្តិការណ៍នានាដែលកើតឡើងលើរូបកាយ ឬ ដែលទាក់ទងនឹងកាយ) ដោយសារធាតុទាំង ៥ និងដឹងនូវ លោកខាងក្នុង (អារម្មណ៍ ចិត្ត) ប្រកបដោយការត្រិះរិះពិចារណា ។ វិញ្ញាណខន្ធ ជាតួនៃចុតិ និង បដិសន្ធិ ដោយអំណាចនៃកម្ម ក្រោមអំណាចនៃចិត្ត ដែលជីវិតកើតហើយស្លាប់ និងស្លាប់ហើយកើតវិញ ព្រោះកុសលកម្មនិងអកុសលកម្ម ។ វិញ្ញាណខន្ធ មាន ៣ ផ្នែក គឺ: កុសលវិញ្ញាណ អកុសលវិញ្ញាណ និង អព្យាកតវិញ្ញាណ ។

**កើតស្លាប់-ស្លាប់កើតដោយសារកម្ម**
**កម្មខ្មៅកម្មស កើតរហង់**

**រលត់ខន្ធ៥រលាយសូន្យបង់**
**ហៅថាចិត្តចង់ ជាចេតនា ។**

*ស៊ាន វ៉ិត*

វិញ្ញាណ មានពិការភាព (មានន័យថា ប្រព័ន្ធការពារសុខភាពកាយ និងលោកខាងក្នុងមាន អារម្មណ៍ ចិត្ត សតិ ប្រាជ្ញា ប្រែជាទន់ខ្សោយ អសមត្ថភាព) ដោយសារតែមនុស្សនោះប្រព្រឹត្តិតែអំពើដែលនាំឱ្យខូចសុខភាពកាយ និងសុខភាពចិត្ត ជាពិសេសអំពើអបាយមុខ ដូចជាការបង្កើនសម្រើបក្នុងកាមតណ្ហា ការផឹកគ្រឿងស្រវឹង ការប្រើឱសថខុស ការបរិភោគអាហារដែលមានជាតិពុល ការឆ្វាញ់នឹងសេចក្ដីខ្ជិលច្រអូស ការកំសាន្តខុស ការកែរូបកាយ ឧទាហរណ៍ វះកាត់អវយវះណា១ ការសិក្សារៀនសូត្រខុស ការមានជំនឿខុស ការយល់ខុស ការព្យាបាទ ការបៀតបៀន ការចងសេចក្ដីក្រោធខឹង ។



នៅពេលដែលមនុស្សស្លាប់ ខន្ធ ៥ ក៏បែកធ្លាយ ក្លាយទៅជាធាតុដើមវិញគឺ មេធម្មជាតិ មាន ធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ។ ដោយអំណាចនៃកម្ម ធាតុទាំង ៤ បង្កើតឱ្យមានកំណើតថ្មី ដែលមានរូបកាយ និង ចិត្ត ។ កាយនិងចិត្ត បង្កើតជា ជីវិតថ្មី ដែលជីវិត មានកម្មជាអកុសលផង និងកម្មជាកុសលផង ក៏នាំឱ្យមានទុក្ខពេញក្នុងជីវិត ព្រោះ អវិជ្ជា ។ ដើម្បីរដោះចាកទុក្ខ ត្រូវលះអកុសលកម្ម និងត្រូវខំសន្សំកុសលកម្មឱ្យបានច្រើនបំផុត និងត្រូវបង្កើតកម្មមិនស-កម្មមិនខ្មៅ ។

ការប្រកាន់មាំក្នុងបញ្ចក្ខន្ធ (ឧបាទានក្ខន្ធ) ជាទុក្ខ ។

## ខ. តើគួររស់នៅបែបណា ដើម្បីបានសេចក្តីសុខ-សេចក្តីចម្រើន?

មនុស្សគ្រប់រូប ប្រាថ្នារស់នៅប្រកបដោយសេចក្តីសុខ និងសេចក្តីចម្រើនរុងរឿងជានិរន្តរ៍ ប៉ុន្តែភាគច្រើនបំផុតរស់នៅក្នុងផ្លូវខុស ពោលគឺរស់នៅក្នុងភពវង្វេង ឬ គតិវង្វេង មានន័យថា មនុស្សចង់ចេះដឹងចង់មានបានតែបែរជាខ្ជិលធ្វើការ មិនខំអានសៀវភៅ ចង់បានសុខតែបែរជាសន្សំទង្វើបាប ចង់ឱ្យគេសរសើរតែបែរជាធ្វើទង្វើឱ្យគេស្អប់ខ្ពើម ចង់ឱ្យគេជួយតែបែរជាធ្វើជាសត្រូវគេទៅវិញ ចង់ល្អតែសេពគប់បុគ្គលពាល ។ មនុស្សចង់បានផ្លែឪឡឹកតែបែរជាខំដាំផ្លែក្រូចខ្លុងទៅវិញ នេះហើយ ហៅថា ខុស ឬ វង្វេង ( មិច្ឆាទិដ្ឋិ ) ។ បើអញ្ចឹង, តើគួររស់នៅដូចម្ដេច ដើម្បីបានសុខ ?

បាទ! ជីវិត ឬ ការរស់នៅ គួរត្រូវចាប់ផ្ដើមដោយយក **ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសារណៈ** គឺជាទីពឹង ជាទីរលឹក ទើបញ៉ាំងឱ្យមនុស្សនោះជួបប្រទះតែសេចក្តីសុខ-សេចក្តីចម្រើនយ៉ាងពិតប្រាកដ ។ មានតែការដើរតាមមាគ៌ានៃព្រះពុទ្ធឱវាទទេ ទើបសត្វលោកស្គាល់សុខតាមផ្លូវកាយផង និងសុខតាមផ្លូវចិត្តផង ហើយរមែងសម្រេចនូវសុខ ៣ ករិតមាន **មនុស្សសុខ** គឺសេចក្តីសុខក្នុងមនុស្ស **ទិព្វសុខ** គឺសេចក្តីសុខក្នុងទិព្វ និង **និព្វានសុខ** គឺសេចក្តីសុខក្នុងព្រះនិព្វាន ។

សេចក្តីសុខក្នុងមនុស្ស តាមព្រះពុទ្ធឱវាទ អាស្រ័យហេតុ ៤ យ៉ាង គឺ (១)សុខព្រោះទ្រព្យកើន, (២)សុខព្រោះចេះប្រើប្រាស់ទ្រព្យតាមផ្លូវសុចរិត, (៣)សុខព្រោះមិនជំពាក់បំណុលគេ, និង (៤)សុខព្រោះមិនមានទោសគឺមិនខុសក្នុងអកុសលកម្មបថ១០។ មនុស្សសុខ កើតអំពីការចិញ្ចឹមជីវិតត្រូវ ដែលអាស្រ័យការមានគុណសម្បត្តិ ៣ យ៉ាងគឺ :

១. **រក្សាសីល ៥** ដែលព្រះពុទ្ធបានសម្តែងថា ជាមាគ៌ានៃសេចក្តីសុខរបស់មនុស្ស និងជាមាគ៌ាឆ្ពោះទៅកាន់កំណើតថ្មីនៅក្នុងទេវលោក ។ អ្នកសុំសីល រមែងមិនធ្វើការងារមានទោសទាំង ៥ យ៉ាង ដែលព្រះសម្មាសម្ពុទ្ធ បានហាមគឺ មិនជួញគ្រឿងសាស្ត្រាវុធ, មិនជួញដូរមនុស្ស, មិនជួញសត្វ, មិនជួញគ្រឿងស្រវឹង, មិនជួញថ្នាំពិសថ្នាំពុល ដោយសារការប្រកបការងារជំនួញទាំងនេះ នាំមកនូវសេចក្តីវិនាស សេចក្តីក្តៅក្រហាយ និងទុក្ខដល់អ្នកធ្វើ ដល់សាច់ញាតិ និងសង្គម ។ សីល ៥ នាំអ្នកបដិបត្តិ ស្អាតកាយស្អាតវាចា និង ស្អាតចិត្ត ឱ្យសុខដល់ខ្លួនឯងផង ឱ្យសុខដល់អ្នកដទៃផង ។ បើចង់បានទ្រព្យសម្បត្តិដោយរស់នៅសុខ ត្រូវចិញ្ចឹមសីល ៥ នេះឱ្យល្អពិត ។ ដើម្បីយល់បន្ថែមអំពីសិក្ខាបទរបស់សីល ៥ ឬ សីល ៨ សូមលោកអ្នកអាន បើកទំព័រ ៥៧ ។

---

**ការបង្កើនមេត្តាធម៌ ជាការសន្សំសុខគ្រប់យ៉ាង ។**

*ស៊ាន វិត*

---

២. **មាន"លោកិយបញ្ញា"** គឺប្រាជ្ញាយល់ច្បាស់អំពីផ្លូវលោក បានដល់ សមត្ថភាពក្នុងផ្លូវលោក ដែលចាំបាច់ត្រូវមានសមត្ថភាព ៣ យ៉ាង (១)**ចំណេះដឹង** គឺយល់ដឹងច្បាស់អំពីសង្គម អំពីការងារ អំពីការគ្រប់គ្រងអំពីខ្លួនឯងនិងអ្នកដទៃ អំពីពេលវេលា អំពីលុយនិងទ្រព្យឯទៀត១ អំពីសុខភាព អំពីតម្លៃពិតនៃជីវិត អំពីចំណេះដឹងចាំបាច់, (២)**គុណធម៌** បានដល់ សេចក្ដីទៀងត្រង់ សេចក្ដីអត់ធ្មត់ ទំនួលខុសត្រូវ មេត្តា-ករុណា ការដឹងគុណ ការជួយយកអាសាអ្នកដទៃដោយស្មោះសមិនលំអៀង, និង (៣)**វិជ្ជាការ** គឺត្រូវមានជំនាញការងារដែលកំពុងធ្វើនោះ ប្រកបដោយបទពិសោធន៍ល្អគ្រប់គ្រាន់យ៉ាងប៉ិនប្រសប់ ។

៣. **មានឥទ្ធិបាទ ៤** ឱ្យគ្រប់ (១)**ឆន្ទៈ** គឺ គោលបំណង, ការពេញចិត្ត, ចេតនាល្អ គឺថា ត្រូវមានបំណងឱ្យច្បាស់ បើជ្រើសយកការងារណាត្រូវឱ្យប្រាកដ ហើយធ្វើដោយការពេញចិត្តនិងចេតនាល្អ, (២)**វីរិយៈ** គឺសេចក្ដីព្យាយាមត្រូវ, ការតស៊ូទៅមុខមិនរាថយ គឺថាត្រូវខិតខំ អត់ធ្មត់ព្យាយាម ប្រឹងប្រែងធ្វើក្នុងគ្រប់ការងារតូចធំទាំងឡាយដោយមិនប្រមាទ, (៣)**ចិត្តៈ** គឺការតម្កល់ចិត្ត, ការប្រើគំនិតត្រិះរិះគិតក្នុងវីរិយៈនិងក្នុងវិធីនាំជោគជ័យ, (៤)**វិមំសា** គឺបញ្ញា សេចក្ដីដឹងច្បាស់ក្នុងសច្ចៈនានាដែលនាំជោគជ័យនិងសេចក្ដីសុខ ។ ព្រះពុទ្ធ សម្ដែងថា ការងារតូចធំក្នុងផ្លូវលោកនិងផ្លូវធម៌ ពុំអាចសម្រេចលទ្ធផលល្អដោយងាយ១ទេ ទាល់តែមាន ឥទ្ធិបាទទាំង ៤ នេះ ។

## គ. តើហេតុនៃកំណើតកូនយ៉ាងដូចម្តេច?

តាមទ្រឹស្តីព្រះពុទ្ធសាសនា មូលហេតុដែលនាំឱ្យ កូនមានកំណើត (ចាប់បដិសន្ធិ) មាន ៣ យ៉ាង ដូចខាងក្រោម ៖

១. មាតាបិតា បានរួមរស់មេត្រីជាមួយគ្នា (រួមដំណេក) ។

២. មាតាមានឧតុសម័យល្អ (ទើបមានផ្ការដូវរួចហើយ) ។

៣. មានវិញ្ញាណបម្រុងមកចាប់កំណើត ។

ទាំង ៣ ខាងលើនេះ បើខ្វះហេតុណា១ មិនអាចមានកំណើតថ្មី កើតបានឡើយ ។ នៅក្នុងហេតុទាំង ៣ នេះ យើងឃើញថា អំណាចនៃគុណរបស់ឪពុកម្តាយ មាន ២ ហេតុ ក្នុងហេតុទាំង ៣ ។ ដូចនេះ បើគ្មានឪពុកនិងម្តាយ គ្មានកំណើតកូនឡើយ ។ លោកទាំងពីរ មិនត្រឹមតែជាហេតុដ៏សំខាន់បំផុតក្នុងការទទួលយកការចាប់បដិសន្ធិរបស់កូន ថែមទាំងថែរក្សាកំណើតក្នុងផ្ទៃបានដោយល្អបំផុត និងមានទំនួលខុសត្រូវទៅលើការធានារ៉ាប់រង ឱ្យកូនមានជីវិតរស់នៅលើលោកនេះផងទៀត ដែលគ្មានមនុស្សណា ឬ ទេវតាណា ឬ ព្រះអង្គណា អាចធ្វើកិច្ចការដ៏ធ្ងន់ធ្ងរបំផុតទាំងពីរដំណាក់នេះ បានយ៉ាងប្រសើរ យ៉ាងប៉ុនប្រសប់ដូចលោកទាំងពីរឡើយ ដូច្នេះហើយ បានជាលោកទាំងពីរ មានគុណរាប់មិនអស់ ច្រើនអនេក ឥតមានអ្វីមកប្រៀបផ្ទឹមបាន ។

ថ្វីត្បិតតែ យើងមិនអាចគណនាគុណរបស់លោកទាំងពីរបាន តែអាចកំណត់គុណដ៏មហិមារបស់លោកជា ៣ ក្រុម ៖

១. **អដ្ឋិគុណៈ** គុណដែលលោកទាំងពីរ បានបង្កើតរូបកាយឱ្យកូន ដោយធាតុ ៤ គឺ ដី ទឹក ភ្លើង ខ្យល់ ដែលគ្មានបុគ្គលណាអាចធ្វើដូច្នេះបានទេ ក្រៅតែអំពី ឪពុកម្ដាយ ។

២. **វិសេសគុណៈ** គុណដែលលោកទាំងពីរ បានចិញ្ចឹមកូនពីពេលកើតចេញពីផ្ទៃម្ដាយរហូតកូនពេញវ័យ ដោយសេចក្ដីស្រឡាញ់ អាណិតអាសូរ ដ៏ស្មោះស ឥតមានទាមទារប្រយោជន៍អ្វីវិញឡើយ ហើយគុណវិសេសមានដោយព្រហ្មវិហារធម៌ទាំង ៤ គឺ មេត្តា ករុណា មុទិតា ឧបេក្ខា ដល់កូន។

៣. **គុណូបការគុណៈ** គុណដែលលោកទាំងពីរ បានទំនុកបម្រុងកូនឱ្យល្អ បានសិក្សារៀនសូត្រចេះដឹង ឱ្យមានអនាគតល្អ ។

ជារួម ឪពុកម្ដាយ បានឱ្យកូននូវអ្វីដែលមនុស្សដទៃមិនអាចមានលទ្ធភាពឱ្យកូនបាន ដោយអ្វីទាំងនោះ ធំហួសប្រមាណ ទើបយើងមិនអាចវាស់ឬកំណត់ឬរាប់គុណរបស់លោកទាំងពីរបាន ដូច្នេះហើយ លោកទាំង២មានឈ្មោះថា **ព្រះរស់** ឯកូនល្អ ត្រូវរស់ខំសន្សំទង្វើតបគុណ ។

---

**"គ្មានបុគ្គលណា ស្រឡាញ់អ្នក ជាងឪពុកម្ដាយរបស់អ្នកឡើយ ។"**

*ស៊ាន វិត*

---

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R P.P

## ឃ. តើឪពុកម្តាយជាព្រះរស់ មានន័យដូចម្តេច?

ឪពុកម្តាយ គឺជាព្រះថ្នាក់កំពូលបំផុតរបស់កូនគ្រប់រូប ក៏ព្រោះថា នៅលើលោកសន្និវាសនេះ គ្មានមនុស្សណា ទេវតាណា ល្អវិសេសមកលើ កូនជាងឪពុកម្តាយឡើយ ។ ដូចនេះហើយ បានជា គេហៅ ឪពុកម្តាយ ថាជា ព្រះរស់ របស់កូន ក្នុងន័យ ៣ យ៉ាងគឺ (១) **ឪពុកម្តាយ ជាព្រះបង្កើតកូន** ឱ្យមានជីវិតនៅលើលោកនេះ ដែលគ្មានព្រះឯណាផ្សេង ទៀត អាចបង្កើតកូនបានដូចជា ឪពុកម្តាយទេ បើទោះជា ឪពុកម្តាយខ្លះ បង្កើតកូនដោយសុឆន្ទៈក្តី ឬ ដោយអសុឆន្ទៈក្តី ។ (២) **ឪពុកម្តាយ ជាព្រះចិញ្ចឹមកូន** បីបាច់ ថែរក្សា ការពារ យកចិត្តទុកដាក់ទាំងថ្ងៃយប់ មើលការខុសត្រូវលើកូន ដើម្បីឱ្យកូនធំធាត់ រហូតដល់កូនធំពេញវ័យ អស់ពេលវេលាយ៉ាងតិច ១៨ ឆ្នាំ ។ (៣) **ឪពុកម្តាយ ជាព្រះជួយកូន** ឱ្យ រស់នៅដោយសេចក្តីថ្លៃថ្នូរ ពោលគឺ រស់ដោយសេចក្តីសុខ-សុភមង្គល សេចក្តីចម្រើន នៅក្នុងសង្គម ។ ឪពុកម្តាយ ជួយកូន នៅត្រង់ទំនុកបម្រុង កូន ឱ្យបានសិក្សារៀនសូត្រគ្រេបជញ្ជក់យកចំណេះវិជ្ជាទាំងផ្លូវលោកនិង និងផ្លូវធមិដើម្បីឱ្យកូនបានទទួលអាវុធទិព្វនេះសម្រាប់ការពារនិងថែរក្សា ខ្លួនឯងនៅក្នុងដំណើរជីវិត។ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់លាស់អំពីលក្ខណៈ ឬ កិច្ចការរបស់ឪពុកម្តាយ សូមអានសៀវភៅ "**ឪពុកម្តាយល្អពិត របស់កូន**" ។

# ខ. តើកូនមាន ៣ ពួក អ្វីខ្លះ?

ព្រះមានព្រះភាគទ្រង់ត្រាស់ថា "បុត្រមាន ៣ ពួក រមែងប្រាកដក្នុងលោក គឺ អតិជាតបុត្រ១ អនុជាតបុត្រ១ អវជាតបុត្រ១" ។

## ១. អតិជាតបុត្រ

អតិជាតបុត្រ ជាបុត្រដែលបានកប់កំណប់ជាកុសលកម្មយ៉ាងច្រើន តាំងពីកំណើតជាតិមុន មាន ទាន សីល ភាវនា ទើបនៅក្នុងបច្ចុប្បន្នជាតិ បុត្រប្រភេទនេះ ជាបុត្រខ្ពង់ខ្ពស់ ឧត្តុង្គឧត្តម វិសេសវិសាលក្រៃ ដោយយកព្រះរតនត្រ័យ ជាសារណគមណ៍ គឺថា បុត្រនេះ យកព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាទីគោរពបូជា ជាទីពឹង ជាទីរលឹក នៅក្នុងជីវិតរបស់ខ្លួន ។



អតិជាតបុត្រ មានលក្ខណៈពិសេស សម្រាប់សំគាល់ ៣ យ៉ាងៈ

### [ក] សីល

អតិជាតបុត្រ មានសីល ៥ ឬ សីល ៨ ឬ សីល ១០ ជាដង្ហើម និងជាសរសៃឈាម សម្រាប់រស់នៅក្នុងជីវិតប្រចាំថ្ងៃ ។ បុត្រដែលយកសីល ធ្វើជាចរិយាធម៌រស់នៅ ព្រោះ**មានបញ្ញាជ្រៅ** គឺយល់ដឹងត្រូវស្គាល់ខុសស្គាល់ត្រូវ **មានសទ្ធា** គឺជឿលើកម្មផល ជឿបុណ្យបាប និង

**មានទាន** គឺការលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដោយការបរិច្ចាគទាន ទាំងអាមិសទាន និងធម្មទាន ដូច្នេះក៏ប្តេជ្ញារស់នៅដោយសីល តាមគន្លងនៃព្រះពុទ្ធធមិ បើទោះជាមើលឃើញថា មាតាបិតា បានរក្សាសីល ធ្វើទាននិងភាវនា ឬ មិនទាន់បានក៏ដោយចុះ ។ បុត្រដែលរក្សាសីលបានល្អពិតប្រាកដ តែងជាមនុស្សមាន សមត្ថភាព លទ្ធភាព និងមាន មេត្តា-ករុណា ជួយសង្គ្រោះខ្លួនឯងពិត ឱ្យឃើបផុតពីទុច្ចរិតទាំង៣ គឺ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ព្រមទាំងអាចជួយញាតិមិត្តជិតឆ្ងាយបានផង ។ កូនដែលមានសីលជាគ្រឿងអលង្ការ ពាក់ជាប់កាយ ជាប់វាចា និង ជាប់ចិត្ត តាមពុទ្ធវចនៈ តែងទទួលបាននូវ**អានិសង្ស ៥** យ៉ាង គឺ : (១) មានទ្រព្យសម្បត្តិបរិបូរដោយសុចរិត ព្រោះមានសម្មាអាជីវៈ (ការចិញ្ចឹមជីវិតត្រូវ) ដោយបញ្ញា ជាមធ្យោបាយ (២) មានកេរ្តិ៍ឈ្មោះល្អ នៅគ្រប់ទីស្ថាន ព្រោះសាងតែអំពើជាប្រយោជន៍ពិតដល់គេឯងដោយបញ្ញា (៣) មានទឹកមុខស្រស់បស់ ប្រិមប្រិយ រីករាយ ជាប្រចាំ ព្រោះ សាងតែអំពើល្អពិតដោយបញ្ញា គ្មានគ្រោះភ័យណាមកបំភ័យនិងធ្វើឱ្យទុក្ខព្រួយឡើយ (៤) មានសតិរលឹកត្រូវជានិច្ច ព្រោះតែបានសាងអំពើល្អទុកតាមថែរក្សា និង (៥) មានកំណើតថ្មីនៅសុគតិភព (ឋានសួគ៌) ។

មនុស្សទាំងឡាយណាដែលមិនរក្សាសីល មិនមានលក្ខណៈពេញលេញជាមនុស្សទេ ហើយក៏មិនអាចរក្សាភាពជាមនុស្សបានដែរ ត្បិតមានរូបកាយជាមនុស្ស ។

## [៦] អរិយកិច្ចនៃកូនល្អពិត

អតិជាតបុត្រ ជាបុត្រអាចបំពេញអរិយកិច្ចនៃកូនល្អពិតបាន ចំពោះមាតាបិតា មានកត្តញ្ញូតាធម៌ប្រកបដោយកតវេទិតាធម៌ ពោលគឺ តបឧបការគុណមាតាបិតា ដោយការបម្រើ ការចិញ្ចឹម និងការសង្គ្រោះ មាតាបិតា ឱ្យងើបផុតពីការលំបាកកាយចិត្ត និងផុតពីអកុសលកម្ម១០ ដែលអកុសលកម្មនេះមិននាំលោកទាំងពីរទៅកាន់ឋានដ៏ថ្លៃថ្នូរទេ ។

ព្រះសម្មាសម្ពុទ្ធ មានពុទ្ធដីកាថា មានបុគ្គល ២ ពួក រកបាន ដោយកម្រ ក្នុងលោក គឺ (១) **បុគ្គលដែលធ្វើឧបការៈទុកមុន ១ ហៅថា បុព្វការី និង (២) បុគ្គលដែលដឹងឧបការៈដែលអ្នកដទៃបានធ្វើហើយ ធ្វើតបវិញ ១ ហៅថា កតញ្ញូកតវេទី ។**

បុត្រដែលជាកតញ្ញូកតវេទី ចំពោះមាតាបិតា ជាមនុស្សមាន ទំនួលខុសត្រូវពេញលេញក្នុងគ្រប់តួនាទីរបស់ខ្លួន រមែងជាបុត្រដែលសំបូរ ដោយសេចក្ដីសុខ សេចក្ដីចម្រើន ដោយសម្បត្តិទាំង ៣ ដែលជាសម្បត្តិ បានដោយកម្រក្នុងលោក នោះគឺ សម្បត្តិមនុស្ស សម្បត្តិទេវតា និង សម្បត្តិព្រះនិព្វាន ។

សូមលោកអ្នក យកចិត្តទុកដាក់អានខ្លឹមសារនៃ "កូនល្អពិត រក្សាអរិយកិច្ច ៣ យ៉ាង" ត្រង់ទំព័រ ៦០ ឱ្យបានយល់ច្បាស់ប្រាកដ ព្រមជាមួយការអនុវត្តតាម រហូតបានលទ្ធផលល្អ ព្រោះតម្លៃពិតនៃជីវិត គឺស្ថិតត្រង់ការបំពេញកិច្ចការទាំងនេះ ។

## [គ] លទ្ធផលត្រូវ

លទ្ធផលត្រូវ ជាគុណវិសេសបញ្ជាក់ថា បុត្រនេះ ពិតជាអតិជាតបុត្រ ព្រោះមិនត្រឹមតែមានសមត្ថភាពរក្សាសីលនិងអរិយកិច្ចបានដោយល្អពិតនោះទេ ថែមទាំងមានបញ្ញាអាចធ្វើឱ្យលទ្ធផលសមតាមការប្រព្រឹត្តដ៏ត្រឹមត្រូវទាំងនោះ កើតចេញជារូបរាងផង ។ អតិជាតបុត្រ អាចធ្វើឱ្យលទ្ធផលល្អកើតឡើង ព្រោះមានកំឡាំង ៧ យ៉ាង តាមព្រះពុទ្ធឱវាទ គឺ :

- កំឡាំងសទ្ធា ១: ជឿកម្មផល បុណ្យបាប គុណទោស ជឿព្រះធម៌...
- កំឡាំងព្យាយាម ១: តស៊ូ ជំនះគ្រប់ឧបសគ្គ អត់ធ្មត់ ខំប្រឹងប្រែង...
- កំឡាំងហិរិ ១: ខ្មើមបាប មិនប្រព្រឹត្តអំពើអបាយមុខ ទុច្ចរិតនានា...
- កំឡាំងឱត្តប្បៈ ១: ខ្លាចបាបវៀរចាកចេញឆ្ងាយពីទុច្ចរិតគ្រប់យ៉ាង...
- កំឡាំងសតិ ១: មានការចងចាំល្អ រលឹកគិតរឿយៗដល់ព្រះធម៌ គុណ..
- កំឡាំងសមាធិ ១: មានកំឡាំងចិត្តខ្លាំង មានវិន័យកាយ វាចា ចិត្ត...
- កំឡាំងបញ្ញា ១: យល់ឃើញត្រូវ គិតត្រូវ មានប្រាជ្ញាស្រាយបញ្ហា...



---

រស់គង់ស្លាប់យូរឆាប់មិនដឹង | ម្តេចមិនខំប្រឹង តបស្នងគុណ
កុំធ្វើបាបព្រះឱ្យរែកពន់ | ទឹកភ្នែកយប់យន់ ហូរព្រោះកូន ។

*ស៊ាន វិត*

---

## ២. អនុជាតបុត្រ

អនុជាតបុត្រ ជាបុត្រដែលបានកប់កំណប់ជាកុសលល្មម ខាងបញ្ញា គឺស្រឡាញ់ការទូន្មាន ប្រៀនប្រដៅ ចេះចាំភាសិត ស្រឡាញ់ការសិក្សារៀនសូត្រ បានសាងអំពើល្អច្រើន កាលពីជាតិមុន ទើបបានជាក្នុងជាតិនេះ អនុជាតបុត្រ មានលក្ខណៈងាយទទួលការអប់រំប្រដៅពីគេឯងហៅថា មនុស្សដែលគេប្រដៅងាយ ។ ដោយសារមានសម្បត្តិល្អទាំងនេះហើយ បុត្រប្រភេទនេះ តែងទទួលបាន ការស្រឡាញ់ សេចក្តីអាណិតអាសូរ ការកោតសរសើរ ពីអ្នកដទៃទាំងពួង នៅគ្រប់ទីកន្លែងអាស្រ័យដោយការចេះគោរពគេបានល្អ ។

អនុជាតបុត្រ ជាបុត្រល្អក្នុងលំដាប់លេខ២ បន្ទាប់ពីបុត្រខ្ពង់ខ្ពស់ គឺអតិជាតបុត្រ ដែលបុត្រទាំង២លំដាប់នេះ មានដោយកម្រនៅក្នុងសង្គមបច្ចុប្បន្ន ។ បើបុត្រណា អាចកែប្រែ លត់ដំ អប់រំខ្លួន ឱ្យក្លាយទៅជាបុត្រល្អណា១បាន ជាការប្រពៃណាស់ ខ្ញុំបាទសូមចូលរួមកោតសរសើរស្ញប់ស្ញែង លើកតម្កើង ។ ការរស់នៅត្រូវ គឺការខិតខំ ព្យាយាម កសាងខ្លួនឱ្យក្លាយជាកូនល្អពិត ពោលគឺ អតិជាតបុត្រ ឬ អនុជាតបុត្រ ។

---

**ព្រះពុទ្ធមានពុទ្ធដីកាថា "ធម៌ពីរដែលជាចំណែកនៃសេចក្តីវិនាស គឺ ភាវៈជាអ្នកដែលគេស្តីប្រដៅបានដោយកម្រ ១, ភាវៈជាអ្នកគប់មិត្តអាក្រក់ ១" ។**

---

អនុជាតបុត្រ មានលក្ខណៈសម្បត្តិសំខាន់ៗ ៣ យ៉ាង :

## [ក] ភាពជាមនុស្សដែលគេប្រដៅងាយ

អនុជាតបុត្រ តែងប្រកបដោយធម៌គោរព ចេះស្ដាប់ឱវាទអប់រំទូន្មានប្រៀនប្រដៅ ពីសប្បុរស ពីបណ្ឌិត ពីកល្យាណមិត្ត ជាពិសេសពីឪពុកម្ដាយ នាំឱ្យបានជាបុគ្គលដែលមានបញ្ញា ការចេះដឹងត្រូវ ការតាំងចិត្តមុតមាំត្រូវ ធ្វើឱ្យអ្នកទាំងឡាយស្រឡាញ់រាប់អាន អាណិតអាសូរ លះបង់ជួយជ្រោមជ្រែង ឱ្យថ្កុំថ្កើងរុងរឿង ។

មនុស្សដែលគេប្រដៅងាយ មានកិរិយា ៦ យ៉ាងជាសំគាល់ :

- **មានឫកពារជាអ្នកចេះស្ដាប់ល្អ** : ស្ដាប់ដោយយកចិត្តទុកដាក់ មិនបង្កការរំខានដល់អ្នកនិយាយអប់រំ ចេះកត់ចំណាំពាក្យពេជន៍ដែលគេប្រៀនប្រដៅហើយយកទៅរំលឹកសិក្សា ចេះស្ដាប់ដោយញញឹម ចេះសួរសំណួរឆ្លាតឈ្លាសទាំងក្នុងពេលស្ដាប់និងក្រោយពេលអនុវត្តតាម ។

- **មានសេចក្ដីអត់ធន់** : ត្រូវចេះអត់ធន់ ៣ យ៉ាង គឺ ចេះអត់ធ្មត់ចំពោះការលំបាកដោយសារលក្ខណៈនៃធម្មជាតិ ដូចជា ក្ដៅ ត្រជាក់ រងារងងិត ព្រលឹម អធ្រាត្រ, ចេះអត់ធ្មត់ចំពោះទុក្ខវេទនាតាមផ្លូវកាយនិងចិត្ត ដូចជា មានជំងឺ ការស្ពឹករោយស្រពន់ដៃជើង ការឈឺចុកចាប់ ការទាស់ចិត្តសេចក្ដីខឹងក្រោធរបស់គេ ការរំលោភបំពាន ការបញ្ឈឺចិត្ត, និង ចេះអត់ធ្មត់ចំពោះការងារនិងការហ្វឹកហាត់ ។

- **មានសេចក្តីគោរព** : ត្រូវខំធ្វើតាមឱវាទទូន្មានបង្ហាញផ្លូវ ឱ្យចេះរស់នៅត្រូវនិងធ្វើត្រូវដើម្បីបានលទ្ធផលល្អ និងត្រូវចេះគោរពមនុស្សទាំងឡាយទាំងអ្នកធំអ្នកតូច ទាំងចាស់ទាំងក្មេង ដោយបែងចែកលក្ខណៈនៃការគោរពឱ្យបានត្រឹមត្រូវថ្លៃថ្នូរ ។

- **មិនបិទបាំងកំហុស** : ត្រូវមានសេចក្តីក្លាហាននិងស្មោះត្រង់ដល់ការសារភាព ឬ បង្ហាញនូវកំហុស ដែលធ្លាប់ប្រព្រឹត្តិនិងកំពុងប្រព្រឹត្តហើយទទួលស្គាល់ថា នោះជាកំហុសរបស់ខ្លួនឯង មិនទម្លាក់កំហុសដាក់អ្នកដទៃ។ មនុស្សទូទៅមិនមានសេចក្តីស្មោះត្រង់និងទំនួលខុសត្រូវចំពោះកំហុសរបស់ខ្លួនឡើយ តែងតែមានចេតនាបិទបាំង លាក់បំពួនកំហុស ព្រោះខ្លាចគេស្តីបន្ទោស ខ្លាចខ្មាសគេ ខ្លាចគេមិនសរសើរ ជាដើម ។ តាមពិត, មនុស្សដែលអ្នកប្រាជ្ញ អ្នក ខ្ពង់ខ្ពស់ សូម្បីព្រះសម្មាសម្ពុទ្ធ តែងសរសើរដល់បុគ្គលដែលស្មោះត្រង់នឹងកំហុស ហើយចេះកែពិតប្រាកដ ត្បិតបុគ្គលអស្ចារ្យទាំងឡាយ តែងស្គាល់កំហុស រៀនពីកំហុស ហើយកែប្រែ។

- **យកចិត្តទុកដាក់កែកំហុស** : កំហុស ប្រៀបដូចជាបំណុល បើលោកអ្នកធ្វើខុស ប្រៀបដូចជាបានជំពាក់បំណុលគេអញ្ចឹងដែរ គប្បីត្រូវតែសងបំណុលគេទាំងដើមទាំងការ(ប្រាក់) បើមិនសងទេ មានន័យថាលួច ឬ បោកប្រាស់យកទ្រព្យគេហើយ ។ បំណុលមានម្ចាស់ រីឯកំហុស ក៏

មានម្ចាស់ ។ កំហុសតូច ក៏អាចក្លាយជាធំ កំហុសធំ ក៏អាចក្លាយជាតូច អាស្រ័យលើ ម្ចាស់កំហុស និង អ្នករងកំហុស និង ពេលវេលា ។ បើលោកអ្នកធ្វើខុស តែមិនកែ ឬ កែមិនបាន ប្រៀបដូចជា មិនព្រមសងបំណុលគេ ឬ សងបំណុលគេមិនទាន់អស់ ។ ដូច្នេះ បើខុស ចូរចេះកែ ដោយ ទី១ ត្រូវទទួលស្គាល់កំហុសរបស់ខ្លួន ទី២ ត្រូវគិតពិចារណាឱ្យម៉ត់ចត់អំពីមូលហេតុនៃកំហុសនិងគ្រោះថ្នាក់ដោយសារកំហុសនោះ ទី៣ ត្រូវរិះរកវិធីកែកំហុសឱ្យបានដាច់ស្រេច បើចាំបាច់ត្រូវសុំដំបូន្មានពីសប្បុរស ទី៤ ត្រូវកែកំហុសនោះដោយស្មោះត្រង់ ដោយបញ្ញា ដោយសមត្ថភាព ដោយគុណធម៌ និង ទី៥ ត្រូវការពារកុំឱ្យកំហុសដដែលនោះកើតឡើងម្តងទៀត ដើម្បីកុំឱ្យបាត់បង់ការទុកចិត្តពីគេឯងនិងកុំឱ្យកើតមានចរិតស្រឡាញ់នូវកំហុសថ្មីចាស់ ។

- **មិនសំឡឹងកំហុសអ្នកដាស់តឿន** : មនុស្សល្អ គប្បីមានចិត្តរីករាយ ថ្លែងអំណរគុណ ដឹងគុណ សរសើរដល់អ្នកដាស់តឿនក្រើនរំឭក ទាំងនៅចំពោះមុខ និងនៅទីកំបាំងមុខ តែងគិតឃើញចំនុចល្អៗទាំងឡាយរបស់អ្នកទូន្មាន ដោយមិនហ៊ានមានចិត្តគិតដល់កង្វះខាតបន្តិចបន្តួចឡើយ ត្បិតមនុស្សតែងមានលក្ខណៈខុសគ្នាខ្លះ ហើយក៏មិនល្អឥតខ្ចោះដែរ ប៉ុន្តែបើចង់ឱ្យអ្នកដាស់តឿនកាន់តែល្អប្រសើរ ត្រូវខិតខំសរសើរឱ្យច្រើន ។

ម្យ៉ាង បើពូកែខាងសំឡឹងកំហុស នោះពិតជាក្លាយជាមនុស្សលុបគុណលុបប្រយោជន៍ដែលគេបានផ្ដល់ឱ្យខ្លួនជាប្រាកដ រហូតដល់ចងជាសត្រូវផង ។ ព្រះពុទ្ធ បានសម្ដែងថា បើអ្នកសរសើរបុគ្គលពាល អ្នកនឹងបាបធ្ងន់ ព្រោះការសរសើរនោះ នាំឱ្យរីកដុះដាលបុគ្គលពាលកាន់តែច្រើន ដែលធ្វើឱ្យសង្គមមិនទទួលបានសុខសន្តិភាព ហើយបើអ្នកសរសើរបណ្ឌិត សប្បុរស កល្យាណមិត្ត អ្នកនឹងបានបុណ្យច្រើន ព្រោះការសរសើរនោះ នាំឱ្យបុគ្គលនោះកាន់តែល្អឡើងៗ ហើយនាំឱ្យរីកដុះដាលបុគ្គលល្អកាន់តែច្រើនឡើងយ៉ាងឆាប់ អាចស្រោចស្រង់សង្គម ឱ្យមានសេចក្ដីសុខ សន្តិភាពបរិបូណ៌។

### [ខ] សីល

អនុជាតបុត្រ មានសេចក្ដីរីករាយ ជ្រះថ្លា គោរពប្រណិប័តន៍តាមឱវាទរបស់មាតាបិតា ដែលប្រកបដោយសីល ទាន និង ភាវនា ។ អនុជាតបុត្រ រស់នៅតាមគន្លងនៃមាតាបិតា គឺថា មានសីល និង ធម៌ ជាខ្យល់ដង្ហើម និងជាម្ហូបអាហារ ។ មាតាបិតាដែលល្អប្រកបដោយសីល ព្រោះតែយល់ឃើញច្បាស់អំពីអានិសង្សនៃជីវិតមានសីល ក៏មានមេត្តា-ករុណា ដឹកនាំបុត្រឱ្យប្រតិបត្តិតាមធម្មអារ្យ គឺសិក្ខាបទ ៥ ឬ សីល ៥ ឬ និច្ចសីល នៅក្នុងជីវិតប្រចាំថ្ងៃ តាំងពីក្មេងវ័យ ដើម្បីសេចក្ដីសុខ-សេចក្ដីចម្រើន និងរុងរឿងនៅក្នុងជីវិតរបស់បុត្រ ព្រោះថា មានតែ សីល និង

ព្រះធម៌ទេ ដែលជាទីពឹងពិតប្រាកដរបស់បុត្រជាដរាប ។ **រក្សាសីល ៥ គឺ ដើម្បីរក្សាតំណែងជាមនុស្ស និង ដើម្បីបានសម្បត្តិមនុស្សនិងទេវតា ។**

## [គ] កតញ្ញូតាធម៌ និង កតវេទិតាធម៌

គុណធម៌មេរបស់កូនល្អ ចំពោះឪពុកម្ដាយគឺ កតញ្ញូតាធម៌និង កតវេទិតាធម៌ ដែលមិនអាចខ្វះធម៌ណា១បានឡើយ ដើម្បីធ្វើខ្លួនជាកូន កតញ្ញូ ឬ កូនល្អពិត ។ អនុជាតបុត្រ រមែងខិតខំធ្វើតបនូវគុណមាតាបិតា តាមគ្រប់កិរិយា ដោយកាយ វាចា និងចិត្ត ។ សេចក្ដីល្អ ចំពោះញាតិជិតឆ្ងាយ ជាអាហារដ៏ឆ្ងាញ់របស់អនុជាតិបុត្រ ក្នុងការលើកតម្កើងគុណជូនមាតាបិតា ដែលតែងទទួលបានការកោតសរសើរថា មានបុត្រតាមគន្លង ។ អនុជាតបុត្រ ជាបុត្រដែលខិតខំសិក្សារៀនសូត្រស្វែងយល់ឱ្យបានច្បាស់លាស់អំពីទំហំនៃគុណរបស់មាតាបិតា មិនមែនគ្រាន់តែចេះតែថាតាមគេថា មាតាបិតាជាព្រះ មានគុណមហាធំ មហាធ្ងន់ មហាច្រើនអនេកទាំងល្ហៃល្ហើនោះឡើយ ត្រូវយល់ដឹងត្រូវអំពីគុណ (កតញ្ញូតាធម៌) ហើយត្រូវយល់ដឹងត្រូវអំពីការបដិបត្តិតបគុណនិងខំតែធ្វើតបគុណ (កតវេទិតាធម៌) ។

---

**"មនុស្សល្អពិត រមែងមានគុណធម៌មេចំនួន ៣ គឺ : ការដឹងគុណ មេត្តា-ករុណា និង ទំនួលខុសត្រូវ ។"** *ស៊ាន វិត*

---

## ៣. អវជាតបុត្រ

អវជាតបុត្រ ជាបុត្រមានលក្ខណៈផ្ទុយពី អនុជាតបុត្រ ហើយរឹតតែមិនអាចប្រៀបផ្ទឹមជាមួយនឹង អតិជាតបុត្រ ទៅទៀត ។ អវជាតបុត្រ មានធម៌ប្រមាទ និងធម៌អកត្តញ្ញូ ជាកល្យាណធម៌ ។

កល្យាណធម៌របស់អវជាតបុត្រ មាន ១៦ ដូចខាងក្រោម :

១. ការរំពៃចង់បានរបស់គេ
២. ខឹងក្រោធ, ប្រទូស្ត
៣. វង្វេង បាត់ស្មារតី គ្មានសុភវិនិច្ឆ័យ
៤. ចិញ្ចឹមសេចក្តីក្រោធ
៥. រមិលគុណ
៦. លើកតម្កើងខ្លួនហួស
៧. ច្រណែនឈ្នានីស, ប្ញសា្យ
៨. កំណាញ់
៩. លាក់ពុត, លាក់កំហុស
១០. អួតអាង
១១. រឹងរូស, ក្បាលរឹង
១២. ចចេស, ប្រកាន់ខ្លួន
១៣. ខ្ជិលច្រអូស
១៤. ប្រមាថមើលងាយគេ
១៥. ស្រវឹងស្រី ស្រា ល្បែង
១៦. ប្រមាទ, ប្រហែសធ្វេស ។

"កាលណាមនុស្ស រស់វង្វេងនឹងប្រាក់ យសស័ក្តិ មុខមាត់ កាមគុណ រមែងរមិលគុណ និងគ្មានពេលវេលាតបស្នងគុណព្រះទាំងពីរ ។"

*ស៊ាន វុិត*

## ឆ. តើមនុស្សមាន ៤ ពួក អ្វីខ្លះ?

នៅក្នុងព្រះពុទ្ធសាសនា មនុស្សត្រូវកំណត់សំគាល់ជា ៤ ប្រភេទផ្សេងៗពីគ្នា ទៅតាមកិរិយាប្រព្រឹត្តរបស់មនុស្សនោះ ដូចខាងក្រោម ៖

១. **មនុស្សទេវោ:** មនុស្សដែលមានសមត្ថភាពជួយខ្លួនឯង ឱ្យរស់នៅតែជាមួយកុសលកម្មបថ ១០ មានទាំងសេចក្ដីសុខ សេចក្ដីចម្រើន និងអាចជួយសង្គ្រោះអ្នកដទៃ ឱ្យរស់នៅដូចខ្លួនដែរ ។

២. **មនុស្សមនុស្សោ:** មនុស្សដែលមានសមត្ថភាពជួយខ្លួនឯងបានពិត ឱ្យរស់នៅជាមួយគុណធម៌ ពោលគឺ រក្សាសីល ៥ និងមានព្រហ្មវិហារធម៌ ចំពោះអ្នកដទៃគ្រប់ៗគ្នា ។

៣. **មនុស្សតិរច្ឆានោ:** មនុស្សដែលរស់នៅក្នុងសភាពអន់ថោកគ្មានសីលធម៌ដឹកមុខ ពោលគឺវង្វេងនឹងតណ្ហា កាមគុណ មានសេចក្ដីក្រោធ ចងគំនុំ ព្យាបាទ គ្មានហេតុ-ផល និងមិនស្គាល់គុណ-ទោស មិនជឿកម្ម-ផល មិនគោរពច្បាប់ ជាខ្ចីជាមនុស្សប្រព្រឹត្តខុសសីល ៥ និងគ្មានព្រហ្មវិហារធម៌ទាំង៤ជាសកល ។

៤. **មនុស្សបេតោ:** មនុស្សដែលរស់នៅក្នុងសភាពអន់ថោកជាងមនុស្សតិរច្ឆានោ ពោលគឺអន់ជាងសត្វតិរច្ឆានទៅទៀត គឺគ្មានប្រយោជន៍សោះឡើយ មានតែនាំគ្រោះថ្នាក់ដល់សង្គម ។

ផ្នែកទី

២

# កិច្ចការ
# របស់កូនល្អពិត

អាហារមាន ៣ ប្រភេទ : ទី១គឺ អាហារជាថ្នាំពុល, ទី២គឺ អាហារជាថ្នាំពុលផងជាឱសថផង, និង ទី៣គឺ អាហារជាឱសថ ។
អាហារល្អបំផុតសម្រាប់កាយគឺ ការបរិភោគដោយចេះប្រមាណ រីឯ អាហារល្អបំផុតសម្រាប់ចិត្តគឺ ព្រះធម៌ ។
មនុស្សបរិភោគអាហារណា នឹងទៅជាមនុស្សបែបនោះ ។

*ស៊ាន វិត*

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ





**ព្រះពុទ្ធ បានសម្តែងថា:** "កូនប្រុសស្រីទាំងឡាយណា ចិញ្ចឹមមាតាបិតាដោយធម៌ សូម្បីទេវតាទាំងឡាយ តែងរក្សានូវនរជនអ្នកចិញ្ចឹមមាតាបិតា ហើយបណ្ឌិតទាំងឡាយក្នុងលោកនេះ តែងសរសើរនូវនរជននោះ នរជននោះ លុះបង់លោកនេះទៅ រមែងរីករាយសប្បាយក្នុងស្ថានសួគ៌" ។

# ផ្នែកទី២: កិច្ចការរបស់កូនល្អពិត

## ក. កូនល្អពិត រក្សាកល្យាណធម៌ ៥

កូនមិនល្អ មានអកុសលធម៌ជាមិត្ត ដូចជា ការមិនស្គាល់គុណគេ ការប្រមាទ ការប្រមាថ អបាយមុខ រួមមាន ឆ្កួតនឹងស្រី ឆ្កួតនឹងស្រា ឆ្កួតនឹងល្បែង ខ្ជិលច្រអូស ប្រើពេលវេលាខុស ជាដើម ។ ផ្ទុយស្រឡះពី កូនល្អ ដែលលំអដោយ **កុសលធម៌ ៥** ជាកល្យាណធម៌ គឺ : *មេត្តា សម្មាអាជីវៈ សន្តោស សច្ចៈ* និង *សតិ* ។

### ១. មេត្តា

កល្យាណធម៌ទី១របស់កូនល្អពិត គឺ មេត្តា ប្រែថា មេត្រី, សេចក្តីរាប់រក, សេចក្តីរាប់អានគ្នា, សេចក្តីប្រណី, បំណងចង់ឱ្យអ្នកដទៃ បានសេចក្តីសុខ សេចក្តីចម្រើន ។ មេត្តា ជាធម៌មេនៃព្រហ្មវិហារធម៌ទាំង៤ ដែលជាគុណធម៌របស់មនុស្ស បើមនុស្សណាខ្វះព្រហ្មវិហារធម៌ មនុស្សនោះ ខ្វះភាពពេញលេញជាមនុស្ស និងខ្វះជម្រកសុខសាន្ត ។

ដើម្បីសិក្សាស្វែងយល់ឱ្យបានយល់ច្បាស់លាស់ អំពីព្រហ្មវិហារធម៌ទាំង ៤ សូម លោកអ្នករកជាវសៀវភៅជាស្នាដៃរបស់ខ្ញុំបាទ មានចំណងជើងថា "**ឪពុកម្តាយល្អពិត របស់កូន**" និងដើម្បីយល់ដឹងអំពីគុណសម្បត្តិដែលត្រូវមាន ដើម្បីត្រៀមខ្លួនធ្វើជាម្តាយឪពុកល្អពិតរបស់កូន ផង និងដើម្បីយល់ដឹងអំពីមធ្យោបាយជួយកូនឱ្យមានអនាគតរុងរឿងត្រចះត្រចង់ផង ។

កូនល្អពិត មានមេត្តាធម៌ចំពោះ (១) ព្រះរតនត្រៃ (២) ញាតិ ៧ សន្តាន (២) ញាតិក្រៅសន្តាន មាន គ្រូតូច-គ្រូធំ ចៅហ្វាយ-កូនចៅ ស្វាមី-ភរិយា មិត្តភក្តិ-អ្នកជិតខាង (៣) សត្វគ្រប់ជំពូក (៤) វត្ថុរួមទាំង (៥) អមនុស្ស ផងដែរ ។ ក្នុងគ្រានេះ ខ្ញុំបាទសូមធ្វើការបកស្រាយតែមួយចំណែកអំពី មេត្តាធម៌របស់កូនល្អ ចំពោះឪពុកម្ដាយ ។

កាលណាមេត្តាធម៌កើតមាននៅក្នុងចិត្តរបស់កូនហើយ រមែងញ៉ាំងឱ្យករុណាធម៌កើតឡើងនៅក្នុងកាយ (ទង្វើ) របស់កូនផងដែរ ចំពោះព្រះទាំងទ្វេ ព្រោះតែកូនមើលឃើញថា ព្រះទាំងទ្វេ ទទួលការលំបាកខ្លាំងណាស់ ទាំងផ្លូវកាយ និងផ្លូវចិត្ត ក្នុងការចិញ្ចឹម ទំនុកបម្រុងកូនឱ្យមានជីវិតក្នុងលោក និងឱ្យកូនមានអនាគតល្អរុងរឿង ។ មេត្តា-ករុណាដែលកូនល្អមានដល់ឪពុកម្ដាយគឺ :

- **ការមានសតិសម្បជញ្ញៈចំពោះគុណរបស់ឪពុកម្ដាយ**

(១)សតិ គឺកូនល្អ គប្បីមានស្មារតីត្រូវ គឺការរឭកឃើញរឿយៗ ការចងចាំជាប់ជានិច្ច ការនឹកគិតរឿយៗ ដល់កិច្ចការរបស់លោកទាំងពីរផង ដល់មហាគុណរបស់លោកទាំងពីរផង រីឯ (២) សម្បជញ្ញៈ គឺកូនល្អ គប្បីដឹងច្បាស់នូវអ្វីដែលត្រូវធ្វើ ជាការតបស្នងសងគុណដល់លោកទាំងពីរវិញ ។ ចូរកូនគ្រប់រូប រក្សាសតិសម្បជញ្ញៈចំពោះឪពុកម្ដាយ ឱ្យជាប់ដើម្បីជៀសវាងការភ្លេចគុណ បើរមិលគុណព្រះ គ្មានថ្ងៃស្គាល់សុខទេ ។

- **ការអធិដ្ឋានមេត្តាធម៌ជូនឪពុកម្ដាយ**

កូនល្អ តែងមានទម្លាប់រស់នៅល្អជាប្រចាំ ក្នុងនោះ គប្បីប្រើពេលវេលាជាទៀងទាត់ ជាពិសេសនៅពេលមុនចូលដេក និងនៅពេលព្រឹកព្រលឹមទើបភ្ញាក់ពីដេក សំរាប់ធ្វើការអធិដ្ឋានមេត្តាធម៌ជូនព្រះទាំងពីរដែលផ្ដល់មេត្តាដល់កូនដោយបរិសុទ្ធ ។ កូនល្អ ត្រូវចេះប្រើពាក្យសម្ដីដែលចេញពី ទឹកចិត្តដឹងគុណលោកដោយស្មោះស និងចេញពី បញ្ញា របស់ខ្លួន ។ ខាងក្រោមនេះ ជាឧទាហរណ៍នៃការអធិដ្ឋានមេត្តាធម៌របស់កូនជូនលោក ។

*ពុកម៉ែ! កូន (ស៊ាន វិត) សូមឧទ្ទិសបួងសួង សូមពុកម៉ែ រួចចាកលំបាកកាយចិត្តក្នុងការចិញ្ចឹមថែទាំកូន !*

*សូមឱ្យការរក្សាសីល ធ្វើទាន រក្សាភាវនា របស់ពុកម៉ែ មានសេចក្ដីចម្រើនជានិច្ចនិរន្តរ៍ !*

*ពុកអើយ! កូនសូមប្រកាសប្ដឹងដល់អស់ ទេវតាថែរក្សាលោកា និងព្រះសម្ពុទ្ធ សូមឱ្យការព្យាយាមរបស់ពុក (ហ៊ូ ស៊ាន) ដែលខិតខំសិក្សាព្រះធម៌ក្នុងព្រះត្រៃបិដក បានជាកំណប់បញ្ញាដល់ពុក ក្នុងបរលោក !*

*ម៉ែអើយ! ម៉ែ (មាស និន) មានទឹកចិត្តមេត្តាប្រពៃពិត មកដល់កូន សូមម៉ែបានដល់ទេវលោក ក្នុងលោកខាងមុខៗ !*

*ពុកម៉ែ! កូន (ស៊ាន វិត) សូមប្ដេជ្ញាធ្វើខ្លួនជាកូនល្អពិត របស់ពុកម៉ែ ! កូនត្រេកអរគ្រប់កាលវេលា ព្រោះបានកើតជាកូនរបស់ពុកម៉ែ !*

## - ការបម្រើឪពុកម្ដាយ

កូនល្អ មិនត្រឹមតែយកចិត្តទុកដាក់ធ្វើកិច្ចការងាររបស់ខ្លួន ដូចជាកិច្ចការរៀនសូត្រ ឬ កិច្ចការការចិញ្ចឹមជីវិត ឱ្យបានចប់និងល្អ ប៉ុណ្ណោះទេ ថែមទាំងមានសមត្ថភាពរំលែកការងាររបស់ឪពុកម្ដាយផង និង សម្រួលការនឿយហត់ជូនលោកទាំងពីរ ឧទាហរណ៍ ចេះបម្រើលោកដោយ ការធ្វើសរសៃបន្ធូរភាពតានតឹងនៃរាងកាយផង ។ សូមលោកអ្នក បើក អានទំព័រខាងមុខត្រង់ចំនុច "អរិយកិច្ចនៃកូនល្អពិត" ដើម្បីយល់ដឹងច្បាស់ អំពីការបម្រើឪពុកម្ដាយ ។



## - ការស្ដាប់បង្គាប់ឪពុកម្ដាយ

ការចេះស្ដាប់បង្គាប់ឪពុកម្ដាយ ជាគុណជាតិនៃកូនល្អ ឈ្មោះថា អតិជាតបុត្ត គឺបុត្រដែលរក្សាសីលបានខ្ពង់ខ្ពស់ជាងឪពុកម្ដាយ ឬ ឈ្មោះថា អនុជាតបុត្ត គឺបុត្រដែលចេះគោរពឪពុកម្ដាយ ស្ដាប់ឱវាទ ការ អប់រំប្រៀនប្រដៅរបស់លោកទាំងទ្វេដោយល្អ ។ បុត្រប្រភេទទាំង ២ នេះ មិនធ្វើឱ្យព្រះរស់ទាំងពីរ មានការហត់នឿយចិត្តក្នុងការប្រៀនប្រដៅ ឬ ត្រូវ លំបាកកាយដោយសារខ្លួនឡើយ ផ្ទុយទៅវិញ ធ្វើឱ្យលោកទាំងពីរមានតែ មោទនភាព រីករាយ សាទរ សុខកាយ សប្បាយចិត្ត ព្រោះតែលោកមាន បុត្រដ៏ល្អបែបនេះ ។ កូនដែលចេះស្ដាប់បង្គាប់ឪពុកម្ដាយ ព្រោះតែចេះយល់ ដល់ចិត្តនិងបំណងរបស់លោកទាំងពីរ យល់ដល់ភារកិច្ចដ៏ធ្ងន់ធ្ងរដែលលោក ទាំងពីរត្រូវរែកពុន និងយល់ដល់កិច្ចការនៃកូនល្អ គឺត្រូវគោរពតាមលោក ។

## - ការសង្គ្រោះឪពុកម្តាយ

កូនដែលអាចសង្គ្រោះឪពុកម្តាយបាន រកបានដោយកម្រក្នុងលោក ហើយជាកូនថ្នាក់ខ្ពស់ បានសំអាតខ្លួនហើយជាស្រេច ឱ្យស្អាតកាយ ស្អាតវាចា និង ស្អាតចិត្ត ពោលគឺកូនល្អពិតមាន សទ្ធា សីល ចាគៈ បញ្ញា រួចដឹកនាំសង្គ្រោះឪពុកម្តាយដែលមិនទាន់មានកុសលធម៌ទាំង ៤ ឱ្យមានដូចខ្លួនដែរ ។ ក្នុងលោកិយនេះ អ្វីជាទីពឹងដ៏ប្រសើរនៃមនុស្សមិនមានឡើយ មានតែ សទ្ធា សីល ការឱ្យទាន (បរិច្ចាគ ឬ ចាគៈ) និង បញ្ញា ទើបជាទីពឹងពិតប្រាកដ សំរាប់បច្ចុប្បន្នផង និងបរលោកផង ។

សូមអាននៅត្រង់ទំព័រអំពី "ធម្មកិច្ច ៥ យ៉ាងនៃកូនល្អពិតចំពោះឪពុកម្តាយ" ដើម្បីយល់ឱ្យបានច្បាស់អំពីចំនុចដ៏វិសេសវិសាលនេះ សំរាប់កូនសងគុណលោកទាំងពីរ ព្រោះកូនអាចសងគុណលោកទាំងពីរអស់ ប្រសិនបើ កូនអាចបំពេញធម្មកិច្ចទាំងនេះបានពិត ។

កូនល្អ រមែងមានមេត្តា-ករុណា ចំពោះលោកទាំងពីរ ដោយចិត្តពិត ញ៉ាំងឱ្យមានទង្វើត្រូវពិត ដើម្បីសម្តែងនូវការតបគុណផង ដើម្បីសម្តែងនូវការអាណិតអាសូរដល់លោកទាំងពីរផង ។ សូមលោកអ្នកបើកអានទំព័រខាងមុខត្រង់ចំនុច "អរិយកិច្ចនៃកូនល្អពិត" ដើម្បីយល់ដឹងជាក់ច្បាស់អំពីទង្វើនៃកូនល្អមានមេត្តា-ករុណាចំពោះឪពុកម្តាយ ។

## ២. សម្មាអាជីវៈ

សម្មាអាជីវៈ ប្រែថា ការចិញ្ចឹមជីវិតត្រូវ សំដៅដល់ការប្រកបរបរ ឬ ធ្វើការងារទាំងឡាយ ដោយមធ្យោបាយសុចរិតទៀងត្រង់។ គប្បីលះបង់នូវមិច្ឆាជីវៈ ការចិញ្ចឹមជីវិតខុសដែល ចាកលំអានរបស់បណ្ឌិតទាំងឡាយ ព្រោះការចិញ្ចឹមជីវិតខុស ជាការបើកទ្វារផ្ទះ ទទួលនូវទ្រព្យក្ដៅក្រហាយ និងភារៈនាំទុក្ខ ដល់ផងខ្លួន ដល់សមាជិកគ្រួសារ និងញាតិផងទាំងពួង ។ ព្រះពុទ្ធជាបរមគ្រូនៃយើង មានពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ លះបង់នូវព្យាយាម ជាគ្រឿងចិញ្ចឹមជីវិតខុស ហើយរស់នៅដោយព្យាយាម ជាគ្រឿងចិញ្ចឹមជីវិតដ៏ប្រសើរ ម្នាលភិក្ខុទាំងឡាយ នេះតថាគតឱ្យឈ្មោះថា "សម្មាអាជីវៈ" ។ ការលះបង់នូវមិច្ឆាជីវៈ គឺលះបង់របរ ឬ ការងារមិនមានទោស ដែលព្រះសម្មាសម្ពុទ្ធបានហាមប្រាម ៥ យ៉ាង គឺ ហាមជួញគ្រឿងសាស្ត្រាវុធ, ហាមជួញដូរមនុស្ស, ហាមជួញសត្វ, ហាមជួញគ្រឿងស្រវឹង, និង ហាមជួញថ្នាំពិសថ្នាំពុល ។ គុណធម៌នៃការប្រតិបត្តិត្រូវរបស់កូនល្អពិតក្នុងការចិញ្ចឹមជីវិតត្រូវ (សម្មាអាជីវៈ) មាន ៣ គឺ :

- **សុំសីល ៥ ឬ សីល ៨**
- **មានលោកិយបញ្ញា**
- **មានឥទ្ធិបាទ ៤**

ខ្ញុំបាទ សូមមិនបកស្រាយនូវខ្លឹមសារនៃគុណធមិទាំង ៣ ខាងលើនេះ សូមលោកអ្នកបើកត្រឡប់ទៅអានទំព័រទី ១៣ ប៉ុន្តែពេលនេះខ្ញុំបាទនឹងបកស្រាយបន្ថែមអំពី "ការចេះរក្សាទ្រព្យតាមផ្លូវសុចរិត" តាមព្រះពុទ្ធឱវាទ ។ **ទ្រព្យសុចរិត ជាទ្រព្យប្រកបដោយធមិ ពោលគឺបានមកដោយធមិ រក្សាទុកដោយធមិ និង កើនដោយធមិ ។**

**ការប្រើប្រាស់ទ្រព្យសុចរិតដែលមាន ដោយស្ថាន ៤ យ៉ាង ៈ**

***(១) ចិញ្ចឹមខ្លួនឯង មាតាបិតា បុត្តស្វាមីភរិយា មិត្ត ទាសកម្មករឱ្យជាសុខ*** គប្បីបែងចែកប្រាក់មួយចំណែកសម្រាប់ពពួកបុគ្គលទាំងឡាយនេះដែលមានឧបការៈនិងមានការទំនុកបម្រុងមកលើខ្លួន ដើម្បីញ៉ាំងពួកគាត់ឱ្យសុខ ឱ្យឆ្អែត រក្សាសុខដោយប្រពៃ ពោលគឺ ត្រូវមាន សង្គហវត្ថុ ៤ យ៉ាងញាតិទាំងនេះគឺ ការឱ្យ១, ពោលពាក្យជាទីគោរពស្រឡាញ់១, ការប្រព្រឹត្តឱ្យប្រយោជន៍១, និង ភាវៈជាបុគ្គលមានខ្លួនស្មោះស្មើ១ ។ នេះជាកិច្ចទី១របស់បុគ្គលដែលចេះរក្សាឬប្រើប្រាស់ទ្រព្យដែលខ្លួនមានដោយប្រសើរ តាមមាគ៌ានៃព្រះធមិ នឹងក្លាយជាបុគ្គលមានសុខព្រោះទ្រព្យ ។

***(២) បំបាត់អន្តរាយដែលកើតអំពីហេតុផ្សេងៗ*** គឺប្រាក់ចំណែកទី ២ សម្រាប់បំបាត់អន្តរាយដែលកើតអំពី រាជភ័យ ចោរភ័យ អគ្គិភ័យ

ឧទកភ័យ ភ័យអំពីបុគ្គលមិនជាទីស្រឡាញ់ក្តី ដោយត្រូវចេះលៃលកប្រើប្រាស់ទ្រព្យដែលមាន ដើម្បីធ្វើកិច្ចទុកការពារទុកជាមុន មិនឱ្យអន្តរាយទាំងនោះកើតឡើង និងដើម្បីដោះស្រាយអន្តរាយដែលកំពុងកើតមាន ។

***(៣) ធ្វើពលី ៥ យ៉ាង*** គឺ១ភាគនៃទ្រព្យដែលមាននោះ លោកឱ្យ

រ្មាះញាតិ ៧

សន្តាន មាន *ញាតិថ្នាក់លើ ៣* គឺ មាតាបិតា នជីតា ១, តាទួតយាយទួត ១, *ញាតិថ្នាក់កណ្តាល ១* គឺ ១ និង *ញាតិថ្នាក់ក្រោម ៣* គឺ កូន ១, ចៅ ១, ចៅទួត ១ ។ **ថិពលី** គប្បីចំណាយទ្រព្យធនខ្លះ រៀបចំតុបតែងកន្លែងទទួលភ្ញៀវ រួមទាំងមាន កែវពែងតែ ទឹកក្តៅទឹកត្រជាក់ កៅអីសមរម្យ ផ្លែឈើ ទឹកផ្លែឈើ ភេសជ្ជៈ ឬ អ្វីដែលចាំបាច់ឯទៀត ដើម្បីទទួលស្វាគមន៍ភ្ញៀវជិតឆ្ងាយ ដែលអញ្ជើញមកលេង ដោយការគួរ ទោះភ្ញៀវនោះ ក្រ ឋានៈទាប យ៉ាងណាក្តី ព្រោះនោះជាសេចក្តីថ្លៃថ្នូររបស់ម្ចាស់ផ្ទះ ត្រូវរក្សានិងលើកតម្កើងជាចាំបាច់ ។ ទី៣ **បុព្វបេតពលី** គឺគប្បីលះទ្រព្យធ្វើបុណ្យទាន ឧទ្ទិសកុសលផលបុណ្យជូនដល់បុព្វការីជនដែលបានចែកឋានទៅហើយ ជាអ្នកមានគុណូបការៈដល់លោកអ្នក ។ ទី៤ **រាជពលី** ឬ **រដ្ឋពលី** គឺគប្បីធ្វើពលីកិច្ចដល់អ្នកគ្រប់គ្រងប្រទេស អ្នកគ្រប់គ្រងដែនដី ប្រធានភូមិ ជាដើម ដែលជាអ្នកមើលថែសន្តិសុខ សុវត្ថិភាព សម្រាប់ប្រជារាស្ត្រ ឱ្យបានរស់នៅប្រចាំថ្ងៃដោយ

គ្មានការបៀតបៀន ឬ គំរាមកំហែង ដូចនេះវាជាការគួរត្រូវតបគុណដល់លោកអ្នកគ្រប់គ្រងទឹកដី ពិសេសត្រូវបង់ពន្ធដារសួយអាករជាដើម ជូនរដ្ឋ ដោយមិនត្រូវគេចវេះឡើយ ។ ទី៥ **ទេវតាពលី** គឺលោកអ្នកគប្បីធ្វើបុណ្យឧទ្ទិសផលដល់ទេវតាដែលឃុំគ្រងលោកអ្នក ឱ្យរស់នៅជាសុខ នៅក្នុងទីកន្លែងដែលរស់នៅ និង នៅទីដែលលោកអ្នកទៅដល់ ។

***(៥) បរិច្ចាគទានដល់សមណព្រាហ្មណ៍*** ជាអ្នកប្រព្រឹត្តល្អពិតប្រាកដក្នុងផ្លូវព្រះពុទ្ធសាសនា ក្នុងគោលបំណងលះបង់ចោលនូវកិលេស នូវផលប្រយោជន៍ផ្ទាល់ខ្លួន ហើយធ្វើខ្លួនជាប្រយោជន៍ដ៏បរិសុទ្ធដល់ពុទ្ធសាសនិកទាំងឡាយ ក៏ដូចជាដល់មហាជនទូទៅ ពិសេសលើកតម្កើងព្រះពុទ្ធសាសនាដែលជាសាសនាសន្តិភាពតែ១គត់នៅលើលោកនេះ ។ ដូចនេះលោកអ្នកគប្បីជួយជ្រោមជ្រែងជាចតុបច្ច័យដល់បុគ្គលល្អបរិសុទ្ធទាំងនោះ មានដូចជា ព្រះសង្ឃ សប្បុរស បណ្ឌិតធម៌ លោកតាលោកយាយដែលនៅសំណាក់ធម៌និងបម្រើវត្តអារាម និងបុគ្គលដែលរក្សាសីលបានខ្ជាប់ខ្ជួនល្អ ។ ការជួយដល់បុគ្គលល្អជាសកលទាំងនេះ ជាការជួយដល់សង្គមនិងសត្វលោកទាំងមូល រមែងញ៉ាំងឱ្យលោកអ្នកកាន់តែចម្រើនឡើងៗ ។

**"មានទ្រព្យអ្វីក៏មិនស្មើមានព្រះធម៌ ល្អអ្វីក៏មិនស្មើល្អក្នុងអំពើបុណ្យ ដើរលើផ្លូវស្អាតអ្វីក៏មិនស្មើដើរតាមផ្លូវអរិយមគ្គអង្គ ៨ ។"** *ស៊ាន វិត*

៤១-ជា កូនល្អ ពិត

## ៣. សន្តោស

ធម៌នេះ មានសារៈសំខាន់និងចាំបាច់ខ្លាំងណាស់ សម្រាប់មនុស្សគ្រប់រូប ដើម្បីបាននូវសេចក្តីសុខ សេចក្តីចម្រើន នៅក្នុងជីវិត ។

មនុស្សទូទៅ តែងមានសេចក្តីមិនរីករាយ តូចចិត្ត ទើសទាល់ចិត្ត ចំពោះអ្វីដែលខ្លួនមានដូចជា រូបសម្បត្តិ ជីវភាពគ្រួសារ សម្ភារៈប្រើប្រាស់ផ្ទាល់ខ្លួន ចំណេះដឹង អត្តចរិត ប្រាក់បៀវត្ស ឋានៈ តួនាទី និង លទ្ធផលនានា ។ល។ នេះក៏ព្រោះតែ អ្វីទាំងនោះមិនល្អសមដូចចិត្ត របស់ខ្លួន ម្ល៉ោះហើយ ក៏កើតមានការមិនសុខចិត្ត មិនសុខកាយ បែបយាងនោះទៅ ។ ការមិនសុខចិត្តនេះបង្កឱ្យមនុស្សនោះ តែងមានជម្លោះ និងធ្វើសង្គ្រាម បំផ្លាញតែខ្លួនឯង និងធ្វើឱ្យប៉ះពាល់ដល់អ្នកដទៃប៉ុណ្ណោះ ព្រោះមនុស្សនោះតែងបង្ហាញឱ្យគេឃើញ ភាពខុសឆ្គង កំហុស សេចក្តីប្រហែស ការប្រមាថ មាននៅនឹង កាយ សម្តី និង គំនិត របស់ផងខ្លួន ។

ឧទាហរណ៍ នៃលក្ខណៈមិនមានធម៌សន្តោស :

- មិនយកចិត្តទុកដាក់ថែទាំសម្ភារៈនិងឧបករណ៍ប្រើប្រាស់នានា ព្រោះមិនល្អ មិនទំនើប មិនមានតម្លៃថ្លៃ តាមចិត្តចង់បានចង់ប្រើ
- ខ្ជិលរៀនសូត្រ ឬ ខ្ជិលធ្វើការងារ ព្រោះកើតមកជាកូនអ្នកក្រ។
- មិនបោស ជូត សំអាត ផ្ទះសំបែង... ព្រោះផ្ទះតូចចង្អៀត ។

- មិនតុបតែងខ្លួន មិនងូតទឹកសំអាតប្រាណ មិនស្លៀកពាក់ឱ្យបានល្អ សមរម្យ ព្រោះរូបសម្បត្តិមិនស្អាតសង្ហារដូចគេ ។
- មិនគិតគូរថែទាំសុខភាព ដូចជា ដោយការហាត់ប្រាណ ការទទួលទានអាហារឱ្យបានត្រឹមត្រូវ... ព្រោះពិបាកចិត្តពេក គ្មានអារម្មណ៍គិតទេ ឬ ព្រោះរវល់ពេក គ្មានពេលគិតទេ ។
- មិនហ៊ានទំនាក់ទំនង ឬ រាប់អានជាមួយអ្នកខ្ពង់ខ្ពស់ អ្នកថ្លៃថ្នូរ អ្នកចេះដឹង ព្រោះខ្លួនឯងជាមនុស្សតូចទាប អន់ ល្ងង់ ។
- មិនធ្វើខ្លួនមានអត្តចរិតល្អ ព្រោះម៉ែឪជាអ្នកប្រព្រឹត្តល្បែង ប្រកបរបរសម្លាប់សត្វ លក់គ្រឿងស្រវឹង ពិសាស្រា...។
- មិនខិតខំរៀនសូត្រ ព្រោះល្ងង់ជាងគេ ព្រោះកើតមកក្នុងពូជអ្នកល្ងង់ ព្រោះខ្វះនេះខ្វះនោះ ព្រោះឆ្ងាយពេក យប់ពេក...។

**សន្តោស** ប្រែថា សេចក្ដីពេញចិត្ត សេចក្ដីត្រេកអរ សេចក្ដីសុខចិត្ត ការព្រមទទួលយកអ្វីដែលមាន ។ ទោះតិចក្ដី ច្រើនក្ដី អាក្រក់ក្ដី ល្អក្ដី ល្អខ្លះក្ដី មិនល្អខ្លះក្ដី រូបកាយខ្មៅឬមិនជាទីពេញចិត្តយ៉ាងណាក្ដី វង្សត្រកូលមិនខ្ពង់ខ្ពស់ គ្រួសារមានជីវភាពក្រីក្រក្ដី ចូរសន្តោសចំពោះវត្ថុទាំងនោះ លក្ខណៈទាំងនោះ សភាពទាំងនោះ ចូរទទួលយកដោយត្រេកអរផងចុះ ព្រោះតែ លោកអ្នកបានមកយ៉ាងនេះ ជាផលនៃកម្មរបស់ខ្លួនដែលបានសាងបានកប់កំណប់បែបនេះ ទុកកន្លងមកនេះហើយ ។

ខ១- ជា កូនល្អ ពិត

ការមានអ្វីទាំងឡាយនោះដែលលោកអ្នកមិនពេញចិត្តក្តី មានប្រយោជន៍ច្រើនណាស់ ជាងការមិនមាន ចូរលោកអ្នកគិតពិចារណាបន្តិចទៅមើល ! ការដែលលោកអ្នកឈឺក្បាលនឹងអ្វីទាំងឡាយនោះ ក៏ព្រោះតែហេតុផល ២ យ៉ាង (១) លោកអ្នកមិនព្រមទទួលយកការពិត បើមិនកាន់យកសេចក្តីពិត ឬ សច្ចៈ ទេនោះ លោកអ្នកមិនសុខឡើយក្នុងចិត្ត ហៅថា មិនសុខចិត្ត ឬ ចិត្តមិនសុខ និង (២) លោកអ្នកមិនចេះកែច្នៃអ្វីទាំងឡាយនោះឱ្យមានប្រយោជន៍ ។ ត្បូងពេជ្រ មានតម្លៃ ល្គិកណាយើងយកវាទៅកែច្នៃ ។ ឧទាហរណ៍ នៅក្នុងបរិវេណ មុខផ្ទះរបស់លោកអ្នកមានដើមត្នោតងាប់ ១ ដើម ដែលលោកអ្នកតែង ចេញចូលទើសមុខទើសមាត់ ឈឺក្បាលដោយសារវាសឹងរាល់ថ្ងៃផង ខ្ញុំបាទសូមសួរលោកអ្នកថាតើវាជាដើមត្នោតរបស់នរណា? តើនរណាយកដើមត្នោតងាប់នោះមកដាក់ក្នុងដីរបស់លោកអ្នក គឺគួរតែទទួលស្គាល់ថា លោកអ្នកជាម្ចាស់វា ហេតុម្តេចមិនមានទំនួលខុសត្រូវ ? ហេតុម្តេចមិនរកវិធីកែច្នៃវាជាប្រយោជន៍ ? ដូច្នេះបានជាព្រះពុទ្ធសាសនាហៅអ្វីទាំងនោះថា **ទ្រព្យតាមមានតាមបាន** មានន័យថា មនុស្សដែលក្លាយជាអ្នកមាន អ្នកខ្ពង់ខ្ពស់ សប្បុរស បណ្ឌិត សុទ្ធតែតាមរយៈអ្វីទាំងឡាយនោះឯងបាទ !

---

"ក្រក៏ទុក្ខច្រើន មានក៏ទុក្ខច្រើន ល្ងង់ក៏ទុក្ខច្រើន មានសញ្ញាបត្រខ្ពស់ក៏ទុក្ខច្រើន ចេះគ្រប់ទើបទុក្ខតិច ។" *ស៊ាន វិត*

---

ធម៌ "សន្ដោស" នេះ ជាធម៌សំរាប់តែមនុស្សមានបញ្ញា និង កូនល្អមានបញ្ញាប៉ុណ្ណោះ ព្រោះកូនមានបញ្ញាយល់អំពីហេតុផលទាំង ២ យ៉ាងនោះ ហើយក៏ធ្វើខ្លួនឱ្យ (១) ចេះទទួលយកការពិត ឬ រស់នៅក្នុងសច្ចៈ, (២) ចេះធ្វើខ្លួនឱ្យរីករាយ គឺសុខចិត្ត ឬ ចិត្តសុខ, (៣) ចេះកែច្នៃ ចេះប្រើប្រាស់ ទ្រព្យតាមមានតាមបានទាំងនោះ ឱ្យទៅជាប្រយោជន៍, និង (៤) ចេះធ្វើឱ្យខ្លួនទទួលបានលទ្ធផលគាប់ប្រសើរ ពោលគឺ មានបាន ខ្ពង់ខ្ពស់ ថ្លៃថ្នូរ ល្បាញល្បី ដោយការមានធម៌សន្ដោស ។

កូនល្អពិត ត្រូវសន្ដោសទ្រព្យតាមមានតាមបាន ៧ ប្រភេទ :

- មនុស្សតាមមានតាមបាន
- ទីកន្លែងតាមមានតាមបាន
- របស់តាមមានតាមបាន
- ឱកាសតាមមានតាមបាន
- វិជ្ជាការតាមមានតាមបាន
- ធម៌តាមមានតាមបាន
- ឥទ្ធិបាទ៤តាមមានតាមបាន

"ចេះគ្រប់ មានន័យ ៣ (១)ប្រែថា ប្រសប់ក្នុងវិជ្ជាការតូចធំ (២) មានលោកិយបញ្ញា និងលោកុត្តរបញ្ញា និង (៣) សុខចិត្តទទួលយកទ្រព្យតាមមានតាមបាន។" *ស៊ាន វុិត*



ខំប្រឹង ជា កូនល្អ ពិត

## ៤. សច្ចៈ

សច្ចៈ ប្រែថា សេចក្ដីពិត, សេចក្ដីទៀងត្រង់, សេចក្ដីសុចរិត ហើយខ្ញុំបាទ កំណត់ សច្ចៈ ជា ២ ប្រភេទ គឺ សច្ចកិរិយា និង សច្ចញាណ ។ សច្ចកិរិយា មានន័យថា ការប្រព្រឹត្តទៀងត្រង់និងសុចរិត សំដៅដល់ កាយសច្ចៈ វចីសច្ចៈ និង មនោសច្ចៈ រីឯ សច្ចញាណ គឺ ការដឹងសេចក្ដីពិត សំដៅដល់ សម្មាទិដ្ឋិ ប្រែថា ការយល់ឃើញត្រូវ ។

កូនល្អពិត គប្បីកាន់សច្ចៈទាំងពីរនេះដោយល្អ ជាការរក្សាភាព ត្រឹមត្រូវរបស់ខ្លួន ក៏ដូចជាការលើកតម្កើងខ្លួនដោយល្អ ដោយបញ្ញា ។



**សច្ចកិរិយា មាន ៣ ប្រការគឺ :**

**(ក). កាយសច្ចៈ ឬ កាយសុចរិត**

- កិរិយាមិនសម្លាប់ជីវិតសត្វលោក
- កិរិយាមិនលួចទ្រព្យអ្នកដទៃ
- កិរិយាមិនប្រព្រឹត្តខុសក្នុងកាម

**(ខ). វចីសច្ចៈ ឬ វចីសុចរិត**

- កិរិយាមិននិយាយអាក្រក់ពីគេ
- កិរិយាមិននិយាយញុះញង់
- កិរិយាមិននិយាយត្រគោះបោះបោក
- កិរិយាមិននិយាយរោយរាយឥតប្រយោជន៍

(គ). មនោសច្ចៈ ឬ មនោសុចរិត

- កិរិយាមិនគិតសម្លឹងចង់បានរបស់គេ
- កិរិយាមិនគិតចងគំនុំ មិនក្រេវក្រោធ
- កិរិយាមិនគិតខុស មិនវង្វេង ។

សម្មាទិដ្ឋិ (ការយល់ឃើញត្រូវ) គឺ :

(ក). សេចក្តីដឹងច្បាស់ក្នុង "អរិយសច្ចៈ ៤"

- ទុក្ខសច្ចៈ
- សមុទយសច្ចៈ
- និរោធសច្ចៈ
- មគ្គសច្ចៈ

(ខ). សេចក្តីដឹងច្បាស់ក្នុង "កម្មបថ ១០"

- កាយកម្ម ៣
- វចីកម្ម ៤
- មនោកម្ម ៣

(គ). សេចក្តីដឹងច្បាស់ក្នុង "ព្រះត្រៃលក្ខណ៍ធម៌ ៣"

- អនិច្ចំ - ទុក្ខំ - អនត្តា

## ៥. សតិ

កុសលធម៌ទី៥ នៃកូនល្អ គឺ "សតិ" ប្រែថា ការរលឹកឃើ រឿយៗ ការចងចាំ ការមិនភ្លេច ។ កូនល្អត្រូវមានសតិ ចំពោះគុណនៃឪពុ ម្តាយ មកលើខ្លួន ដែលធ្ងន់ជាងប្រឹថពីទៅទៀត ឱ្យបានដក់ជិតជាប់នៅក្នុ អារម្មណ៍ ចិត្ត និង វាចា របស់ខ្លួន គ្រប់ពេលវេលា ។ ការភ្លេចឬបាត់ស ចំពោះឧបការគុណរបស់លោក នាំឱ្យកូននោះមានធម៌ប្រមាទដល់គុណរបស លោកទាំងពីរ ដែលនឹងនាំមកនូវសេចក្តីវិនាស ខូចកេរ្តិ៍ឈ្មោះ និងការខា បង់ប្រយោជន៍ជាប្រាកដ ក្នុងឈ្មោះថា កូនល្មើសគុណឪពុកម្តាយ ។

កូនល្អពិត គប្បីរក្សាសតិត្រូវ ៦ យ៉ាង ៖

- សតិក្នុងវ័យ
- សតិក្នុងការតបគុណ
- សតិក្នុងទំនួលខុសត្រូវ
- សតិក្នុងកិច្ចការ
- សតិក្នុងហេតុនៃសេចក្តីវិនាស
- សតិក្នុងទិសដៅ

សតិ គឺសេចក្តីមិនប្រហែសធ្វេស ដូចនេះ ចូរកូនល្អ ចៀសអំពី សេចក្តីប្រហែសធ្វេសទាំងឡាយ។ ចៀសពីសេចក្តីប្រហែសធ្វេសក្នុងវ័យទាំង

៣ គឺ បឋមវ័យ (ជាវ័យត្រូវខិតខំរៀនសូត្រ លត់ដំខ្លួន កែប្រែខ្លួន ឱ្យក្លាយទៅបុគ្គលមានសម្បត្តិមនុស្សពាគី បញ្ញា អត្តចរិតល្អ និងសមត្ថភាពការងារ). មជ្ឈិមវ័យ (វ័យត្រូវខិតខំធ្វើការងារនិងគ្រប់គ្រងគ្រួសារឱ្យមានវិបុលសុខនិងសុភមង្គល) និង បច្ឆិមវ័យ (វ័យត្រូវខិតខំបំពេញកិច្ចជាទីពឹងរបស់ខ្លួនសម្រាប់បរលោក ដូចជា ខិតខំរក្សាសីល ធ្វើទាន និងចម្រើនភាវនា ក្នុងព្រះពុទ្ធសាសនា ពោលគឺ កិច្ចជាពុទ្ធសាសនិកល្អពិត) ។ ចៀសវាងពីសេចក្ដីប្រហែសក្នុងការតបគុណ ដែលខ្ញុំបាទសូមលើកយកទៅ បកស្រាយនៅក្នុងកថាខ័ណ្ឌខាងក្រោម ។ ចូរចៀសវាងពីសេចក្ដីប្រហែសក្នុងទំនួលខុសត្រូវ (ទំនួលខុសត្រូវ មានន័យ ៣ រួមគ្នា គឺការខិតខំធ្វើជាម្ចាស់នៃជីវិតរបស់ផងខ្លួន និងការខិតខំបំពេញតួនាទីរបស់ផងខ្លួន និងការមានសុឆន្ទៈព្រមទទួលយកលទ្ធផលរួមទាំងលទ្ធផលមិនល្អផង)។ ចូរចៀស វាងពីសេចក្ដីប្រហែសធ្វេសក្នុងកិច្ចការ (ត្រូវខំយកចិត្តទុកដាក់ធ្វើដោយឆន្ទៈ ដោយភាពឆ្លាតឈ្លាស និងដោយសេចក្ដីទៀងត្រង់ ទាំងកិច្ចការតូចធំ និងទាំងកិរិយាសម្ដែងចេញដោយឥរិយាបថទាំង៤) ។ ចូរចៀសវាងពីសេចក្ដីប្រហែសក្នុងហេតុនៃសេចក្ដីវិនាស (ត្រូវរឮករឿយៗរឿយៗដល់ហេតុដែលនាំឱ្យវិនាស ត្រូវចេះការពារប្រសើរជាងព្យាបាល ដោយការចេះប្រយ័ត្នប្រយែង រារាំងមិនឱ្យវិនាសព្រោះហេតុទាំងនោះ ត្បិតប្រហែសបាត់ ប្រយ័ត្នគង់) ។ ចូរចៀសវាងកុំឱ្យភ្លេចថា ត្រូវរស់នៅដោយទិសដៅក្នុងគ្រប់ការងារនិងគ្រប់ពេលវេលា ហើយត្រូវខំធ្វើឱ្យបានជោគជ័យ ។

ខ្ញុំ- ជា កូនល្អ ពិត

កូនល្អពិត ជាមនុស្សល្អ ពោលគឺ មានសេចក្តីល្អនៅគ្រប់កាលៈទេសៈ ល្អជាសកល ល្អជាទូទៅ ល្អមិនដោយលំអៀង ដែលតែងរក្សាសតិត្រូវក្នុងការតបគុណ ប្រៀបដូចជា ដើមឈើតែងហុចផលនូវម្លប់ផ្លែផ្កាជានិច្ចនិរន្តរ៍ ដល់អ្នកដែលថែរក្សាដាំដុះវា និងដល់អ្នកមកសុំជ្រក។ ព្រះពុទ្ធមានពុទ្ធដីកាថា មានបុគ្គល ២ ពួក រកបានដោយកម្រ "**បុគ្គលដែលធ្វើឧបការៈទុកមុន ១ បុគ្គលដែលដឹងឧបការៈដែលអ្នកដទៃបានធ្វើហើយ ធ្វើតបវិញ ១**" ។

កូនល្អពិត រមែងជាមនុស្សកតញ្ញូ មានបដិការៈចំពោះគុណ ៦ យ៉ាង :

- តបគុណ**ដល់បុគ្គលមានគុណ**
- តបគុណ**ដល់សត្វមានគុណ**
- តបគុណ**ដល់រុក្ខជាតិ**
- តបគុណ**ដល់វត្ថុមានគុណ**
- តបគុណ**ដល់បុណ្យ**
- តបគុណ**ដល់រាងកាយ**

ក្នុងកថាខ័ណ្ឌនេះ ខ្ញុំបាទ នឹងធ្វើការបកស្រាយតែចំពោះការតបគុណដល់បុគ្គលមានគុណ តែប៉ុណ្ណោះ ដោយកូនល្អពិត តែងជាមនុស្សម្នាក់ប្រកបដោយគុណធមិយ៉ាងប៉ិនប្រសប់ទៀងត្រង់ ក្នុងន័យនេះគឺ តបគុណដល់បុគ្គល ១០ ពួក :

- តបគុណដល់ព្រះរតនត្រៃ
- តបគុណដល់ឪពុកម្តាយ
- តបគុណដល់ជីដូនជីតា
- តបគុណដល់បងប្អូនប្រុសស្រីបង្កើត
- តបគុណដល់គ្រូបង្រៀន
- តបគុណដល់ចៅហ្វាយនាយ
- តបគុណដល់កល្យាណមិត្ត
- តបគុណដល់ញាតិជិតខាង
- តបគុណដល់អ្នកក្រោមបង្គាប់
- តបគុណដល់អ្នកមានឧបការគុណ ។

ហើយក្នុងកថាខ័ណ្ឌនេះផងដែរ ខ្ញុំបាទ ក៏នឹងធ្វើការអត្ថាធិប្បាយតែអំពីការតបគុណចំពោះបុគ្គល ១ ពួកតែប៉ុណ្ណោះ នោះគឺ ការតបគុណដល់ឪពុកម្តាយ ។ កូនល្អពិត មានការតបគុណ ឬ ការសងគុណ ចំពោះព្រះទាំងទ្វេ ដោយធម៌ ២ មេ គឺ កតញ្ញូតាធម៌ និង កតវេទិតាធម៌ ។ ការតបគុណ (១) ជាឫសគល់នៃកុសលធម៌, (២) ជាប្រធាននៃគុណធម៌, (៣) នាំឱ្យចម្រើនអំពើល្អ, និង (៤) នាំឱ្យឆ្ពោះដល់ការសម្រេចនូវសម្បត្តិ ៣ គឺ សម្បត្តិមនុស្ស សម្បត្តិទេវតា សម្បត្តិព្រះនិព្វាន ។

សតិក្នុងការតបគុណ ការរក្សាសតិត្រូវ ចំពោះគុណឪពុកម្ដាយ មាន មេធមិ ២ យ៉ាង :

- **កតញ្ញូតាធមិ**

កតញ្ញូតាធមិ គឺសេចក្ដីដឹងឧបការគុណដែលឪពុកម្ដាយ បាននិងកំពុងធ្វើដល់ខ្លួន។ កូនកតញ្ញូ ត្រូវដឹងច្បាស់លាស់ ទាំងរាក់ជ្រៅ អំពីគុណូបការៈលោកទាំងពីរ ដោយការសិក្សាឈ្វេងយល់អំពីមហាគុណនេះ តាមរយៈការសិក្សាព្រះធមិ សួរបណ្ឌិតធមិ អង្កេតពិចារណាដល់ភាពជាក់ស្ដែង ដើម្បីទទួលបានបញ្ញាយល់ច្បាស់អំពីមហាគុណឪពុកម្ដាយ ជៀសវាងមានតែចិត្តដឹងគុណ ប៉ុន្តែខ្វះបញ្ញា ។ បើខ្វះបញ្ញាហើយ នឹងធ្វើខុសជាប្រាកដ មិនខុសអ្វីពីកូនអកតញ្ញូឡើយ ។ កូនដែលមានកញ្ញូតាធមិ ជាកូនចេះគោរពឪពុកម្ដាយយ៉ាងពិតប្រាកដ ហើយកូនកតញ្ញូ ត្រូវមាន :

➢ **បញ្ញាចំពោះគុណឪពុកម្ដាយ** គឺឈ្វេងយល់ដឹងច្បាស់អំពីហេតុទាំងឡាយដែលថា ឪពុកម្ដាយពិតជាមានគុណដ៏មហិមាទាំង៣ ចំពោះកូនគឺ អជ្ឈិគុណ, វិសេសគុណ, និង គុណូបការគុណ តាមរយៈការសិក្សារៀនសូត្រតាមពុទ្ធធមិ និង ឱវាទរបស់បណ្ឌិតនានា ។

➢ **សទ្ធាចំពោះគុណឪពុកម្ដាយ** គឺជឿជាក់យ៉ាងមុតមាំថា ម៉ែឪ ពិតជា ព្រះរស់មានគុណជាងនរណាៗទាំងអស់នៅក្នុងលោក ហើយថា

កិច្ចការចម្បងក្នុងជីវិតរបស់កូន គឺប្រណិប័តន៍ និងប្រព្រឹត្តទង្វើទាំងឡាយ ជាកូនមានកញ្ញូតាធមិពិត១ ដើម្បីជីវិតសុខសាន្តត្រាណ ជាដរាប ។

➤ **សតិចំពោះគុណឪពុកម្តាយ** គឺត្រូវចងចាំ ហើយរលឹកនឹកគិតរឿយ១ ដល់មហាគុណនិងគុណធមិរបស់លោកទាំងពីរមានចំពោះកូន ។ បើពេលណា ខ្លួនប្រហែសដោយធ្វើទង្វើប្រមាទដល់គុណ និងសេចក្តីថ្លៃថ្នូររបស់លោកទាំងពីរ ត្រូវចេះដាស់សតិខ្លួនឯង ហើយធ្វើការកែប្រែភ្លាម ។

ផ្ទុយទៅវិញ កូនអកតញ្ញូ មិនដឹង មិនចងចាំ ឧបការគុណឪពុកម្តាយទេ ហើយក៏មិន ព្រមខិតខំសិក្សាស្វែងយល់ដឹងអំពីមហាគុណនៃលោកតើធ្ងន់ជាងប្រឹថពីយ៉ាងដូចម្តេចដែរ គឺបានតែមាត់ថា ម៉ែឪមានគុណ គុណមានទម្ងន់ ធ្ងន់ជាងប្រឹថពី តែប៉ុណ្ណោះ គ្មានបញ្ញាយល់ច្បាស់អំពីគុណនោះធ្ងន់យ៉ាងដូចម្តេចឱ្យប្រាកដទេ ។ កូនដែលមានអកតញ្ញូតាធមិ ជាកូនមិនគោរព មិនស្តាប់ដំបូន្មានឪពុកម្តាយឡើយ គឺមានតែការប្រមាទដល់លោកទាំងពីរ តែប៉ុណ្ណោះ ។ បើកូនមិនស្គាល់គុណឪពុកម្តាយធ្ងន់យ៉ាងដូចម្តេចហើយនោះ តើកូននោះនឹងមានទឹកចិត្តពិតមកពីណាតបគុណដល់លោកទាំងពីរវិញ ? តើកូននោះធ្វើបាបលោកទាំងពីរប៉ុណ្ណាទៅវិញ ?

បើកូនធ្វើបាបព្រះរបស់ខ្លួនទៅហើយនោះ តើកូននោះមានសេចក្តីគោរព ស្រឡាញ់ ការតបគុណដល់មនុស្សដទៃទៀតយ៉ាងម៉េច

ទៅកើត ? តើសេចក្ដីស្រឡាញ់មានមកពីណា ដល់ភរិយា-ស្វាមី និង កូនៗរបស់ខ្លួន ? ធ្វើម្ដេចកូននោះ នឹងអាចស្វែងរកសេចក្ដីសុខ សុភមង្គល សេចក្ដីចម្រើន រកសួគ៌ភពឃើញ បើធ្វើបាបចិត្តនិងកាយព្រះរាល់ថ្ងៃ !

- **កតវេទិតាធម៌**

កតវេទិតាធម៌ ប្រែថា ការដែលគិតតែពីតបស្នងសងគុណដល់ឪពុកម្ដាយមានឧបការគុណធ្ងន់ដល់ខ្លួន។ កូនមានកតវេទិតាធម៌ ជាកូនសម្បូរដោយគុណធម៌ក្នុងជីវិតនៅគ្រប់ដង្ហើមចេញចូលរបស់ខ្លួន ដោយកាយ វាចា ចិត្ត ។ ការតបស្នងសងគុណឪពុកម្ដាយ ជាធម៌ដឹកមុខកូនកតញ្ញូ ញុំាងឱ្យកូននោះ មានតែកុសលធម៌ សីលធម៌ សេចក្ដីទៀងត្រង់ សេចក្ដីសុចរិត ទំនួលខុសត្រូវពេញលេញ ការខិតខំព្យាយាមលើកតម្លៃនៃគុណឪពុកម្ដាយ ។ កូនដែលប្រកបដោយកតវេទិតាធម៌ ត្រូវមាន :

➢ **កតញ្ញូតាធម៌** គឺត្រូវមានគុណធម៌ទាំង ៣ ចំនុចខាងលើ ។

➢ **ការមានចិត្តតបគុណឪពុកម្ដាយ** គឺកូនល្អ ត្រូវមានការតាំងចិត្ត ប្ដេជ្ញាចិត្ត តម្កល់ចិត្ត តបស្នងសងគុណដល់ព្រះទាំងពីរ ដោយបញ្ញា ដោយគុណធម៌ ដោយសមត្ថភាព ។ ម្ដាយរបស់ខ្ញុំបាទ ឧស្សាហ៍ទូន្មានខ្ញុំបាទ ស៊ាន វ៉ិត ថា "ចិត្តល្អ ក្រខ្លួន" ដោយម្ដាយខ្ញុំបាទ អប់រំថា កូនជាកូនល្អហើយ ដែលមានសន្ដានចិត្តល្អ ហើយចេះធ្វើតបគុណដល់អ្នកទាំងឡាយ សូម្បី

អ្នកនោះ បានធ្វើគុណបន្តិចបន្តួចមកលើកូនក៏ដោយ (ឧទាហរណ៍ អ្នកនោះ បានឱ្យទឹកកូនញ៉ាំ ១ កែវ) ក៏កូនត្រូវចិត្តល្អ ធ្វើល្អ តបគុណគេវិញ ដោយបញ្ញា ដោយគុណធម៌ និងដោយសមត្ថភាព ទើបចិត្តល្អរបស់កូន នាំឱ្យកូនបានសុខ បានសប្បាយ បានការសរសើរ បានក្លាយជាអ្នកមាន ណាកូន! ដូចនេះម្ដាយរបស់ខ្ញុំបាទ ចង់ទូន្មានខ្ញុំបាទថា "ចិត្តល្អ ក្រខ្លួន ព្រោះចិត្តល្អមិនដោយបញ្ញា មិនដោយគុណធម៌ មិនដោយសមត្ថភាព" និងថា "ចិត្តល្អនាំឱ្យមានបានឡើងៗ ព្រោះចិត្តល្អដោយបញ្ញា ដោយគុណធម៌ និងដោយសមត្ថភាព" ។

➤ **ការបំពេញតួនាទីជាកូនល្អ** គឺខំព្យាយាមធ្វើឱ្យសម្រេចនូវគោលបំណងពិតទាំង ៣ របស់ឪពុកម្ដាយ ។ សូមលោកអ្នក អានខ្លឹមសារលំអិតនេះនៅក្នុង "ផ្នែកទី៣: សមត្ថភាព ៣ យ៉ាងនៃកូនល្អពិតដើម្បីសម្រេចគោលបំណងពិតរបស់ឪពុកម្ដាយ" នៃសៀវភៅនេះ ឱ្យបានយល់ជាក់ច្បាស់ ជៀសវាងខំបំពេញតួនាទីខុសព្រោះល្ងង់ ។

---

ព្រះពុទ្ធ បានសម្ដែងថា "បុគ្គល ២ ពួក រកបានដោយកម្រគឺ
បុគ្គលដែលធ្វើឧបការៈទុកមុន ១ ហៅថា បុព្វការី និង បុគ្គលដែល
ដឹងឧបការៈដែលអ្នកដទៃបានធ្វើហើយ ធ្វើតបវិញ ១ ហៅថា កតញ្ញូកតវេទី" ។

---

## អានិសង្សនៃកតញ្ញូតា មាន ៤ យ៉ាង :

១. កតញ្ញូតា ជាឫសគល់នៃកុសលធម៌ទាំងពួង

២. កតញ្ញូតា ជាប្រធាននៃបារមីទាំង ១០ និង ៣០

៣. កតញ្ញូតា ជាទីចម្រើននៃបុណ្យកុសល

៤. កតញ្ញូតា ជាធម៌ញ៉ាំងឱ្យសម្រេចនូវសម្បត្តិទាំង៣។

**អត្ថន័យនៃទង់ជាតិខ្មែរ**

- **ពណ៌ខៀវ** តំណាង សាមគ្គីភាព ភាតរភាព មេត្តា-ករុណា សន្តិភាព អហិង្សា ក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះមហាក្សត្រ ។
- **ពណ៌ក្រហម** តំណាង ស្មារតីអង់អាចក្លាហានមោះមុត ពុះពារជំនះគ្រប់ឧបសគ្គដើម្បីការពារទឹកដី ឱ្យឋិតថេរគង់វង្សជានិរន្តរ៍ ។
- **រូបប្រាសាទអង្គរពណ៌ស** តំណាងអរិយធម៌ដ៏រុងរឿងរបស់ខ្មែរនាសម័យមហានគរ និងតំណាងខ្មែរកាន់សាសនាព្រះពុទ្ធ សិរីសុទ្ធ ។



"គ្មានអ្វីថ្លៃវិសេស ស្មើនឹង គុណ គឺគុណនៃឪពុកម្តាយ ហៅថា **គុណមាតាបិតា** និង គុណនៃធម៌ ហៅថា **គុណធម៌** ។ មនុស្សមានគុណធម៌ ជាមនុស្សសង្គ្រោះខ្លួនឯងពិត និងជួយសង្គ្រោះអ្នកដទៃ នាមថា **មនុស្សល្អពិត**" ។

*ស៊ាន វិត*

## ខ. កូនល្អពិត រក្សាសីល៥ ឬ សីល៨

សីល គឺជាវិន័យ ជាការសង្រួម នៃកាយវាចាចិត្តមិនឱ្យកាន់យកកិរិយាខុសទាំងឡាយ ហើយប្រតិបត្តិកិរិយាជាកុសលទាំងឡាយវិញ ។ ទ្រព្យ ឬ សម្បត្តិដ៏ឧត្តុង្គឧត្តមពិតរបស់មនុស្សគឺ សីល ចំណែកឯ លុយកាក់ ឬ អ្វីៗផ្សេងទៀត គ្រាន់តែជាទ្រព្យក្រៅខ្លួនតែប៉ុណ្ណោះ ។ អ្នកដែលមានលុយមិនរក្សាសីល ទោះជាលុយច្រើនអនេកយ៉ាងណា ក៏មិនស្គាល់សុខដែរ ព្រោះលុយទាំងនោះច្រើនបានមកដោយអំពើទុច្ចរិត ប៉ុន្តែអ្នករក្សាសីលបានល្អពិតរមែងមានសម្បត្តិមនុស្សសព្វគ្រប់ទាំងអស់ ដូចជា លុយកាក់ ផ្ទះ ដីធ្លីរបស់របរប្រើប្រាស់ សេចក្តីសុខ សេចក្តីថ្លៃថ្នូរ ភាពរីករាយ ការគោរពកោតសរសើរពិតពីមនុស្សជិតឆ្ងាយទាំងពួង ព្រោះសីល គឺជាឃ្លាំងមានទុកទ្រព្យសម្បត្តិគ្រប់បែបយ៉ាងដែលជាសេចក្តីត្រូវការរបស់មនុស្ស។ កូនដែលរក្សាសីល ជាកូនដែលរក្សាសេចក្តីគោរពចំពោះខ្លួនឯង ចំពោះឪពុកម្តាយនិងចំពោះមនុស្សដទៃ រីឯ កូនដែលមិនរក្សាសីល ជាកូនដែលរក្សាសេចក្តីប្រមាថ និងសេចក្តីប្រមាទចំពោះខ្លួនឯង ចំពោះឪពុកម្តាយ និងចំពោះអ្នកដទៃ ។ សេចក្តីគោរព នាំឱ្យមានសេចក្តីសុខ សេចក្តីចម្រើន សន្តិភាព តែសេចក្តីប្រមាថនិងសេចក្តីប្រមាទ នាំឱ្យមានសេចក្តីវិនាសដល់គេឯង។ ចូររកជាវអានសៀវភៅ "ពុទ្ធសាសនិកល្អពិត" ដើម្បីយល់ដឹងឱ្យបានច្បាស់អំពីសីល ៥ និង ៨ ។

សីល ៥ គឺជានិច្ចសីល ប្រែថា សេចក្ដីល្អដែលគប្បីបដិបត្តិជានិច្ចកាល រៀងរាល់ថ្ងៃ ជារៀងរហូតតទៅ ដើម្បីរក្សាភាពជាមនុស្សពិត ។ ក្នុងសីល ៥ បើមនុស្សណា ខ្វះសិក្ខាបទ១ ទុកដូចជាខ្វះភាពជាមនុស្ស ២០ ភាគរយ បើខ្វះសិក្ខាបទចំនួន ២ គឺខ្វះភាពពេញលេញជាមនុស្ស ៤០ ភាគរយ

**សីល ៥ ឬ និច្ចសីល** ដែលមនុស្សត្រូវរក្សា មានអង្គ ៥ ដូចខាងក្រោម ៖

(១). មិនសម្លាប់ជីវិតសត្វលោក

(២). មិនលួចទ្រព្យសម្បត្តិរបស់អ្នកដទៃ

(៣). មិនប្រព្រឹត្តិខុសក្នុងកាមគុណទៅលើកូនប្រពន្ធអ្នកដទៃ

(៤). មិនពោលពាក្យមិនពិត

(៥). មិនសេពគ្រឿងស្រវឹង

**អានិសង្សនៃការរក្សាសីល ៥ បានល្អ ៖**

(១). មានទ្រព្យសម្បត្តិបរិបូណ៌តាមផ្លូវសុចរិត

(២). មានកេរ្តិ៍ឈ្មោះល្អ ផ្សាយនៅគ្រប់ទីកន្លែង

(៣). មានទឹកមុខស្រស់បស់ ក្លៀវក្លា រីករាយ

(៤). មានសតិរឭកត្រូវជានិច្ច

(៥). មានកំណើតថ្មីនៅទេវលោក

"មនុស្សគ្មានសាសនា ប្រៀបដូច សត្វស្វាគ្មានជម្រក ។ មនុស្សកាន់សាសនាភ្ជាក់ផ្អើល ប្រៀបដូច កាន់ភ្លើងដុតឆេះខ្លួនឯង ។" *ស៊ាន វិត*

**សីល ៨ ឬ ឧបោសថសីល មាន អង្គ ៨ ៖**

បន្ថែម ៣ សិក្ខាបទទៀត ពីលើសីល ៥

(៦). មិនបរិភោគនូវភោជនាហារក្នុងកាលខុស

(៧). មិនរាំនិងច្រៀងនិងប្រគុំនិងមើលនូវល្បែង និងមិនតាក់តែងស្អិតស្អាងរាងកាយដោយផ្កាកំរងនិងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ

(៨). វៀរចាកទីសេនាសនដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនដ៏ប្រសើរ ។

**កូនល្អរក្សាសីល ហៅថាបុគ្គលបដិបត្តិធម៌តាមព្រះពុទ្ធឱវាទ ត្រូវមានធម៌ ៤ ប្រការដូចខាងក្រោម ៖**

១. ត្រូវចេះចាំព្រះធម៌ ឱ្យបានស្ទាត់

២. ត្រូវយល់ន័យព្រះធម៌ ឱ្យបានច្បាស់

៣. ត្រូវបដិបត្តិតាមព្រះធម៌ ហៅថា សមាទានសីល ឬ សុំសីល ដោយទៅវត្តជារៀងរាល់ថ្ងៃសីល និងដោយប្រតិបត្តិតាមសិក្ខាបទទាំង ៥ ឬ ៨ នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ រាល់ៗថ្ងៃ

៤. ត្រូវទទួលបានលទ្ធផលល្អ ដោយសម្រេចឱ្យបាននូវអានិសង្សទាំង ៥ ខាងលើ ។

## គ. កូនល្អពិត រក្សាអរិយកិច្ច ៣ យ៉ាង

កូនល្អពិត ជាកូនដែលបានធ្វើកិច្ចការដ៏ធំបំផុតក្នុងជីវិត ឱ្យសម្រេចជោគជ័យ ។ កិច្ចការដ៏ធំបំផុត១នោះ ឈ្មោះថា អរិយកិច្ចនៃកូនល្អពិតដែលមាន ៣ ប្រការ ដូចខាងក្រោម :

- សក្ការៈ ២៣ យ៉ាងនៃកូនល្អពិតចំពោះឪពុកម្តាយ
- ធម្មកិច្ច ៥ យ៉ាង នៃកូនល្អពិតចំពោះឪពុកម្តាយ
- សមត្ថភាព ៣ យ៉ាង នៃកូនល្អពិតដើម្បីសម្រេចគោលបំណងពិតរបស់ឪពុកម្តាយ



### ១. សក្ការៈ ២៣ យ៉ាងនៃកូនល្អពិតចំពោះឪពុកម្តាយ

សក្ការៈ ប្រែថា សេចក្តីគោរព តង្វាយ ជំនួន គ្រឿងបូជា ការធ្វើបដិសណ្ឋារៈដោយគោរព ឬ ការបម្រើ ។ កូនល្អ ត្រូវគោរពឪពុកម្តាយដោយ កាយ វាចា ចិត្ត នូវគ្រឿងសក្ការៈ និង ការបម្រើដោយសេចក្តីគោរព ជាការសម្តែងនូវអំណរគុណចំពោះគុណរបស់លោកទាំងពីរ ។ កូនល្អត្រូវមានសមត្ថភាព អាចតបគុណ ដោយទំនុកបម្រុងលោកទាំងពីរ ជាប្រាក់កាសនិងសម្ភារៈ ព្រមទាំងត្រូវបម្រើលោកទាំងពីរដោយផ្ទាល់ដៃ ដោយសុឆន្ទៈ ពីព្រោះ លោកជាបុព្វការីរបស់កូន ។

ដូចនេះ កូនល្អពិត ត្រូវបដិបត្តិសក្ការៈ ២១ យ៉ាង ជូនព្រះទាំងពីរ ដូចខាងក្រោម :

### [១]. ជូនសំលៀកបំពាក់

កូនល្អ ត្រូវជូនឪពុកម្តាយនូវសំលៀកបំពាក់សមរម្យតាមវ័យចាស់ទុំ កាន់ធមិអារ្យ រក្សាសីល ៥ ឬ ៨ ឱ្យបានគ្រប់គ្រាន់ ជាមួយនឹងក្រមាឬកន្សែងតូចធំ ដើម្បីលោកប្រើប្រាស់នៅក្នុងគ្រប់ឱកាសនៃពិធីបុណ្យទានក្តី សម្រាប់ប្រើប្រចាំថ្ងៃក្តី ទាំងក្នុងរដូវក្តៅ និងរដូវត្រជាក់រងា ។

### [២]. ជូនម្ហូបអាហារនិងទឹកពិសា

កូនល្អ ត្រូវជូនឪពុកម្តាយនូវបាយសម្ល នំចំណី បង្អែម ផ្លែឈើ ទឹកដោះគោ ទឹកផ្លែឈើ ស្ករស ទឹកក្តៅទឹកត្រជាក់សម្រាប់ពិសា និង គ្រឿងបរិភោគផ្សេងៗទៀត ទាំងពេលព្រឹក ពេលថ្ងៃត្រង់ និង ពេលល្ងាច ព្រមទាំងជូនលោកទាំងពីរនៅពេលលោកមានតម្រូវការ ។

### [៣]. ជូនទីសេនាសន

កូនល្អ ត្រូវជូនឪពុកម្តាយនូវទីកន្លែងដ៏សមគួរសម្រាប់សម្រាកសម្រាន្ត មានដូចជា បន្ទប់ គ្រែ កៅអី ពូក មុង កន្ទេល ខ្នើយ រនាំងវាំងនន ព្រំ ជាដើម ដើម្បីលោកបានសម្រាកនិងសម្រាន្តស្រួលកាយ ។

---

"កូនល្អ ត្រូវតបគុណឪពុកម្តាយដោយទាំង នាមរូប និង នាមធមិ ។"

*ស៊ាន វិត*

---

## [៤]. ជូនថ្នាំព្យាបាលរោគ

កូនល្អ ត្រូវជូនឪពុកម្ដាយនូវឱសថ បង្ការទុកសម្រាប់ព្យាបាលជម្ងឺ ឬ បន្ថយភាពតានតឹងនៃជម្ងឺ ពេលលោកមានជម្ងឺស្រាលៗ ពិសេសនៅពេលលោកទាំងពីរនៅម្នាក់ឯង ។ ត្រូវរៀបចំឱ្យមានថ្នាំកែរោគមួយចំនួន មានដូចជាថ្នាំសម្រាប់បំបាត់ជម្ងឺផ្ដាសាយ ឈឺក្បាល ក្ដៅខ្លួន ប្រេងខ្យល់ ប្រេងកូឡា ឱសថសម្រាប់បំបាត់ការឈឺចុកចាប់ពេលមានសត្វល្អិតឬសត្វមានពិសទិចឬខាំ ជាដើម ។

## [៥]. ជូនគ្រឿងសំអាតកាយ

កូនល្អ ត្រូវជូនឪពុកម្ដាយនូវគ្រឿងនិងប្រដាប់ប្រដាប្រើប្រាស់សម្រាប់សំអាតកាយ មានដូចជា សាប៊ូកក់សក់ សាប៊ូដុះខ្លួនប្រាណ ថ្នាំដុះធ្មេញ ច្រាសដុះធ្មេញ ច្រាសដុះដៃជើង ក្រមាឬកន្សែងសម្រាប់ជូតទឹក គ្រឿងក្រអូបដើម្បីលោកទាំងពីរមានអារម្មណ៍រីករាយជ្រះថ្លា ។

## [៦]. ជូនមធ្យោបាយសិក្សាព្រះធម៌

កូនល្អ ត្រូវជូនឪពុកម្ដាយនូវសម្ភារៈសិក្សាព្រះធម៌ មានដូចជា សៀវភៅសរសេរ សៀវភៅអាន សៀវភៅព្រះធម៌មានគម្ពីរព្រះត្រៃបិដកជាដើម ប៊ិច ខ្មៅដៃ តុ កៅអី វិទ្យុម៉ាញ៉េសម្រាប់ស្ដាប់ព្រះធម៌ ខ្សែ

អាត់ វីដេអូព្រះធម៌ ដើម្បីលោកសិក្សារៀនសូត្រឱ្យមានបញ្ញាក្នុងធម៌ ឬ អានសៀវភៅធម៌ជូនលោកស្តាប់ ។ ម្យ៉ាងទៀត កូនល្អ គប្បីប្រើមធ្យោបាយធ្វើដំណើរផ្ទាល់ខ្លួន ដូចជា ម៉ូតូ ឬ រថយន្ត ជាដើម ជូនព្រះមានគុណទាំងទ្វេទៅរៀនព្រះធម៌ ឬ ទៅស្តាប់ព្រះធម៌ទេសនា នៅវត្តអារាម និងទីផ្សេងៗទៀង ជូនពេលវេលាដល់លោក ដើម្បីបានទៅសំណាក់ធម៌ ធ្វើសមាធិចម្រើនវិបស្សនាកម្មដ្ឋាននៅទីជិតឆ្ងាយ ។ ជាងនេះទៀត កូនល្អ គប្បីនិមន្តព្រះសង្ឃ ឬ បណ្ឌិតធម៌ មកសម្តែងព្រះធម៌ នៅឯគេហដ្ឋានផ្ទាល់ខ្លួនជាពិសេសនៅថ្ងៃសីល ។

## [៧]. បួសក្នុងព្រះពុទ្ធសាសនា

ចំពោះកូនប្រុស គប្បីចូលសាងផ្នួសដើម្បីរៀនសូត្រធម្មវិន័យ ដើម្បីព្យាយាមប្រតិបត្តិតាមព្រះធម៌ដ៏ថ្លៃបរិសុទ្ធ និងដើម្បីព្យាយាមបង្ហាត់បង្រៀនព្រះធម៌ដល់ពុទ្ធបរិស័ទ ឱ្យចេះរស់នៅក្នុងជីវិតប្រចាំថ្ងៃស្អាតបាតដោយសីលធម៌ល្អ សង្រួមកាយ សង្រួមវាចា សង្រួមចិត្ត។ ចាត់ថាជាកូនមានឧបនិស្ស័យខ្ពស់ ដោយបានបួសរៀនតាមព្រះពុទ្ធមាគ៌ា បានធ្វើឱ្យឪពុកម្តាយសប្បាយចិត្ត មានកិត្តិយស មានឱកាសច្រើនបំពេញបុណ្យកុសល ។

---

"អាហារឆ្ងាញ់យ៉ាងណា គង់ណាយចិត្ត

បពិត្រព្រះធម៌ ពិតថ្លៃវិសេស ក្រេបរសមិនចេះណាយ ។" *ស៊ាន វិត*

---

## [៨]. ជូនលុយកាក់

កូនល្អ ត្រូវជូនឪពុកម្តាយនូវលុយកាក់ជាប្រចាំ ប្រចាំថ្ងៃ សប្តាហ៍ ខែ ឬ ប្រចាំឆ្នាំ ជាទៀងទាត់ និងជូនប្រាក់កាសដល់លោកទាំងពីរ នៅពេលលោកមានតម្រូវការចាំបាច់បន្ទាន់ ដើម្បីលោកចាយវាយប្រចាំថ្ងៃ និងដើម្បីសាងបុណ្យទាន ។ កូនល្អ មិនត្រូវបណ្តោយឱ្យលោកធ្វើការរកលុយចិញ្ចឹមអាត្មាទៀតឡើយ ចាប់ពីលោកមានអាយុ ៥០ ឆ្នាំឡើង ឬ ពេលលោកឈានចូលបច្ឆិមវ័យ គឺកូនល្អ ត្រូវមានសមត្ថភាព និង លទ្ធភាពទំនុកបម្រុងចិញ្ចឹមលោកវិញ។ **ព្រះពុទ្ធគាថា:** "កូនប្រុសស្រីទាំងឡាយណាចិញ្ចឹមមាតាបិតាដោយធម៌ សូម្បីទេវតាទាំងឡាយ តែងរក្សានូវនរជនអ្នកចិញ្ចឹមមាតាបិតានេះ ហើយបណ្ឌិតទាំងឡាយក្នុងលោកនេះ តែងសរសើរនូវនរជននោះ នរជននោះ លុះបង់លោកនេះទៅ រមែងរីករាយសប្បាយក្នុងស្ថានសួគ៌" ។

## [៩]. ងូតទឹកនិងដុះសំអាតដៃជើង

កូនល្អ ត្រូវបម្រើឪពុកម្តាយដោយការងូតទឹកជូនលោក ឱ្យបានសមគួរនិងស្អាតបាត ឱ្យដូចកាលលោកធ្លាប់ងូតទឹកឱ្យកូនអញ្ចឹងដែរ។ កូនល្អ ត្រូវលៃលកឱ្យមានទឹកក្តៅទឹកត្រជាក់ជាប្រចាំ សម្រាប់លោកងូតតាមរដូវកាលរងានិងរដូវក្តៅ ។ សម័យបច្ចុប្បន្ននេះ គេមានឧបករណ៍ទឹកក្តៅទឹកត្រជាក់សម្រាប់ងូត ដែលកូនល្អដែលមានសមត្ថភាព គួររៀបចំទុក

ជាស្រេចជូនលោកប្រើប្រាស់តាមតម្រូវការ ដើម្បីឱ្យមានទឹកក្តៅទឹកត្រជាក់ទុកប្រើទាំងនៅពេលព្រឹក ពេលថ្ងៃ និងពេលយប់ព្រលប់ ។ ជាងនេះទៀត កូនល្អ ត្រូវរៀបចំទឹកក្តៅឧណ្ហៗដើម្បីត្រាំដៃជើងជូនលោក ឱ្យលោកស្រួលខ្លួន និងយកកូនកន្សែងបន្សើមទឹកក្តៅល្មម ជូតមុខមាត់ជូនលោកទាំងពីរ ហើយក៏គួរតែកំដៅដៃជើងរបស់លោកមុនពេលសម្រាន្ត ឬ កំពុងសម្រាក ។

## [១០]. បម្រើឪពុកម្តាយក្នុងកិច្ចការសំអាត

កូនល្អ ត្រូវបម្រើឪពុកម្តាយដោយការបោស ជូត សំអាត ដុះលាង ផ្ទះនិងបរិវេណផ្ទះ, បន្ទប់សម្រាកសម្រាន្តរបស់លោក រួមទាំង តុ កៅអី គ្រែ មុង ភួយ ខ្នើយ និងអ្វីដែលលោកប្រើប្រាស់ មានដូចជា រថយន្ត ម៉ូតូ កង់ និងសំលៀកបំពាក់របស់លោក ឱ្យបានល្អស្អាតជាប្រចាំ ។

## [១១]. គក់ច្របាច់ជូនឪពុកម្តាយ

កូនល្អ ត្រូវបម្រើឪពុកម្តាយដោយការគក់ច្របាច់ ចាប់សរសៃដៃសរសៃជើង កាច់កដៃកជើង ធ្វើយ៉ាងណា ដើម្បីលោកធូរស្បើយភាពតានតឹងនៃរាងកាយ ក៏ដូចជាដើម្បីលោកសម្រួលអារម្មណ៍ឱ្យល្អ ។ កូនល្អ គប្បីយកចិត្តទុកដាក់ធ្វើ និងហ្វឹកហាត់ធ្វើឱ្យប្រសប់ ជាជាងការបម្រើលេងៗដែលជាកិរិយាប្រមាទ ។ បើសិនជា កូនមានជំនាញ ឬ ស្ទាត់ខាងការធ្វើសរសៃ ឬ ការគក់ច្របាច់ទៀត រឹតតែប្រសើរខ្លាំងណាស់ ព្រោះកិច្ចការបម្រើបែបនេះ ជាការចងសញ្ចូតនាជិតដិតរវាងកូននិងលោកមានគុណ ។

## [១២]. ជូនមធ្យោបាយធ្វើដំណើរដល់ឪពុកម្តាយ

កូនល្អ ត្រូវបម្រើឪពុកម្តាយដោយការការពារដឹកជញ្ជូនលោកដោយខ្លួនឯង ពីទីកន្លែង១ទៅទី១ទៀត ដែលលោកមានធុរៈត្រូវអញ្ជើញទៅ ដូចជា លោកអញ្ជើញទៅធ្វើបុណ្យ ទៅសិក្សាព្រះធម៌ ទៅសួរសុខទុក្ខលេងញាតិបងប្អូន ឬ ទៅកំសាន្តទីណា១ ជាដើម ។ កូនល្អ គប្បីដឹកនិងជូនលោកធ្វើដំណើរដោយសុវត្ថិភាព កុំឱ្យមានការបារម្ភភ័យ ចំពោះគ្រោះថ្នាក់អ្វីឱ្យសោះ មិនថាធ្វើដំណើរដោយម៉ូតូ រថយន្តក៏ដោយ ។ បើកូនល្អមានសមត្ថភាព ត្រូវមានរថយន្តជូនលោកទៅមក ព្រោះរថយន្តផ្តល់ភាពសុខស្រួល សុវត្ថិភាពជាងមធ្យោបាយឯទៀត ។

## [១៣]. រំលែកកិច្ចការរបស់ឪពុកម្តាយ

កូនល្អ ត្រូវបម្រើឪពុកម្តាយដោយការចែករំលែកកិច្ចការផ្ទាល់ខ្លួនរបស់លោក យកមកធ្វើជំនួស ដើម្បីបានសំរាលការលំបាកដល់លោកផង ដើម្បីកូនបានរៀនសូត្រពីកិច្ចការរបស់ចាស់ទុំផង ដើម្បីលុបបំបាត់ចរិតខ្ជិល ឬ ពេលទំនេរឥតប្រយោជន៍ ឬ ទម្លាប់អាក្រក់របស់ខ្លួន ។ មានកិច្ចការរបស់លោកទាំងពីរមួយចំនួនដែលកូនអាចធ្វើបាន ប៉ុន្តែបើមានកិច្ចការមិនអាចធ្វើបាន កូនឆ្លាត ត្រូវសុំឱ្យលោកជួយណែនាំ ប្រាប់ពីវិធីធ្វើ ហើយកូនត្រូវតែយកចិត្តទុកដាក់រៀនធ្វើឱ្យម៉ត់ចត់ មានទំនួលខុសត្រូវខ្ពស់

កុំលេងសើច បើមានចំនុចណាធ្វើមិនកើត ឬ ធ្វើមិនទាន់បានល្អ ឬ មិនច្បាស់ ត្រូវចេះជម្រាបលោកដោយត្រង់ និងជម្រាបសួរលោកឱ្យណែនាំបន្ថែមជាបន្តបន្ទាប់ កុំបីខ្លាចគាត់បន្ទោសឱ្យសោះ ហើយជៀសវាងចរិតលាក់បាំង ភូតកុហក ឱ្យបានជាដាច់ខាតដែលជាចរិតធ្វើឱ្យបាត់ទំនុកចិត្ត ។

## [១៤]. ថ្វាយបង្គំឪពុកម្ដាយ

កូនល្អ គប្បីប្រណិប័តន៍ចំពោះឪពុកម្ដាយដោយអង្គ ៥ គឺ ក្បាល ១ ដៃ ២ និង ជើង ២ ព្រមដោយកាយ វាចា ចិត្ត ។ ការដែលកូនចេះគោរពឪពុកម្ដាយដោយការសំពះ និងការថ្វាយបង្គំលោកទាំងពីរ លាតត្រដាងបញ្ជាក់ច្បាស់ថា កូនពិតជា ទទួលស្គាល់ទម្ងន់នៃគុណរបស់លោកទាំងពីរមកលើខ្លួនជាប្រាកដ ហើយការគោរពបែបនេះ ក៏បញ្ជាក់ដល់លោកទាំងពីរថា កូនរឭកនិងចងចាំក្នុងចិត្តជានិច្ចនូវគុណូបការៈរបស់លោក ។ ថ្វីត្បិតតែ ការសំពះនិងការថ្វាយបង្គំ ជាកិរិយាមិនពិបាកធ្វើ ប៉ុន្តែវាជាទ្វាររបស់ចិត្ត ហើយកូនសម័យបច្ចុប្បន្ននេះ ភាគច្រើនមិនប្រណិប័តន៍កិរិយាទាំងនេះឡើយ ។ គុណរបស់លោកទាំងទ្វេច្រើនអនេក បែរជាមិនទទួលស្គាល់ កូនខ្លះយកការអៀន មិនហ៊ានសំពះ ថ្វាយបង្គំលោកទៅវិញ ដែលនេះជាទង្វើលុបគុណនិងប្រមាទគុណព្រះហើយ ។ ចូរចេះកែខ្លួន ខំតបគុណព្រះ !

---

**"មិនគោរពសំពះព្រះរស់ព្រោះអៀន មិនអីមអៀមសំពះគេបាន ។"**

*ស៊ាន វិត*

---

## [១៥]. រំសាយកង្វល់របស់ឪពុកម្ដាយ

កូនល្អ ត្រូវចេះយ៉ាងប៉ិនប្រសប់ក្នុងការធ្វើយ៉ាងណា ឱ្យក្ដីបារម្ភ កង្វល់ កំហឹង ភាពតានតឹងនឿយណាយតាមផ្លូវចិត្តទាំងឡាយ ត្រូវបានរសាយខ្លះចេញពីទ្រូងរបស់ពួកគាត់ ។ ការធ្វើជាកូនដែលឪពុកម្ដាយទុកចិត្ត កោតសរសើរ ជាឥទ្ធិពលដ៏សំខាន់ដែលធ្វើឱ្យកូនអាចលួងលោមនិយាយសម្រួលផ្លូវចិត្ត ឬ សម្ដែងការយល់ចិត្តដល់លោក បានលទ្ធផលល្អ ។ កូនល្អ អាចលើកយកស្នាដៃរបស់ខ្លួនមកជម្រាបលោក ក៏អាចធ្វើឱ្យលោកបានសប្បាយចិត្តខ្លះដែរ ឬ និយាយកំប្លែងលេងជាមួយគាត់ដោយសមគួរ ។ កង្វល់ ជាចំណែកមួយនៃជំងឺចិត្តដែលក៏ពាក់ព័ន្ធនឹងកាយផងដែរ ដូចនេះកូនអាចធ្វើសរសៃ គក់ ច្របាច់ តប់ ដោយឥរិយាបថយកចិត្តទុកដាក់និងប្រសប់ កុំធ្វើលេងៗដោយសេចក្ដីប្រហែសធ្វេសឱ្យសោះ ឬ យកទឹកក្ដៅត្រាំជើងរបស់ពួកគាត់ ឬ ជូនកន្សែងជូតមុខជ្រលក់ទឹកក្ដៅឧណ្ហៗទៅគាត់ ដើម្បីធ្វើឱ្យលោកទទួលអារម្មណ៍ស្រស់ថ្លាតាមផ្លូវកាយ ។

---

"កូនដែលល្អ ព្រោះមានការយល់ដឹងត្រូវថា ខ្លួនជាកូនត្រូវធ្វើអ្វីខ្លះ ហើយខិតខំព្យាយាមធ្វើតាមការយល់ដឹងត្រូវនោះ ។ រីឯ កូនដែលមិនល្អ ព្រោះមានការយល់ដឹងខុស (១) មិនដឹងថាខ្លួនជាកូនត្រូវធ្វើអ្វីខ្លះ ក៏ធ្វើទាំងល្ងិតល្ងង់ (២) ដឹងថាកូនល្អត្រូវធ្វើអ្វីខ្លះដែរ តែមិនព្រមព្យាយាមធ្វើតាមការដឹងត្រូវនោះ ។" *ស៊ាន វិត*

---

## [១៦]. រៀបចំបាយទឹកជូនឪពុកម្ដាយ

កូនល្អ គប្បីបម្រើលោកទាំងពីរ ដោយផ្ទាល់ដៃ ឱ្យសមនឹងពាក្យថា សងគុណលោកដោយក្បាល ១ ដៃ ២ និងជើង ២ ជាជាងប្រើ ឬពឹងអ្នកដទៃឱ្យធ្វើជំនួស ក្នុងការរៀបចំបាយទឹកជូនលោកពិសា បើទោះជាពេលខ្លះ លោកមិនអាចពិសាក្នុងហេតុណា១ ក៏លោកមានទឹកចិត្តរីករាយពិសាបាយដែលកូនល្អរបស់គាត់បានរៀបចំជូនគាត់ដែរ ត្បិតឪពុកម្ដាយតែងរីករាយពេលឃើញកូនសង្វាតខំសងគុណ ។ កូនណា ខំតបសងគុណព្រះ រមែងបានគុណប្រយោជន៍កាន់តែច្រើន គឺជួបប្រទះតែសេចក្ដីសុខ មានលាភសំណាងក្នុងការសិក្សា ការងារ គ្រួសារ និងសង្គម មានទ្រព្យសម្បត្តិចាយវាយមិនខ្វះ អ្នកជិតឆ្ងាយសរសើរគ្រប់ៗគ្នា ។ គប្បីបម្រើលោកឱ្យស្មើដៃស្មើជើងគឺទិញម្ហូបអាហារ ធ្វើម្ហូប ដាំបាយ រៀបចំបាយទឹក អញ្ជើញលោកពិសាដោយការគួរ លាងជូតសំអាតចានឆ្នាំងកែវទឹកកន្លែងពិសាបាយឱ្យស្អាតល្អ និង រៀបចំទុកដាក់របស់របរពិសាបាយក្នុងទីសមគួរ ។ ជាងនេះទៀត ក៏គួររៀបចំបង្អែមផ្លែឈើជូនលោកពិសាមុនឬក្រោយបាយ ដើម្បីបើកក្រពះនិងលាងមាត់ ។ ក្រោយពីលោកបានពិសាអាហារឆ្ងាញ់ដោយទឹកចិត្តដ៏ប្រពៃរបស់កូនហើយ ចូរកូនល្អ កុំភ្លេចឱ្យសោះ អនាម័យល្អ ដែលជាការបង្ការនូវជំងឺបានជាច្រើនផង នាំឱ្យលោកមានសុខភាពល្អ អាយុយឺនយូរ ។

## [១៧]. បម្រើយាយតាដូចបម្រើឪពុកម្ដាយ

កូនល្អ មិនត្រឹមតែតបស្នងសងគុណដល់បុព្វការីជិត មានដូចជា ឪពុកម្ដាយ គ្រូបង្រៀន ចៅហ្វាយនាយ ប៉ុណ្ណោះទេ ថែមទាំងដល់បុព្វការីឆ្ងាយ មាន យាយតាទាំងសងខាង គ្រូបង្រៀនរបស់ឪពុកម្ដាយ និងលោកអ្នកមានគុណឯទៀតរបស់ឪពុកម្ដាយផងខ្លួន ព្រោះលោកទាំងនេះជាបុព្វការីរបស់ឪពុកម្ដាយ ។ កូនល្អ គឺជាទ្រព្យដ៏មានតម្លៃបំផុត ជាមុខជាមាត់ ជាដៃជើង ជាភ្នែកជាច្រមុះ ជាបេះដូងថ្លើមប្រមាត់ ជាសាវ័ក និងជាប្រភពនៃក្ដីសុខរបស់ឪពុកម្ដាយ ដូចនេះ ឪពុកម្ដាយជាកូនល្អ ជាសិស្សល្អ ជាកូនចៅល្អ និង ជាមនុស្សល្អ ល្អិកណាលោកទាំងពីរមានអវយវៈ ប្រុសាវ័កល្អ ដែលស្គាល់នូវគុណរបស់បុព្វការីឆ្ងាយ ។ សំគាល់ថា ជាមនុស្សនៅត្រង់មានគុណធម៌ គឺការដឹងគុណនិងតបគុណដល់បុគ្គលដែលមានឧបការៈមកលើខ្លួន ហើយផ្ដល់នូវមេត្តាធម៌ដល់សព្វសត្វលោក ទើបមានលក្ខណៈជាមនុស្សទាំងរូបកាយ និងសតិវិញ្ញាណ យ៉ាងដូច្នេះហើយ ក្នុងបច្ចុប្បន្នជាតិបានតែសេចក្ដីសុខ សុភមង្គល ហើយនឹងបានទៅកើតក្នុងភពខ្ពង់ខ្ពស់ ពេលធ្វើមរណកាលទៅកាន់លោកខាងមុខ ។

---

"កូនល្អពិត រមែងបង្អោនចិត្តនឹករឭករឿយៗនិងគោរពចំពោះគុណទាំង ៥ គឺគុណនៃ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មាតាបិតា និងគុណ គ្រូ ។"

*ស៊ាន វិត*

---

## [១៨]. ជួយយកអាសាបងប្អូនបង្កើតនិងញាតិសន្តាន

កូនល្អ បានបម្រើដល់កិច្ចការផ្ទាល់របស់ឪពុកម្តាយហើយ ក៏គប្បីមិនបង្ករឿងហេតុមិនល្អដល់បងប្អូនបង្កើត ដែលសុទ្ធជាសរសៃឈាមរបស់ឪពុកម្តាយ ។ មិនត្រឹមតែមិននាំរឿងដល់បងប្អូនទេ គឺត្រូវចេះធ្វើជាបងប្អូនសាច់ឈាមដូចគ្នាដែលស្រឡាញ់គ្នា រួមសុខរួមទុក្ខគ្នា រួមដោះស្រាយបញ្ហានានាយ៉ាងស្មោះស្ម័គ្រពិត ជៀសវាងនូវការច្រណែនគ្មានហេតុផល ការប្រទូស្តរាយ ការព្រងើយកន្តើយ ការព្យាបាទ ការបៀតបៀន ។ បងប្អូនល្អ តែងជួយជ្រោមជ្រែងគ្នាឱ្យថ្កុំថ្កើង រីកចម្រើន ទាំងចំណេះវិជ្ជា សមត្ថភាព ទ្រព្យសម្បត្តិ សេចក្តីល្អទូទៅ កតញ្ញូតា កតវេទិតា ជាដើម ។

## [១៩]. ជួយយកអាសាញាតិខាងឪពុកខាងម្តាយ

កូនល្អ គប្បីធ្វើល្អ ដោយចេះជួយយកអាសាញាតិទាំងសងខាង ទាំងខាងឪពុក ទាំងខាងម្តាយ ពេលញាតិទាំងឡាយត្រូវការក្តី ឬក៏ត្រូវចេះទៅបម្រើញាតិដោយស្ម័គ្រចិត្ត ។ ញាតិទាំងពីរខាង សុទ្ធតែជាអ្នកដែលបានសាងល្អ ដល់ឪពុកម្តាយកន្លងមក យ៉ាងនេះហើយ កូនល្អ តែងចេះធ្វើល្អជាតំណាងឪពុកឬម្តាយ ក៏ដើម្បីធ្វើឱ្យញាតិទាំងសងខាងចេះគោរពស្រឡាញ់ រាប់រកគ្នា ជួយគ្នាទៅវិញទៅមកដោយស្មោះត្រង់ជាដរាប ។ ការចេះយកអាសា រមែងញុំាងអ្នកប្រព្រឹត្តឱ្យសម្បូរញាតិ ។

## [២០]. ជួយយកអាសាអ្នកជិតខាង

កូនល្អ គប្បីចាត់ទុកអ្នកជិតខាង ជាញាតិជិតដែរ ដែលប្រៀបពួកគាត់ទៅនឹងរបងផ្ទះ, សុខ ឬ ទុក្ខ ដោយសារតែរបង ។ ធ្វើល្អទៅលើពួកគាត់ រមែងទទួលបានសេចក្តីល្អ សេចក្តីស្រឡាញ់រាប់អាន មើលថែទាំ ការពារ មិនបង្ករឿងហេតុអាក្រក់ មកវិញដែរ ។ ជាធម្មតា, ផ្ទះរបស់លោកអ្នកមានសេចក្តីសុខ លុះត្រាតែអ្នកជិតខាងមានសេចក្តីសុខដែរ ហើយដែលសេចក្តីសុខនេះ កើតអំពីការចេះឱ្យសុខដល់គ្នាទៅវិញទៅមក ។ អ្នកជិតខាង ក៏ប្រៀបដូចជាទេវតាអញ្ជើងដែរ បើលោកអ្នកធ្វើឱ្យពួកគាត់រីករាយ ពួកគាត់នឹងនាំសុខ ប៉ុន្តែបើលោកអ្នធ្វើឱ្យពួកគាត់ខឹងសម្បា នាំឱ្យពួកគាត់ចងគំនុំ ព្យាបាទ បៀតបៀនលោកអ្នកមិនឱ្យរស់នៅសុខឡើយ ។ ដំណោះស្រាយល្អបំផុត កូនល្អ ត្រូវចេះធ្វើល្អជាមុនចំពោះអ្នកជិតខាង កុំប្រកាន់អ្នកជិតខាងក្រ ឬ មាន ឱ្យសោះ ដើម្បីចៀសវាងការច្រណែននិន្ទាតិះដៀលគ្នា ។ ការចេះយកអាសាអ្នកជិតខាង គឺជាការចាក់កំផែងផ្ទះឱ្យមាំបញ្ឈៀសអមនុស្សចូលទៅញាំញី ។ ចូរចាត់ទុកអ្នកជិតខាង ជាញាតិជិតរបស់លោកអ្នកផង ហើយកុំភ្លេច មានសម្លចានជូនអ្នកជិតខាងផង ។

"ការញញឹមរាក់ទាក់របស់អ្នកជិតខាង គឺជាសេចក្តីសុខរបស់អ្នក ។" OK

*ស៊ាន វិត*

ទី១ - ជា កូនល្អ ពិត

## [២១]. ជម្រាបសួរអំពីតម្រូវការរបស់ឪពុកម្តាយ

បើទោះជាកូនល្អ តែងឆ្លាតវៃ អាចដឹងចិត្តឪពុកម្តាយបានថាតើលោកត្រូវការអ្វី ក៏កូនល្អ ត្រូវចេះជម្រាបសួរអំពីតម្រូវការផ្ទាល់ខ្លួនរបស់លោកផង ព្រោះលោកតែងមានលាក់ទុកនៅក្នុងចិត្ត ហើយលោកក៏ប្រាថ្នាមានកូនល្អបំពេញតម្រូវការទាំងនោះដែរ ។ តើពុកម៉ែចង់បានអ្វីផ្សេងទៀតដែរឬទេ? តើម៉ែចង់ឱ្យកូនធ្វើអ្វីបន្ថែមទៀតដើម្បីឱ្យកូនរឹតតែល្អជាងនេះទៀត? តើកូនមិនគួរធ្វើអ្វីខ្លះ សូមពុកម៉ែមានប្រសាសន៍មក?

## [២២]. ឱនលំទោនចំពោះឪពុកម្តាយដោយកាយ វាចា ចិត្ត

កូនល្អ គប្បីគោរពលោកដោយកាយ គឺត្រូវចេះដើរថ្នមៗដោយការឱនលំទោន ពេលដើរកាត់លោក ទាំងចំពីមុខ ក្រោយ លើ ក្រោម ឆ្វេង ស្តាំ និងទីកន្លែងសម្រាន្តរបស់លោក ។ នៅពេលអង្គុយក្បែរលោក ត្រូវអង្គុយបត់ជើង បើលោកអង្គុយលើគ្រែឬកៅអី កូនល្អត្រូវអង្គុយនៅទីទាបជាងដោយបត់ជើង ។ នៅពេលដ៏សមគួរ ត្រូវលើកដៃសំពះលា សំពះជម្រាបសួរ សំពះសុំទោស ថ្វាយបង្គំលា ថ្វាយបង្គំជម្រាបសួរ ថ្វាយបង្គំសុំទោស ។ គោរពលោកដោយវាចា គឺត្រូវនិយាយតែពាក្យពិតដោយសម្តីទន់ភ្លន់ មានរបៀប សម្តីគោរព ។ កូនល្អប្រើពាក្យ *"ជម្រាប"* ជំនួសពាក្យ *"ប្រាប់"* ឧទាហរណ៍ ម៉ែ, កូនមានដំណឹងល្អ១ ជម្រាបម៉ែ ។

ប្រើពាក្យ *"ពិសា"* ជំនួសពាក្យ *"ហូប, ញ៉ាំ"* ឧទាហរណ៍ ពុកម៉ែ, អញ្ជើញពិសាបាយ ។ ប្រើពាក្យ *"ជូន"* ជំនួសពាក្យ *អោយ* ឧទាហរណ៍ ពុក, កូនបានទិញស្បែកជើង១គូជូនពុក សូមពុកទទួលហើយលមើល ។ ប្រើពាក្យ *"មានប្រសាសន៍"* ជំនួសពាក្យ *"និយាយ"* ឧទាហរណ៍ ម្សិលមិញ ពុកម៉ែមានប្រសាសន៍ថានឹងទិញម៉ូតូឱ្យកូន បើកូនប្រឡងជាប់ ។ ប្រើពាក្យ *"សម្រាន្ត"* ជំនួសពាក្យ *ដេក* ឧទាហរណ៍ ប្អូនៗ, កុំមាត់ឮៗពេក ម៉ែកំពុងសម្រាន្ត ។ ប្រើពាក្យ *"ជម្រាបសួរ"* នៅពេលឆ្លើយឆ្លងតាមទូរស័ព្ទ ឧទាហរណ៍ ជម្រាបសួរម៉ែ! ថ្ងៃនេះទាល់តែដល់ម៉ោង១២:០០ថ្ងៃត្រង់ ទើបកូនចេញពីរៀន។ ចៀសវាងប្រើពាក្យ អាឡូ, ម៉ែ! ជាពាក្យនិយាយទៅកាន់មនុស្សស្មើឋានៈ ។ ប្រើពាក្យ *"អញ្ជើញ"* ឧទាហរណ៍ ពុក, ស្អែកអញ្ជើញទៅវត្តនៅម៉ោងប៉ុន្មាន? កុំប្រើពាក្យ *"ពុកឯង"*, *"ម៉ែឯង"* នេះជាពាក្យជេរឬពាក្យគ្រេវគ្រោធដាក់ព្រះទាំងពីរ ។ គោរពលោកដោយចិត្ត គឺត្រូវគិតរឿយៗអំពីការលំបាករបស់លោក ក្នុងការបង្កើតចិញ្ចឹមទំនុកបម្រុងខ្លួនដល់បច្ចុប្បន្ននេះ ត្រូវគិតរិះរកវិធីរៀនសូត្រនិងធ្វើការងារឱ្យបានលទ្ធផលល្អឆាប់ដើម្បីចិញ្ចឹមលោកវិញ ត្រូវគិតពិចារណាអំពីទង្វើចំពោះលោក តើមានធ្វើអ្វីខុសនិងត្រូវខ្លះ ហើយត្រូវកែប្រែយ៉ាងដូចម្តេច ត្រូវគិតរិះរកវិធីធ្វើយ៉ាងម៉េចដើម្បីនាំលោកឱ្យមានសម្បទា៤គឺ សទ្ធា សីល ទាន និង បញ្ញា ដែលជាទ្រព្យរបស់លោកទៅកាន់បរលោក ។ ញញឹមជាគ្រឿងអលង្ការនៃទង្វើ ។

## [២៣]. សុំខមាទោសឪពុកម្តាយ

កូនគ្រប់រូប តែងបង្កើតកំហុសខុសឆ្គងដោយផ្ទាល់ផង ដោយប្រយោលផង នៅចំពោះមុខឪពុកម្តាយផង នៅទីអាថិកំបាំងផង ។ កូនល្អ ងាយនឹងកែកំហុសទាំងឡាយ ឯកូនមិនល្អ មិនស្តាប់បង្គាប់ ងាយនឹងបង្កើតកំហុសច្រើនឡើងៗ ។ មិនថាកំហុសនោះតូច ឬ ធំក្តី កូនគ្រប់រូប គួរចេះសុំទោសដោយលើកដៃសំពះ ឬ លុតជង្គង់ថ្វាយបង្គំ ជាមួយពាក្យសម្តីទន់ភ្លន់ គោរព និងតាមហេតុផលពិត ជម្រាបសុំខមាទោសពីលោកចំពោះកំហុសឆ្គងទាំងឡាយនោះ ។ កូនដែលខ្វះការដឹងគុណ តែងអៀនមិនហ៊ានលើកដៃសំពះ ឬ លុតជង្គង់ថ្វាយបង្គំសុំទោសលោកឡើយ ចូរយល់ថា ទង្វើមិនគោរពលោកនេះ ជាទង្វើប្រមាទដល់គុណរបស់លោកទាំងពីរពិតៗ ព្រោះមានន័យថា ឪពុកម្តាយបែបហ្នឹង មិនសមនឹងកូននេះគោរពសំពះសោះហើយមើលទៅ? ហើយជាទង្វើប្រមាទដល់ទឹកចិត្តរបស់លោកទាំងពីរផង ព្រោះមានន័យថា កូននេះបានធ្វើខុសហើយ ធ្វើឱ្យលោកពិបាកចិត្តជាងនេះទៀត មិនព្រមកែកំហុសទៀត លោករឹតតែពិបាកចិត្តខ្លាំងឡើង ។ បើគ្រាន់តែហាមាត់និយាយសុំទោស ក៏មិនទាន់ល្អគ្រប់ដែរ ត្បិតសេចក្តីល្អ សេចក្តីបរិសុទ្ធ សេចក្តីពិតនៃទង្វើ១ ត្រូវធ្វើដោយកាយ និងដោយវាចា និងដោយចិត្ត ព្រមដោយបញ្ញាទៀត ទើបល្អគ្រប់ពិតប្រាកដ ។

កូនគ្រប់រូប គប្បីដឹងថា ពុកម៉ែចង់ឃើញកូនសម្ដែងនូវកតវេទិតាធម៌ គឺការខំតែតបគុណដោយផ្ទាល់ខ្លួនផ្ទាល់ដៃរបស់កូន ជាជាងកូនពឹង ឬ ជួលគេ ឱ្យធ្វើជំនួស ។ ដូចនេះ ចូរកូនទាំងឡាយអើយ គប្បីខិតខំបម្រើដោយផ្ទាល់ដៃ ដើម្បីកូនយល់ច្បាស់ពីសុខទុក្ខរបស់ព្រះទាំងពីរផង ដើម្បីបញ្ជាក់ថាកូនពិតជាមានចិត្តដឹងនូវឧបការគុណរបស់លោកពិត១ផង ដើម្បីទទួលបានផលបុណ្យច្រើនក្រៃផង និងដើម្បីធ្វើជាគំរូល្អដល់ញាតិមិត្តផង ។

កូនល្អ គប្បីទំនុកបម្រុងព្រះរស់ទាំងទ្វេ ដោយគ្រឿងសក្ការៈទាំង ២៣ យ៉ាងនេះ កុំបីធ្វេសប្រហែសឡើយ ព្រោះនេះជាការបញ្ជាក់ថាកូនមិនប្រមាទគុណឪពុកម្ដាយផង មិនប្រមាថឪពុកម្ដាយផង ជាកូនកតញ្ញូប្រកបដោយកតវេទិតាធម៌ពិត១ ។ កាលបើកូនបានធ្វើនូវសក្ការៈទាំងនេះហើយ កូននោះបានជូនសម្បត្តិទាំងឡាយក្នុងលោកិយនេះ ដល់លោកអ្នកមានគុណមហិមាទាំងពីរ ហើយកូននោះនឹងមិនខាតប្រយោជន៍ឡើយ គឺកូននោះបានបុណ្យច្រើនណាស់ ជាបុណ្យដែលមិនមានចំនួនអាចរៀបរាប់បានប្រមាណមិនត្រូវ ព្រោះតែបានធ្វើបុណ្យជាមួយព្រះរស់របស់ខ្លួន ។

ទោះយ៉ាងនេះក្ដី កាលបើឪពុកម្ដាយបានទទួលលោកិយសម្បត្តិពីកូនហើយ លោកបានសុខស្រួលតែក្នុងលោកនេះប៉ុណ្ណោះ ម្យ៉ាងសេចក្ដីទុក្ខក៏នៅមានច្រើនមហិមាដែរ ត្បិតបុគ្គលណាមាននូវសម្បត្តិទាំងនេះ រមែង

នៅជាប់ជំពាក់ នៅប្រកាន់មាំ ជាមួយនឹងសម្បត្តិទាំងនេះ ដែលញ៉ាំងចិត្តក្តីអារម្មណ៍ក្តីរបស់ឪពុកម្តាយ ឱ្យនៅមាន រាគៈ ឬ លោភៈ, ទោសៈ និងមោហៈ ជាធូលីនៃចិត្ត រំខានចិត្តមិនឱ្យសុខសោះឡើយ ។ ជាការល្អណាស់ដែលកូនមានចិត្ត មានសមត្ថភាពជូនឪពុកម្តាយនូវលោកិយសម្បត្តិបាន ដើម្បីឱ្យរីតតែពិសេសបំផុត ឬ ឱ្យរីតតែបានបុណ្យច្រើនបំផុតនោះ កូនល្អ គប្បីតបគុណលោកទាំងពីរដោយការជួយសង្គ្រោះលោក តាមផ្លូវលោកុត្តរធម៌ ពោលគឺ កូនត្រូវបំពេញ "ធម្មកិច្ចពី១ ដល់ ៥ យ៉ាង" ដូចខាងក្រោមទៀត ។

ចូរអានសៀវភៅ

"ឪពុកម្តាយល្អពិតរបស់កូន"

សម្រាប់ :

- បុរសនារីគ្រប់រូប ត្រូវអានដាច់ខាត ដើម្បីនឹងក្លាយជាឪពុកម្តាយល្អពិត
- ឪពុកម្តាយគ្រប់រូប ត្រូវអានដាច់ខាត ដើម្បីជួយកូនឱ្យមានអនាគតល្អពិត



## ២. ធម្មកិច្ច ៥ យ៉ាងនៃកូនល្អពិតចំពោះឪពុកម្តាយ

ធម្មកិច្ច គឺករណីយកិច្ចតាមផ្លូវធម៌របស់កូនល្អ ត្រូវធ្វើទៅកាន់ឪពុកម្តាយ ដើម្បីជាការតបស្នងសងគុណ តាមជំនឿនៃព្រះពុទ្ធសាសនា ។ ខ្ញុំបាទ សូមអនុញ្ញាតធ្វើការបូកបញ្ចូលធម្មកិច្ចទាំងឡាយជា ៥ ប្រការ មាន *សទ្ធា សីល ទាន បញ្ញា* និង *បុណ្យ* ហើយដែលព្រះពុទ្ធ មានដីកាថា ធម្មកិច្ចទាំងឡាយនេះ ជាអរិយទ្រព្យ បានន័យថា ជាទ្រព្យប្រសើរបំផុត គ្មានទ្រព្យផ្សេងណាប្រសើរដូច ។



### (១). កិច្ចនាំឪពុកម្តាយឱ្យមានសទ្ធា

សទ្ធា ប្រែថា ជំនឿ គឺការជឿត្រូវ តាមហេតុ-ផល ពោលគឺសេចក្តីជឿថា មានកម្ម-ផល មានបុណ្យ-បាប មានគុណ-ទោស ។ កូនល្អពិត រមែងតម្កល់ខ្លួនក្នុងអំពើល្អ អំពើត្រូវហើយ ក៏ញ៉ាំងនាំឪពុកម្តាយដែលមិនទាន់មានសទ្ធា ឱ្យមានសទ្ធាទាំង ៤ យ៉ាង ។ **ទី១គឺ ជឿកម្ម** ដោយកូនល្អពិត ប្រើប្រាជ្ញាដឹកនាំឪពុកម្តាយឱ្យជឿកម្ម ក្នុងព្រះពុទ្ធសាសនាដែលជាសាសនាកម្មផល គឺថា អ្វីៗក្នុងលោកនេះ កើតឡើងដោយសារកម្ម គឺអំពើរបស់មនុស្ស សត្វ វត្ថុ រុក្ខជាតិ មានប្រតិកម្ម ឬ មានការប៉ះទង្គិចគ្នា នាំឱ្យកើតមានអ្វី១ទៀត មានន័យថា បើយើងសាងអំពើល្អ នឹងទទួលបានផលល្អ បើយើងសាងអំពើអាក្រក់ នឹងទទួលបានផលអាក្រក់ ឬ ពពកប៉ះនឹងខ្យល់

បង្កើតបានជាទឹកភ្លៀង ។ ដែលនេះខុសអំពីសាសនាអាទិទេពនិយមថា អ្វីៗគ្រប់បែបយ៉ាងក្នុងលោក កើតឡើងដោយសារតែព្រះអាទិទេព ជាអ្នកបង្កើត ឬ កើតមានឡើងដោយសារព្រះព្រហ្ម។ ព្រះពុទ្ធ បានត្រាស់សម្ដែងថា "ម្នាលមាណព សត្វទាំងឡាយ មានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាគ្រឿងរលឹក កម្មតែងចែកសត្វទាំងឡាយ ដើម្បីឱ្យថោកទាប និង ខ្ពង់ខ្ពស់" ។ ព្រះពុទ្ធ ក៏បានសម្ដែងថា "កម្លាំងអ្វីមិនស្មើនឹងកម្លាំងកម្ម" ។ **ទី២គឺ ជឿផលរបស់កម្ម** ដោយកូនល្អ ពិត ប្រើប្រាជ្ញាធ្វើឱ្យឪពុកម្ដាយជឿតាមព្រះពុទ្ធដីកាថា "សាងកម្មខ្មៅ ឱ្យផលខ្មៅ សាងកម្មស ឱ្យផលស សាងកម្មខ្មៅខ្លះកម្មសខ្លះ ឱ្យផលខ្មៅខ្លះសខ្លះ សាងកម្មមិនខ្មៅមិនស ឱ្យផលមិនខ្មៅមិនស" ។ បើមនុស្សយើង ទទួលបានផលខ្មៅ នោះមកពី បានសាងកម្មខ្មៅ បើបានផលស នោះមកពី បានសាងកម្មស ដែលខ្លួនឯងជាអ្នកបានសាងទុកសំរាប់ខ្លួនឯង ។ បើជឿវិបាក (ផល) របស់កម្មហើយ ចូររក្សាធមិសន្ដោស ។ ដូចនេះ ចូរចងចាំនូវព្រះពុទ្ធដីកា ហើយបើចង់បានផលស គប្បីខំសាងផលសដោយបញ្ញា ។ ព្រះពុទ្ធ បានសម្ដែងថា "អ្នកធ្វើអំពើល្អ រមែងបានផលល្អ, អ្នកធ្វើអំពើអាក្រក់ រមែងបានផលអាក្រក់, ដូចបុគ្គលសាបព្រោះពូជបែបណា រមែងបានផ្កាផ្លែបែបនោះ" ។ **ទី៣គឺ ជឿថាសត្វលោករស់ក្រោមអំណាចកម្ម**

តាមព្រះពុទ្ធដីកាថា "សព្វសត្វទាំងអស់ មានកម្មជារបស់ខ្លួន មានកម្មជាមរតក មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីពឹង" ។ សត្វលោក វិលកើតវិលស្លាប់នៅ ក្នុងសង្សារវដ្ដ វិលវល់អន្ទោលទៅរកទីបំផុតគ្មាន ព្រោះអំណាចនៃកម្ម ។ បើមនុស្សណា សាងកម្មស នឹងបានរស់នៅជាសុខក្នុងបច្ចុប្បន្នជាតិ ហើយនឹងទៅចាប់កំណើតថ្មីនៅទេវលោកក្រោយពេលស្លាប់ បើមនុស្សណា សាងកម្មខ្មៅ នឹងរស់នៅក្នុងទុក្ខវេទនាជាពន់ពេកក្នុងបច្ចុប្បន្នជាតិ ហើយនឹងទៅចាប់ កំណើតថ្មីនៅទុគ្គតិភព ឬ អបាយភូមិ ៤ មាន នរក ប្រេត តិរច្ឆាន អសុរកាយ ពេលធ្វើមរណកាល បើមនុស្សណា សាងកម្មខ្មៅខ្លះកម្មសខ្លះ នឹងរស់នៅជាមួយទុក្ខផងសុខផង ថែមទាំងទៅចាប់កំណើតថ្មីអាចធ្លាក់ទៅក្នុងទុគ្គតិភព ឬ នៅក្នុងមនុស្សលោក បើមនុស្សណា សាងកម្មមិនខ្មៅមិនស នោះនឹងរស់នៅជាសុខដ៏បរិសុទ្ធ ហើយនឹងសម្រេចបានសម្បត្តិដ៏ប្រសើរក្រៃ គ្មានសម្បត្តិអ្វីប្រៀបផ្ទឹមបានឡើយគឺព្រះនិព្វាន អស់ទុក្ខទាំងពួង ។ **ទី៤គឺ ជឿថាមានព្រះពុទ្ធត្រាស់ដឹង** ព្រះពុទ្ធជាបុគ្គលដែលកើតមកនៅក្នុងលោក ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខសេចក្ដីចម្រើន ដល់មនុស្សសត្វទូទៅ។ ព្រះអង្គជាអ្នកត្រាស់ដឹងនូវញេយ្យធម៌ទាំងឡាយទាំងពួង "សម្មាសម្ពុទ្ធ" និង ចាកឆ្ងាយពីទុក្ខក្នុងកំណើតនិងមរណៈ ។ ព្រះអង្គ មានព្រះមហាករុណាទិគុណយ៉ាងធំធេងក្រៃលែងរកទី

បំផុតគ្មាន ហើយជាព្រះបរមសាស្តាចារ្យដ៏ប្រសើរបំផុតក្នុងត្រៃលោក (មនុស្សលោក, ទេវលោក, ព្រហ្មលោក) ដែលបានសម្តែងព្រះធម៌បង្រៀន ដឹកនាំ ស្រោចស្រង់សព្វសត្វនិករទាំងឡាយក្នុងត្រៃភព ឱ្យបានឆ្លងផុតសេចក្តីទុក្ខលំបាកទាំងឡាយនៅក្នុងជីវិត រហូតដល់សម្រេចបានត្រាស់ដឹងជាព្រះពុទ្ធដែរ ។ ព្រះពុទ្ធ ជាអ្នកបង្កើតព្រះពុទ្ធសាសនា ក្នុងគោលបំណងបង្រៀនព្រះធម៌ដល់មនុស្ស ទេវតា ឱ្យទទួលបានប្រយោជន៍ គឺសេចក្តីសុខ សេចក្តីចម្រើន សន្តិភាព កើតមាននៅក្នុងជីវិត តាមរយៈព្រះធម៌ ឬព្រះពុទ្ធឱវាទ ចំនួន ៨៤,០០០ ធម្មក្ខន្ធ ចារិកទុកក្នុង គម្ពីរព្រះត្រៃបិដក ចំនួន ១១០ ភាគ ចែកចេញជា ៣ ផ្នែកគឺ ព្រះវិន័យបិដក (មាន ១៣ ភាគ ចំនួន ២១,០០០ ធម្មក្ខន្ធ), ព្រះសូត្រ ឬ ព្រះសុត្តន្តបិដក (មាន ៦៤ ភាគ ចំនួន ២១,០០០ ធម្មក្ខន្ធ), និង ព្រះអភិធម្មបិដក (មាន ៣៣ ភាគ ចំនួន ៤២,០០០ ធម្មក្ខន្ធ) ។ ព្រះពុទ្ធ បានត្រាស់សម្តែងព្រះធម៌ទាំងនេះដល់មនុស្សលោក ដើម្បីញ៉ាំងឱ្យមានសទ្ធា **លះបាប-សាងបុណ្យ-អប់រំចិត្តឱ្យល្អបរិសុទ្ធ** តាមរយៈ ៣ សិក្ខា **សីលសិក្ខា សមាធិសិក្ខា បញ្ញាសិក្ខា** ដែលជាមាគ៌ាតែ១គត់ ឆ្ពោះទៅរក **សុភមង្គល នៅក្នុងជីវិត និង ព្រះនិព្វាន ឬ ការត្រាស់ដឹង** ដូចព្រះអង្គដែរ ដែលផុតអស់ទុក្ខទាំងពួង ។

គ្មានសុខណា ប្រសើរជាងសុខស្ងប់ តាមមាគ៌ានៃអរិយមគ្គអង្គ ៨ ។



កាលដែលកូនល្អពិតបានបំពេញនូវបុណ្យកុសលដ៏ធំធេងហើយ គឺញ៉ាំងព្រះទាំងទ្វេដែលមិនទាន់មានសទ្ធា ឱ្យមានសទ្ធា ពោលដោយសង្ខេប គឺព្រះទាំងពីរ ជឿកម្ម ជឿផល ជឿថាសត្វលោកកើតរស់ព្រោះកម្ម និង ជឿព្រះពុទ្ធ ហើយនោះ ព្រះទាំងពីរតែងជាមនុស្សមានអរិយលក្ខណៈ ៣ យ៉ាង ដ៏ប្រសើរគឺព្រះទាំងពីរ **ចូលចិត្តសប្បុរសធម៌** **ចង់ស្តាប់ព្រះសទ្ធម្ម** និង **មានចិត្តប្រាសចាកសេចក្តីកំណាញ់** ។ ផលដ៏ប្រពៃនេះបានសម្រេចហើយ កូនល្អពិតនោះ រមែងទទួល បាននូវអរិយទ្រព្យណា១ដែលកូនប្រាថ្នា គឺ សម្បត្តិមនុស្ស សម្បត្តិទេវតា សម្បត្តិព្រះនិព្វាន ។ ព្រះពុទ្ធ បានសម្តែងថា "កុលបុត្រមានសទ្ធា រមែងបានបុណ្យច្រើន ព្រោះមានសទ្ធាក្នុងទីចំពោះមុខ ព្រោះមានទេយ្យធម៌ក្នុងទីចំពោះមុខ ព្រោះមានទក្ខិណេយ្យបុគ្គលក្នុងទីចំពោះមុខ" ។

## (២). កិច្ចនាំឪពុកម្ដាយឱ្យរក្សាសីល

សីល ប្រែថា ការវៀរចាកកិរិយាខុសតាម ផ្លូវកាយ ផ្លូវវាចា និង ផ្លូវគំនិត ហើយសង្រួមកាន់ចរិយាមារយាទល្អតាមផ្លូវទាំងពារិញ ។ អ្នកមានសីលដ៏បរិសុទ្ធ លុះត្រាតែ អ្នកនោះសមាទានសីល ៥ ឬ សីល ៨ ឬ សីល ១០ ដោយបរិសុទ្ធ ហៅថា អ្នករក្សាសីលវិសុទ្ធ រមែងទទួលបាននូវសេចក្ដីសុខ សេចក្ដីចម្រើន ចាកឆ្ងាយពីសេចក្ដីវិនាស បើពោលតាមព្រះពុទ្ធដីកាថា មាន**អានិសង្សនៃសីលសម្បទា ៥ យ៉ាង**ជារបស់អ្នកសមាទានសីលវិសុទ្ធគឺ (១)សំបូរទ្រព្យសម្បត្តិដោយសុចរិត (២)មានកិត្តិសព្ទដ៏ពីរោះផ្សាយទៅសព្វទិស (៣)មានទឹកចិត្តក្លៀវក្លា មុខមាត់រីករាយស្រស់បស់ (៤)មិនវង្វេង គឺមានសតិត្រូវជានិច្ច សូម្បីពេលធ្វើមរណកាល និង (៥)បានទៅកើតក្នុងសុគតិសួគ៌ទេវលោក បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ។ អ្នកដែលមិន រក្សាសីល និង អ្នកដែលទទួលសីល ៥ ឬ ៨ ឬ ១០ ដែរ តែនៅមានសេចក្ដីប្រមាទក្នុងសិក្ខាបទនីមួយៗ ហៅថា បុគ្គលទ្រុស្តសីល ឬ បុគ្គលដាច់សីល ឬ បុគ្គលវិនាសសីល ឬ បុគ្គលមានវិបត្តិចាកសីល រមែងទទួលបាននូវសេចក្ដីវិនាស បាត់បង់សេចក្ដីថ្លៃថ្នូរ បើពោលតាមពុទ្ធដីកាថា **ទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីលមាន ៥ យ៉ាង**គឺ (១)មានសេចក្ដីវិនាសនៃទ្រព្យសម្បត្តិយ៉ាងធំ (២)មានកិត្តិសព្ទអាក្រក់ផ្សាយទៅសព្វទិស

(៣) មិនមានទឹកចិត្តក្លៀវក្លា មានមុខមិនរីករាយស្រស់បស់ មានមុខឱនចុះ (៤) តែងវង្វេង គឺមានសតិខុសជានិច្ច វង្វេងទាំងពេលធ្វើមរណកាល និង (៥) តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក ។

កូនល្អពិត ជាអតិជាតបុត្រ ឬ អនុជាតបុត្រ រមែងមាន ហិរិ និង ឱត្តប្បៈ បដិបត្តិសីល ៥ ឬ សីល ៨ បានដោយល្អប្រពៃហើយ មានប្រាជ្ញានាំឪពុកម្តាយដែលមិនទាន់រក្សាសីល ឱ្យសមាទានសីល ៥ ឬ សីល ៨ នៅក្នុងជីវិតរបស់ពួកគាត់ ដោយបញ្ញាតាមព្រះធម៌ ឈ្មោះថា ឪពុកម្តាយជាអ្នកបដិបត្តិព្រះធម៌ ។ អ្នកបដិបត្តិព្រះធម៌ គប្បីជាអ្នកដែល (១) ចេះចាំព្រះធម៌ (២) យល់ព្រះធម៌ (៣) ប្រតិបត្តិតាមព្រះធម៌ និង (៤) បានលទ្ធផលល្អពីព្រះធម៌ ។ កូនល្អពិត ដែលបានញុំាងឪពុកម្តាយឱ្យបដិបត្តិសីលតាមព្រះពុទ្ធឱវាទហើយនោះ តែងបានអានិសង្សជាអនេក ហើយឪពុកម្តាយនឹងក្លាយជាមនុស្សមនុស្សោ ឬ មនុស្សទេវោ ជាប្រាកដ ដែលមានអរិយលក្ខណៈ ៥ យ៉ាងគឺមាន **មេត្តា សម្មាអាជីវៈ សន្តោស សច្ចៈ** និង **សតិ** ។ សីល សមាធិ បញ្ញា ជាមាគ៌ាតែ១គត់ ញុំាងចិត្តឱ្យគ្មានធូលី ។

អ្នករក្សាសីល ៥ មានឈ្មោះជាមនុស្សមនុស្សោ ព្រោះមិនមែនជាឃាតករ មិនមែនជាចោរ មិនមែនជាបុគ្គលល្មោភកាម មិនមែនជាបុគ្គលកុហក និង មិនមែនជាបុគ្គលបាត់សតិ ។

## (៣). កិច្ចនាំឪពុកម្តាយឱ្យពេញចិត្តធ្វើទាន ឬ ចាគះ

ទាន ប្រែថា អំណោយ ឬ ការឱ្យ ដែលមាន ៥ ប្រភេទគឺ អាមិសទាន, ធម្មទាន, អភ័យទាន, សុខទាន, និង ទក្ខិណានុប្បទាន ។ **អាមិសទាន** ឬ វត្ថុទាន គឺទានជាសម្ភារៈ ឧបករណ៍ របស់របរប្រើប្រាស់ ដល់អ្នកដែលមានសេចក្តីត្រូវការ រួមទាំងការឱ្យចតុប្បច្ច័យ (បច្ច័យ៤) មាន *ចីវរប្បច្ច័យ* គឺគ្រឿង ស្លៀកដណ្តប់ ដូចជា សំលៀកបំពាក់ មុង ភួយ ក្រមា ក្រណាត់ជូតដៃជើង, *បិណ្ឌបាតប្បច្ច័យ* គឺម្ហូបអាហារ ទឹក ភេសជ្ជៈ, *សេនាសនប្បច្ច័យ* គឺកន្លែងស្នាក់នៅ ជ្រកកោន កៅអី គ្រែ, និង *គិលានភេសជ្ជប្បច្ច័យ* គឺថ្នាំរំងាប់ជំងឺ ឱសថកែរោគ ប្រេងខ្យល់ ប្រេងកូឡា កៅអៀក ។ អ្នកសំបូរបរិច្ចាគ ឬ ការលះ ឬ ការឱ្យនូវអាមិសទាន ឈ្មោះថា អ្នកកំពុងសន្សំទ្រព្យទាំងនោះ ទុកឱ្យខ្លួនឯងសំរាប់ពេលខាងមុខ នោះមិនមែនជាការលះបង់ចោលឥតប្រយោជន៍ឡើយ ។ មនុស្សដែលឱ្យអាមិសទាន រមែងកាន់តែសំបូរទានទាំងនោះនៅក្នុងបច្ចុប្បន្នជាតិ ផ្ទុយទៅវិញ សេចក្តីកំណាញ់ ឬ សេចក្តីអាត្មានិយម នាំមកនូវសេចក្តីវិនាស ៥ យ៉ាង មាន វិនាសញាតិ វិនាសភោគសម្បត្តិ វិនាសព្រោះរោគ វិនាសសីល និង វិនាសទិដ្ឋិ ។ **ធម្មទាន** គឺការឱ្យចំណេះដឹង គំនិត ប្រាជ្ញា សមត្ថភាព ឱវាទ ការដាស់តឿន ការណែនាំ ការបង្រៀន ការកែប្រែការយល់ខុសទៅជាត្រូវ

ការលើកទឹកចិត្ត ការពន្យល់ឱ្យស្គាល់ទង្វើល្អតាមផ្លូវកាយ វាចា ចិត្ត ។ ធម្មទាន មាន ២ ប្រភេទៈ លោកិយធម្មទាន គឺការអប់រំឱ្យយល់ដឹង ស្គាល់ និងចេះរស់នៅប្រសើរក្នុងផ្លូវលោក រីឯ លោកុត្តរធម្មទាន គឺការអប់រំតាមព្រះធម៌ គឺតាមព្រះពុទ្ធឱវាទ ឱ្យលះបាប-សាងបុណ្យ-អប់រំចិត្តឱ្យបរិសុទ្ធ ដើម្បីរស់នៅដោយសេចក្តីចម្រើនឆ្ពោះដល់សេចក្តីសុខស្ងប់ ។ ធម្មទាន ដែលប្រសើរបំផុត សដ៏បរិសុទ្ធនោះគឺ លោកុត្តរធម្មទាន ពោលគឺ ការឱ្យព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ។ ព្រះពុទ្ធ បានសម្តែងថា "ធម្មទាន ជាទានប្រសើរជាងគេបង្អស់ ជាទានឈ្នះអស់ទានទាំងពួង"។ អ្នកបរិបូណ៌ដោយធម្មទាន ឈ្មោះថា អ្នកឱ្យខ្លួនឯងនូវបញ្ញា និងឱ្យសេចក្តីសុខ សេចក្តីចម្រើនដល់គេ ។ **អភ័យទាន** គឺការឱ្យអភ័យ ការមិនប្រកាន់ទោស ការមិនចាប់កំហុស ការមិនបៀតបៀន ការមិនប្រមាទ ។ អភ័យទាន ចែកចេញជា ៣ ប្រភេទ គឺ *ការលើកលែងទោស* ការមិនប្រកាន់ទោសកំហុស មិនចងគំនុំ មិនសងសឹក មិនព្យាបាទតប មិនចងសេចក្តីក្រោធខឹង ដល់អ្នកដែលបានធ្វើខុសមកលើខ្លួន, *ការមិនបំភ័យ* ការមិនធ្វើឱ្យគេភិតភ័យខុស ការមិនធ្វើឱ្យគេដែលមិនមានកំហុសទទួលក្តីបារម្ភខុសដោយសារខ្លួន និង *ការមិនទម្លាក់កំហុស* ការមិនយកទោសកំហុសរបស់ខ្លួនទៅដាក់បន្ទុកលើគេ ការមិនបៀមឈាមព្រួសដាក់គេ ការមិនយកទោសរបស់មនុស្សម្នាក់ទៅទម្លាក់

ថ្ងៃនេះ ជាថ្ងៃល្អ ពិត

លើមនុស្សម្នាក់ផ្សេងទៀត។ អ្នកឱ្យអភ័យទាន មានឈ្មោះថា អ្នកមានមេត្តា គឺជាអ្នកឱ្យសុខដល់ខ្លួនឯងផង ដល់អ្នកដទៃផង ឬថា អ្នកដែលស្រឡាញ់អ្នកដទៃ ដូចស្រឡាញ់ផងខ្លួនដែរ ។ អ្នកមានមេត្តាធម៌ រមែងសម្រេចបាននូវសម្បត្តិដ៏ប្រសើរក្នុងលោកគឺ សម្បត្តិមនុស្ស និងសម្បត្តិទេវតា។ ប្រភេទទី៤នៃទាន គឺ **សុខទាន** សំដៅដល់ ការឱ្យសេចក្ដីសុខមួយរយៈពេល ការឱ្យការយកចិត្តទុកដាក់មើលថែទាំងកាយ ចិត្ត និងស្មារតី ឧទាហរណ៍ ឪពុកម្ដាយឱ្យសុខទានដល់កូន ដោយការចិញ្ចឹមបីបាច់ ថែរក្សា ថ្នាក់ថ្នម មើលការខុសត្រូវ ផ្ដល់ឱកាសដល់កូនបានសិក្សារៀនសូត្រក្រេបយកវិជ្ជា ។ ទី៥គឺ **ទក្ខិណានុប្បទាន** សូមអានត្រង់ សិក្ខាបទទី៥នៃ "កូនល្អពិត បំពេញសិក្ខាបទ ៥ យ៉ាងចំពោះឪពុកម្ដាយ" នៅទំព័រទី ១១៨ ។

ការឱ្យទាន មានគោលដៅសំខាន់ ៣ យ៉ាង (១)ឱ្យទានដើម្បីលះសេចក្ដីកំណាញ់ផ្ទាល់ខ្លួនផងនិងសន្សំបុណ្យសម្រាប់អនាគតជាតិផង (២)ឱ្យទានដើម្បីជួយសង្គ្រោះអ្នកមានតម្រូវការ និង (៣)ឱ្យទានដើម្បីទទួលទាន ។ ការឱ្យទាន ជាបារមីទី១នៃបារមីទាំង ១០ និង ទាំង ៣០ ដែលជាគុណធម៌របស់មនុស្សខ្ពង់ខ្ពស់គួរបំពេញ ។

ដូច្នេះ កូនល្អពិត ដែលជាកំពូលមនុស្ស តែងនាំឪពុកម្ដាយឱ្យ ពេញចិត្តពេញថ្លើម ធ្វើទានដ៏បរិសុទ្ធដោយឆន្ទៈ ដោយគុណធម៌ និងដោយឧបេក្ខា ជាការសង្គ្រោះលោកទាំងពីរ ឱ្យទទួលបាននូវមហាកុសលដែលជាកំណប់ទ្រព្យដ៏ ប្រសើរបំផុតរបស់លោកទាំងពីរផ្ទាល់ ទាំងសំរាប់ជាតិនេះ និងបរលោក ។

## (៤). កិច្ចនាំឪពុកម្តាយឱ្យមានបញ្ញា

បញ្ញា ប្រែថា សេចក្តីដឹងជាទូទៅ, សេចក្តីដឹងច្បាស់នូវសេចក្តីពិត ។ បញ្ញា មានពីរយ៉ាងៈ លោកិយបញ្ញា គឺចំណេះដឹង, ការដឹងអំពីសង្គម, ការមានសមត្ថភាពខាងឬវិជ្ជាការខាង វិទ្យាសាស្ត្រ សង្គមវិជ្ជា សេដ្ឋកិច្ច នយោបាយ សុខមាលភាពសង្គម ប្រជាធិបតេយ្យ ការបង្កើតអ្វី១ឬការច្នៃប្រឌិតអ្វី១សំរាប់មនុស្សលោកអាស្រ័យប្រើប្រាស់ ។ រីឯ លោកុត្តរបញ្ញា គឺ សេចក្តីដឹងច្បាស់ក្នុងផ្លូវព្រះធម៌ ពោលគឺ យល់ឃើញច្បាស់ក្នុងអរិយសច្ចៈ៤, កុសលកម្មបថ១០និងអកុសលកម្មបថ១០, និង ត្រៃលក្ខណ៍ធម៌ទាំង ៣ ។ កូនល្អ គប្បីនាំឪពុកម្តាយឱ្យមានបញ្ញាក្នុងផ្លូវធម៌ ទើបជាការប្រសើរក្រៃបំផុត ត្បិតពន្លឺព្រះអាទិត្យ ពន្លឺព្រះច័ន្ទ និង ពន្លឺចង្កៀងគង់ភ្លឺមិនស្មើពន្លឺបញ្ញាព្រះធម៌ ។ លោកុត្តរបញ្ញា មាន ២ យ៉ាងគឺ សម្មាទិដ្ឋិ (ការយល់ឃើញត្រូវ) និង សម្មាសង្កប្បៈ (ការគិតត្រិះរិះពិចារណាត្រូវ) ។ កូនល្អប្រកបដោយបញ្ញា ពិតជាយល់ច្បាស់ថា ត្រូវដឹកនាំឪពុកម្តាយឱ្យខំសិក្សាព្រះធម៌ ដោយការចេះ ៤ គឺ **ចេះស្តាប់ចេះអាន** នាំលោកទាំងពីរឱ្យចេះស្រឡាញ់ចូលចិត្តស្តាប់ព្រះធម៌និងអានសៀវភៅធម៌ឱ្យទៅជាទម្លាប់រាល់ៗថ្ងៃ, **ចេះគិតរកហេតុផល** នាំលោកទាំងពីរឱ្យចេះគិតតាមសម្មាទិដ្ឋិដោយការត្រិះរិះក្នុងការចេញចាកកាម ត្រិះរិះក្នុងការមិនព្យាបាទ ត្រិះរិះ

ក្នុងការមិនបៀតបៀន ពិសេសនាំលោកឱ្យធ្វើសមាធិ ចម្រើនភាវនា, **ចេះសួរ** នាំលោកឱ្យចេះបង្កើតសំណួរនិងពិភាក្សាក្នុងព្រះធម៌ ព្រមទាំង **ចេះកត់ចំណាំ** ព្រះធម៌ ។ ព្រះពុទ្ធ បានសម្តែងថា "ម្នាលភិក្ខុទាំងឡាយ **អវិជ្ជា** (គ្មានបញ្ញា) ជាប្រធាននៃអកុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅដើម្បីញ៉ាំង សេចក្តីមិនខ្មាសបាប និង មិនខ្លាចបាប ឱ្យកើតឡើងជាលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ **សេចក្តីយល់ឃើញខុស** រមែងកើតឡើងដល់បុគ្គលល្ងង់ខ្លៅ ប្រកបដោយអវិជ្ជា, **សេចក្តីត្រិះរិះខុស** កើតឡើងដល់បុគ្គលមានសេចក្តីយល់ឃើញខុស, **វាចាខុស** កើតឡើងដល់បុគ្គលមានសេចក្តីត្រិះរិះខុស, **ការងារខុស (ទង្វើខុស)** កើតឡើងដល់បុគ្គលមានវាចាខុស, **ការចិញ្ចឹមជីវិតខុស** កើតឡើងដល់បុគ្គលមានការងារខុស (ទង្វើខុស), **ការព្យាយាមខុស** កើតឡើងដល់បុគ្គលមានការចិញ្ចឹមជីវិតខុស, **ការរឭកខុស** កើតឡើងដល់បុគ្គលមានការព្យាយាមខុស, **ការតាំងចិត្តមាំខុស** កើតឡើងដល់បុគ្គលមានការរឭកខុស" ។ ព្រះអង្គ បន្តសម្តែងថា "ម្នាលភិក្ខុទាំងឡាយ **វិជ្ជា** (បញ្ញា) ជាប្រធាននៃកុសលធម៌ទាំងឡាយ ប្រព្រឹត្តទៅដើម្បីញ៉ាំង សេចក្តីខ្មាសបាប និង សេចក្តីខ្លាចបាប ឱ្យកើតឡើងជាលំដាប់ ។ ម្នាលភិក្ខុទាំងឡាយ **សេចក្តីយល់ឃើញត្រូវ** រមែងកើតឡើងដល់បុគ្គលអ្នកដឹងច្បាស់ប្រកបដោយវិជ្ជា, **សេចក្តីត្រិះរិះត្រូវ** កើតឡើងដល់បុគ្គលមានសេចក្តីយល់

ឃើញត្រូវ, **វាចាត្រូវ** កើតឡើងដល់បុគ្គលមានសេចក្ដីត្រិះរិះត្រូវ, **ការងារត្រូវ (ទង្វើត្រូវ)** កើតឡើងដល់បុគ្គលមានវាចាត្រូវ, **ការចិញ្ចឹមជីវិតត្រូវ** កើតឡើងដល់បុគ្គលមានការងារត្រូវ (ទង្វើត្រូវ), **ការព្យាយាមត្រូវ** កើតឡើងដល់បុគ្គលមានការចិញ្ចឹមជីវិតត្រូវ, **ការរព្ញកត្រូវ** កើតឡើងដល់បុគ្គលមានការព្យាយាមត្រូវ, **ការតាំងចិត្តមាំត្រូវ** កើតឡើងដល់បុគ្គលមានការរព្ញកត្រូវ" ។

តាមពិត, មនុស្សគ្រប់រូប កើតមកសុទ្ធតែមានបញ្ញារួចជាស្រេចនោះបានដល់ **អតីតបញ្ញា** គឺបញ្ញាចាស់ដែលមនុស្សយើងបានកសាងសន្សំពីបុព្វជាតិ ហើយជិតជាប់ជាមួយនឹងវិញ្ញាណថ្មី គឺ ជាតិកំណើតថ្មីហ្នឹងឯង វាគ្រាន់តែខុសគ្នាត្រង់ថា មនុស្សខ្លះមានបញ្ញាច្រើន ខ្លះមានតិច ទៅតាមកម្ម ជាឧបនិស្ស័យរបស់រៀងៗខ្លួនដែលបានសន្សំពីជាតិមុនៗទៀត ។ ទោះខ្លះមានតិចក្ដី ច្រើនក្ដី ចូរយល់ថា អតីតបញ្ញា ជាដើមទុនចាស់យ៉ាងចាំបាច់បំផុត សំរាប់បង្កើតបញ្ញាថ្មី គឺបច្ចុប្បន្នបញ្ញា ដែលលោកអ្នកអានទាំងអស់និងខ្ញុំបាទកំពុងតែសន្សំយ៉ាងឃ្មាតខ្មីរាល់ថ្ងៃនេះ ។ អ្នកមានបញ្ញាតិចពីជាតិមុន ក៏អាចព្យាយាមឱ្យមានបញ្ញាជ្រៅឬច្រើននៅពេលបច្ចុប្បន្នបាន ដូចអ្នកមានបញ្ញាច្រើនពីជាតិមុនអញ្ចឹងដែរ ប៉ុន្តែ ទាំងអ្នកបញ្ញាតិចនិងអ្នកបញ្ញាច្រើនពីជាតិមុន ក៏អាចមានបញ្ញាតិចនៅពេលបច្ចុប្បន្នដែរ ឱ្យតែមិនខំ

ព្យាយាមកសាងបញ្ញាថ្មី ឬ ព្យាយាមខុស ឬ ធ្វេសប្រហែស ។ ចូរលោកអ្នកពិចារណាទៅលើមនុស្សពីរនាក់ ដែលម្នាក់មានលុយតិចបំផុត ហើយម្នាក់ទៀតមានលុយច្រើនលួម ជាលទ្ធផលអ្នកទាំងពីរអាចក្លាយជាមហាសេដ្ឋីដូចគ្នា ឬ អ្នកមានលុយតិចពីមុនអាចមានលុយច្រើននាពេលបច្ចុប្បន្ន រីឯអ្នកមានលុយច្រើនពីមុនអាចធ្លាក់មកមានតិចវិញនាពេលបច្ចុប្បន្ន ឬ...។ បញ្ញាមួយដំណាក់កាលទៀត បានដល់ **បច្ចុប្បន្នបញ្ញា** ដែលយើងទាំងអស់គ្នាកំពុងប្រឹងប្រែងសន្សំទាំងយប់ទាំងថ្ងៃ ដោយការព្យាយាមត្រូវ ខ្ញុំបាទសូមមិនធ្វើការបកស្រាយបន្ថែមទេ ព្រោះបានកំពុងនឹងបកស្រាយច្រើនហើយ ។ នៅមានបញ្ញាមួយប្រភេទទៀត បានដល់ **អនាគតបញ្ញា** ដែលបច្ចុប្បន្នបញ្ញា បង្កើតសំរាប់បញ្ញានៅក្នុងអនាគតជាតិ ។

ព្រះពុទ្ធ បានសម្ដែងថា "ធម៌ ៤ ប្រការ ប្រព្រឹត្តទៅដើម្បីចំរើនបញ្ញាគឺ (១) ការសេពគប់សប្បុរស (២) ការស្ដាប់ធម៌របស់សប្បុរស (៣) យកចិត្តទុកដាក់ដោយឧបាយ (៤) ប្រតិបត្តិធម៌ដ៏សមគួរតាមកាល ។

ដូចនេះ បញ្ញា ជាគុណជាតិនាំដល់សេចក្ដីសម្រេចជោគជ័យលើក្ដីប្រាថ្នា គឺសេចក្ដីសុខក្នុងសម្បត្តិមនុស្ស សេចក្ដីសុខក្នុងសម្បត្តិទេវតា និងសេចក្ដីសុខស្ងប់ក្នុងសម្បត្តិព្រះនិព្វាន ។

តើកូនដែលមានសមត្ថភាព ញុំាងឪពុកម្ដាយមិនទាន់មានបញ្ញាឱ្យមានបញ្ញា នឹងទទួលបានអានិសង្សវិសេសវិសាលប៉ុណ្ណា ?

## (៥). កិច្ចបំពេញបុណ្យជូនឪពុកម្ដាយ

បុណ្យ ប្រែថា សេចក្ដីល្អ, កុសលកម្ម, សេចក្ដីសុខ, ឬ គុណធម៌ជម្រះកាយវាចាចិត្តឱ្យល្អ ។ បុណ្យ ជាអំពើល្អដែលផ្ដល់ប្រយោជន៍ដល់ទាំងអ្នកធ្វើ និងអ្នកទទួល បើធ្វើល្អតាមផ្លូវកាយ ហៅថា កាយសុចរិត បើធ្វើល្អតាមផ្លូវវាចា ហៅថា វចីសុចរិត ហើយ បើធ្វើបុណ្យតាមផ្លូវចិត្ត ហៅថា មនោសុចរិត ។ ផ្ទុយពីនេះ បាបជាអំពើអាក្រក់ដែលផ្ដល់នូវវិបត្តិ ឬ ផលអាក្រក់ដល់អ្នកធ្វើ ឬ អ្នកទទួល ឬ វិបត្តិនេះកើតឡើងចំពោះទាំងអ្នកធ្វើនិងអ្នកទទួល។ មនុស្សសាងបុណ្យតែងមានលក្ខណៈសំគាល់បានដោយខ្លួនឯង តាម ៣ ដំណាក់កាល **ទី១ ដំណាក់កាលមុនសាងបុណ្យ** អ្នកសាងរមែងរីករាយក្នុងចិត្ត **ទី២ ដំណាក់កាលកំពុងសាង** អ្នកសាងរមែងមានចិត្តជ្រះថ្លាក្នុងអំពើបុណ្យ និង **ទី៣ ដំណាក់កាលក្រោយសាង** អ្នកសាងរមែងទទួលបានសេចក្ដីសុខ-សេចក្ដីចម្រើន ដែលដំណាក់កាលទី១ និង ទី២ ត្រូវប្រកបដោយ អង្គ ៣ គឺ សាងដោយមាន ឆន្ទៈ (ចេតនានៃចិត្ត), បញ្ញា (សេចក្ដីយល់ច្បាស់ក្នុងសភាវធម៌ ហើយសាងបុណ្យដោយមិនឱ្យមានផលអាក្រក់ដល់ភាគីណាមួយ), និង ឧបេក្ខា (ធ្វើបុណ្យដោយមិនអគតិ គឺមិនលំអៀង) ។ ផ្ទុយពីនេះ អ្នកសាងអំពើបាប ក៏អាចសំគាល់ដោយខ្លួនឯងបានតាម ៣ ដំណាក់កាលដូចគ្នា **ទី១ ដំណាក់កាលមុនសាង**

អ្នកសាងបាបរមែងមានកង្វល់ក្នុងចិត្ត **ទី២ ដំណាក់កាលកំពុងសាងបាប** អ្នកសាងរមែងមានភ័យ និង **ទី៣ ដំណាក់កាលក្រោយសាងបាប** អ្នកសាងរមែងទទួលទុក្ខ-សេចក្ដីក្ដៅក្រហាយ ដែលអ្នកសាងបាបរមែងប្រកបដោយ ឆន្ទៈ (មានបំណងសាងបាប), សេចក្ដីល្ងង់ខ្លៅ (មិនជឿកម្ម-ផល), និង គ្មានមេត្តា-ករុណា (មិនស្រឡាញ់អាណិតអាសូរខ្លួនឯងពិត មិនគោរពគេ) ។ ដូច្នេះ **សាងបុណ្យ នាំមកនូវសុខ, សាងបាប នាំមកនូវទុក្ខ** ។

កូនល្អពិត គប្បីសាងបុណ្យជូនឪពុកម្ដាយ តាម ២ ដំណាក់កាល គឺ សាងបុណ្យជូនលោកទាំងពីរនៅពេលលោកនៅមានជីវិត និង សាងបុណ្យជូនលោកទាំងពីរនៅពេលលោកបានធ្វើមរណកាលទៅកាន់លោកខាងមុខ។ ចូរកូនប្រុសស្រីទាំងឡាយចងចាំថា កាលធ្វើបុណ្យ ត្រូវឧទ្ទិសបួងសួងបញ្ជូនបុណ្យដែលបានសាងទាំងឡាយនេះដល់ឪពុកម្ដាយ ឬ ញាតិទាំង ៧ សន្ដានផង ហើយត្រូវប្រាថ្នាសូមឱ្យបានប្រយោជន៍ដល់ខ្លួនឯងផងគឺ នឹងបានជួបព្រះពុទ្ធ ព្រះធម៌ ព្រះអរិយសង្ឃ និងសូមឱ្យមានបញ្ញាក្នុងព្រះធម៌ដើម្បីសម្រេចមគ្គផលផ្សេងៗ រហូតរួចចាកទុក្ខទោសទាំងពួង ។ អំពើជាបុណ្យដែលកូនល្អតែងធ្វើ ជូនកុសលដល់ឪពុកម្ដាយ មានដូចជា :

- ពិធីចម្រើនព្រះជន្ម ជូនព្រះរស់
- ពិធីស្រង់ព្រះរស់

- ពិធីសង្ឃទាន
- ពិធីបរិច្ចាគទាន
- និមន្តព្រះសង្ឃឬអញ្ជើញសប្បុរសសម្ដែងធម្មទេសនាជូនលោកទាំងពីរស្ដាប់ រួមទាំងញាតិជិតខាង
- និមន្តព្រះសង្ឃឆាន់
- ពិធីរាប់បាត្រ
- បុណ្យឈាបនកិច្ច
- បុណ្យទក្ខិណានុប្បទាន
- បុណ្យខួបមរណភាព (១ សប្ដាហ៏, ១០០ ថ្ងៃ, ១ ឆ្នាំ,....)
- ។ល។

---

"បុណ្យ ជានិរន្តរទ្រព្យប្រសើរជាងទ្រព្យទាំងពួងក្នុងលោក គួរខំសន្សំ ។"
"បុណ្យ ជាឱសថទិព្វ ព្យាបាលរោគកាយចិត្ត ប្រសើរជាងឱសថដទៃ ។"
"បុណ្យ ជាអំពើនាំសន្តិភាព នាំភាតរភាពក្នុងគ្រួសារនិងសង្គម ។"
"បុណ្យ ជាជម្រកសុខ ប្រសើរជាងជម្រកដទៃក្នុងលោក ។"
"បុណ្យ ជាមាគ៌ាឆ្ពោះទៅកាន់ព្រះនិព្វាន ។"

*ស៊ាន វិត*

---

## បុញ្ញកិរិយាវត្ថុ ១០ យ៉ាង :

ក្នុងព្រះពុទ្ធសាសនា អំពើបុណ្យ កើតឡើងតាមកិរិយា ១០ យ៉ាង :

(១). ការបរិច្ចាគទាន

(២). ការរក្សាសីល

(៣). ការចម្រើនភាវនា

(៤). ការគោរពកោតក្រែង

(៥). ការជួយខ្វល់ខ្វាយ ការបម្រើ

(៦). ការជូនចំណែកបុណ្យដល់គ្នា

(៧). ការអនុមោទនាចំណែកបុណ្យ (ដែលអ្នកដទៃជូន)

(៨). ការស្ដាប់ធម៌

(៩). ការសម្ដែងធម៌

(១០). ការត្រិះរិះពិចារណាត្រូវ (សម្មាទិដ្ឋិ) ។

---

ព្រះពុទ្ធ មានពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំខ្លាចបុណ្យឡើយ ព្រោះពាក្យថាបុណ្យនេះ ជាឈ្មោះនៃសេចក្ដីសុខ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីស្រឡាញ់ ជាទីពេញចិត្ត ។ បុគ្គលក្នុងលោកនេះ ជាអ្នកស្ដាប់តិច មិនបានធ្វើបុណ្យ តម្កល់ចិត្តខុស ពោលវាចាខុស ធ្វើការងារខុសដោយកាយ បុគ្គលនោះជាអ្នកឥតប្រាជ្ញ លុះបែកធ្លាយរាងកាយស្លាប់ទៅ ព្រោះជីវិតមនុស្សក្នុងលោកនេះតិចណាស់ រមែងកើតនៅក្នុងនរក" ។

---

## បុណ្យមានអានិសង្ស ៥ យ៉ាង :

កូនល្អដែលខំសន្សំបុណ្យ តែងទទួលបានផលានិសង្ស ៥ យ៉ាង :

(១). មានប្រាជ្ញាក្លៀវក្លាមោះមុត

(២). មានពណ៌សម្បុរល្អ

(៣). មានរូបល្អ

(៤). មានទ្រង់ទ្រាយល្អ

(៥). នឹងបានទៅជាស្ដេចចក្រពត្តិ (ឬ មេដឹកនាំ) ក្នុងជាតិណា១ពុំខានឡើយ ។

ជាបញ្ចប់នេះ កូនដែលបានធ្វើធម្មកិច្ចទាំង ៥ នេះ ដោយប្រពៃហើយ កូននោះមានឈ្មោះថា ជាកូនកតញ្ញូប្រកបដោយកតវេទិតាធម៌ពិតហៅថា កូនកតញ្ញូកតវេទី ជាកូនបានសង្គ្រោះឪពុកម្ដាយយ៉ាងពិតប្រាកដព្រោះធម៌ទាំង ៥ នេះ មាននៅក្នុងបុគ្គលណាហើយ រមែងញុំាងបុគ្គលនោះឱ្យឆ្លងផុតទុក្ខទាំងពួងបាន និង ជៀសផុតពីអបាយភូមិគឺឋានថោកទាប ហើយនឹងបានសុទ្ធតែ សេចក្ដីសុខ ហៅថា ឯកន្តសុខ ឬ ឯកន្តបរមសុខ ដល់នូវព្រះនិព្វាន ជាទីសុខស្ងប់ រលត់ទុក្ខតូចធំគ្មានសេសសល់ឡើយ ។

*សូមឱ្យលោកអ្នកអានទាំងឡាយ លំអជីវិតដោយការសន្សំបុណ្យ ទើបជាការសន្សំទ្រព្យជាប់ខ្លួនពិតប្រាកដសម្រាប់ជាតិនេះ និងបរលោក !*

## ៣. សមត្ថភាព ៣ យ៉ាងនៃកូនល្អពិតដើម្បីសម្រេច គោលបំណងពិតរបស់ឪពុកម្តាយ

សូមលោកអ្នកអាន បន្តសិក្សាស្វែងយល់ឱ្យបានជាក់ច្បាស់នូវសមត្ថភាពទាំង ៣ នេះ ក្នុង "ផ្នែកទី៣" នៅទំព័របន្ទាប់នៃសៀវភៅនេះ ។

សមត្ថភាព ៣ យ៉ាងនៃកូនល្អពិតក្នុងការសម្រេចគោលបំណងពិតរបស់ឪពុកមាន :

- កូនល្អមានសមត្ថភាពបំពេញ "តួនាទីជាកូនល្អពិត"
- កូនល្អមានសមត្ថភាពកសាង "អនាគតល្អពិត"
- កូនល្អមានសមត្ថភាពធ្វើជា "មនុស្សល្អពិត"

សម្បត្តិទ្រព្យ

និង

សម្បត្តិសុខ

ទាំងអស់

មាននៅក្នុង

កូនល្អ

ចូរ

អាន ច្រើនដង

ហើយ

គិត ច្រើនដង

ហើយ

ធ្វើ ច្រើនដង

*ស៊ាន វិត*

## ផ្នែកទី ៣

# សមត្ថភាព ៣ យ៉ាង នៃកូនល្អពិត ដើម្បីសម្រេច បំណងពិតរបស់ឪពុកម្តាយ

"មានសមត្ថភាពសម្រេចបំណងពិតរបស់ឪពុកម្តាយ
ប្រសើរជាង មានសម្បត្តិលោកីយ៍ ។"

*ស៊ាន វិត*



តាមព្រះពុទ្ធឱវាទៈ "ឥទ្ធិបាទ ៤ ជាធម៌ញ៉ាំងឱ្យសម្រេចគ្រប់កិច្ចការតូចធំ ក្នុងផ្លូវលោកនិងផ្លូវធម៌គឺ ឆន្ទៈ ១, វីរយៈ ១, ចិត្តៈ ១, និងវិមំសា ១" ។

# ផ្នែកទី៣ : សមត្ថភាព ៣ យ៉ាងនៃកូនល្អពិត ដើម្បីសម្រេចបំណងពិតរបស់ឪពុកម្តាយ

ឪពុកម្តាយមាន ២ ប្រភេទ គឺឪពុកម្តាយប្រកបដោយបញ្ញា និងឪពុកម្តាយប្រកបដោយអវិជ្ជា ។ នាពេលបច្ចុប្បន្ននេះ ឪពុកម្តាយប្រកបដោយបញ្ញា រកបានដោយកម្រ មានច្រើនបំផុតតែឪពុកម្តាយដែលខ្វះនូវសេចក្តីយល់ដឹងច្បាស់អំពីសច្ចៈនៃជីវិត ហេតុដូច្នេះហើយ ពួកគាត់មិនយល់ឃើញត្រូវអំពីដូចជា តម្លៃនៃជីវិត គោលបំណងពិតរបស់ពួកគាត់ គោលបំណងរបស់កូនៗ សីលធម៌នៃជីវិត វិធីអប់រំកូនឱ្យល្អពិត ជាដើម ។

បើទោះជាឪពុកម្តាយខ្លះមានបញ្ញាក្នុងផ្លូវលោកផងនិងផ្លូវធម៌ផង ហើយឪពុកម្តាយខ្លះទៀតមានសេចក្តីល្ងង់ខ្លៅក៏ដោយ ក៏លោកទាំងពីរប្រភេទនេះ មានបំណងពិតដូចគ្នាចំពោះកូនគ្រប់រូប។ កាលបើកូនណាបានសម្រេចបំណងពិតទាំង ៣ របស់ឪពុកម្តាយហើយ កូននោះឈ្មោះថាកូនដ៏ឧត្តុងឧត្តម ជាអរិយបុគ្គល១រូប ព្រោះបានបំពេញកិច្ចដែលនាំឱ្យខ្លួនប្រសើរខ្ពង់ខ្ពស់ វិសេសវិសាលបំផុត ។ បំណងពិតទាំង ៣ នោះមាន :

ក. កូនល្អមានសមត្ថភាពបំពេញ "តួនាទីជាកូនល្អពិត"

ខ. កូនល្អមានមានសមត្ថភាពកសាង "អនាគតល្អពិត"

គ. កូនល្អមានសមត្ថភាពធ្វើជា "មនុស្សល្អពិត"

## ក. កូនល្អមានសមត្ថភាពបំពេញ "តួនាទីជាកូនល្អពិត"

ឪពុកម្ដាយ ជាព្រះរបស់កូន ព្រោះលោក (១)បានបង្កើតកូនឱ្យមានជីវិតក្នុងលោកិយ ដើម្បីមានឱកាសកសាងជីវិតឱ្យល្អប្រសើរតទៅអនាគតជាតិ (២)**ចិញ្ចឹមកូនបាន ២០ ឆ្នាំប្លាយ ឬ លើសពីនេះ** និង (៣)**រៀបចំអនាគតល្អឱ្យកូន** ។ តើមានកូនណា អាចបំពេញតបចំនុច ៣ ខាងលើនេះបាន? ព្រោះតែគ្មានកូនណាអាចបំពេញតបគុណទាំង ៣ ខាងលើរបស់ឪពុកម្ដាយបាន ទើបបានជាមិនអាចសងគុណលោកឱ្យអស់បាន ។ ក្នុងចំនុច ១ ខាងលើ គ្មានកូនណាអាចបង្កើតជីវិតឪពុកម្ដាយឱ្យរស់បានវិញឡើយក្រោយពីលោកធ្វើមរណកាលទៅបាត់. មានកូនតិចណាស់ កម្រមានណាស់ ដែលកូនអាចចិញ្ចឹមឪពុកម្ដាយ ឱ្យរស់នៅដោយស្រណុកកាយចិត្ត ដូចដែលលោកបានចិញ្ចឹមកូននោះដែរ ។ កូនខ្លះថែមទាំងមិនបានចិញ្ចឹមលោកទាំងពីរផង ខ្លះទៀតបានចិញ្ចឹមលោកតែ ១-៣ឆ្នាំ ខ្លះទៀតបានចិញ្ចឹមលោក ៤-១០ឆ្នាំ តែដោយសេចក្ដីប្រមាទគុណរបស់លោកដោយកាយវាចាចិត្តទៀតផង ។ កម្រមានកូនដែលបានចិញ្ចឹមលោកដល់ ៤ឆ្នាំ ១០ឆ្នាំ ២០ឆ្នាំ ដោយបញ្ញា ដោយកាយវាចាចិត្តសុចរិត ។ សព្វថ្ងៃកូនច្រើនតែយកលុយជាធំ និងជះលើគុណរបស់លោកទាំងពីរទៅវិញ ។

កូនដែលអាចបំពេញតួនាទីជាកូនល្អពិតបាន លុះត្រាតែកូននោះមានទាំងសមត្ថភាពក្នុងផ្លូវលោក និងសមត្ថភាពក្នុងផ្លូវធម៌ បើនិយាយឱ្យងាយយល់ជាងនេះ សំដៅដល់ អតិជាតបុត្រ ឬ អនុជាតបុត្រ ប៉ុណ្ណោះ ដែលមានសមត្ថភាពទាំងនេះបាន។ (សូមអានទំព័រក្នុងសេចក្តីផ្តើមឡើងវិញ បើលោកអ្នកភ្លេចនូវគុណសម្បត្តិនៃ អតិជាតបុត្រ និង អនុជាតបុត្រ ។

ព្រះសម្មាសម្ពុទ្ធ បានត្រាស់សម្តែងហើយថា មានតែការតបស្នងសងគុណទេ ទើបជាគុណធម៌ញ៉ាំងកូនប្រុសស្រីទាំងឡាយ និង មនុស្សទាំងឡាយដែលចេះខំតបគុណដល់មនុស្សមានឧបការគុណ ឱ្យជួបសេចក្តីសុខពិត និង សេចក្តីរុងរឿងរីកចម្រើនប្រកបដោយសុភមង្គលពិត ។

"តួនាទីជាកូនល្អពិត" មាន ៣ ប្រការ :

[១]. កូនល្អពិតបំពេញ "សិក្ខាបទ ៥ ចំពោះឪពុកម្តាយ"

[២]. កូនល្អពិតបំពេញ "សិក្ខាបទ ៤ ចំពោះបងប្អូនបង្កើត"

[៣]. កូនល្អពិតបំពេញ "សិក្ខាបទ ៥ ចំពោះញាតិមិត្ត"

---

ម៉ែឪល្ងង់ហើយទីទាល់ក្រ | តែលោកស្មោះស ចំពោះកូន
ចិញ្ចឹមកូនបួនដប់មិនសួន្យ | ខុសអីកូនៗ ធ្វើមិនបាន ។

*ស៊ាន វិត*

---

## [១]. កូនល្អពិតបំពេញ "សិក្ខាបទ ៥ ចំពោះឪពុកម្ដាយ"

សិក្ខាបទ ប្រែថា សីល ឬ វិន័យ ដែលត្រូវខំប្រតិបត្តិ ដើម្បីបាននូវប្រយោជន៍ និងដើម្បីចៀសពីសេចក្ដីវិនាសទាំងឡាយទាំងពួង ។ "សិក្ខាបទ ៥ ចំពោះឪពុកម្ដាយ" សំដៅដល់ សីល ៥ ឬ វិន័យ ៥ ដែលកូនល្អត្រូវខិតខំព្យាយាមប្រតិបត្តិដោយផ្ទាល់ចំពោះព្រះមានគុណទាំងពីរ ដើម្បីតបស្នងសងគុណលោក និងដើម្បីទទួលបានផលានិសង្សពីការបំពេញបុណ្យទាំង ៥ យ៉ាងនេះ សំរាប់ខ្លួននៅពេលបច្ចុប្បន្នកាល និងអនាគតជាតិ ។ កូនដែលមិនភ្លេចនូវមហាគុណទាំង ៣ មាន អជ្ឈិគុណ វិសេសគុណ និងគុណូបការគុណ ដែលលោកបានឱ្យ ហើយឃ្នាតខ្ចីធ្វើតបគុណវិញ ឈ្មោះថា **កូនកតញ្ញូកតវេទី** ដែលព្រះពុទ្ធ ត្រាស់សម្ដែងថា ជាកូនដែលមានដោយកម្រក្នុងលោក ព្រះអង្គ បានលើកសិក្ខាបទទាំង ៥ នោះដូចខាងក្រោម :

- កូនល្អ ត្រូវចិញ្ចឹមមាតាបិតាវិញ
- កូនល្អ ត្រូវជួយធ្វើការងាររបស់មាតាបិតា
- កូនល្អ ត្រូវលើកតម្កើងវង្សត្រកូលឱ្យល្អ
- កូនល្អ ត្រូវទទួលទ្រព្យមរតកដោយបដិបត្តិឱ្យសមគួរ
- កូនល្អ ត្រូវធ្វើបុណ្យឧទ្ទិសទក្ខិណាទានជូនមាតាបិតា

## សិក្ខាបទទី១: កូនល្អ ត្រូវចិញ្ចឹមមាតាបិតាវិញ

ឪពុកម្ដាយ បានលះបង់ឈាម ៣ ប្រភេទ ដើម្បីចិញ្ចឹមកូនឱ្យរស់រានមានជីវិត ដែលជាឱកាសដ៏វិសេសវិសាលជាងគេបំផុតក្នុងលោក ដើម្បីកូនកសាងខ្លួនឱ្យកាន់តែប្រសើរឡើងក្នុងភពមនុស្សលោក ហើយរហូតសម្រេចដល់ទេវលោក និង ព្រះនិព្វាន ដែលខុសពីសត្វតិរច្ឆានមិនអាចមានសតិសម្បជញ្ញៈសម្រេចនូវសម្បត្តិទាំង ៣ បានដូចមនុស្សឡើយ ។ ឈាមទាំង ៣ ប្រភេទនោះមាន *(១) ទឹកដោះម្ដាយ* គឺជាឈាមស្រស់ជាទឹកអម្រិតដ៏ស័ក្តិសិទ្ធ ជាអាហារទិព្វដំបូងតែ១គត់ សំរាប់សង្គ្រោះ និងចិញ្ចឹមជីវិតកូនឱ្យធំធាត់ ដែលឈាមស្រស់នេះ បានមកពីការបំលែងនៃឈាមនិងសារធាតុនានាក្នុងកាយម្ដាយតាមច្បាប់ធម្មជាតិ ។ *(២) ញើសស្រស់* គឺសាច់ស្រស់ ដែលឪពុកម្ដាយលះបង់ដោយសេចក្តីស្មោះស ពួកគាត់ខិតខំធ្វើការងារទាំងយប់ថ្ងៃ មិនគិតឈឺ-ជា ហត់ហេវ ភ្លៀងផ្គរ បែកដៃបែកជើង រួមទាំងត្រូវគេជេរស្ដីបន្ទោស ក៏លោកអត់ធ្មត់ដើម្បីកូន សូម្បីប្រឈមនឹងការបាត់បង់ជីវិត ក៏លោកមិនខ្លាចមិនតក់ស្លុតដែរ ដើម្បីរកប្រាក់យកមកចិញ្ចឹមផ្គត់ផ្គង់កូន ដើម្បីកសាងកេរ្តិ៍ឈ្មោះគ្រួសារឱ្យល្អថ្លៃថ្នូរក្នុងសង្គម ដើម្បីដោះស្រាយវិបត្តិព្រមទាំងតម្រូវការនានាក្នុងគ្រួសារ ។ *(៣) ទឹកមាត់ស្រស់* គឺឱវាទអប់រំប្រៀនប្រដៅ ការទូន្មាន បង្រៀនកូន ឱ្យ

មានចំណេះចេះដឹងជ្រៅជ្រះ ដើម្បីជាដើមទុនក្នុងការងារចិញ្ចឹមជីវិតនៅថ្ងៃមុខ ជាពិសេសលោកអប់រំកូនឱ្យជាមនុស្សល្អ រក្សាគោលការណ៍ជាមនុស្សទៀងត្រង់ សុចរិតដោយកាយ វាចា និងចិត្ត ។ លោកទាំងពីរ តែងមានបំណងប្រដៅកូនឱ្យល្អ មានគំនិតល្អ អត្តចរិតល្អ ការងារល្អ ។

កូនល្អពិត គប្បីចិញ្ចឹមឪពុកម្តាយដោយប្រពៃ នូវកត្តា ២ ផ្នែកគឺ ចិញ្ចឹមកាយ និងចិញ្ចឹមចិត្តរបស់លោក ដែលទាំងពីរនេះមានទំនាក់ទំនងគ្នាបំផុត :

- កូនល្អពិត ត្រូវ**ចិញ្ចឹមកាយ**របស់ឪពុកម្តាយ
- កូនល្អពិត ត្រូវ**ចិញ្ចឹមចិត្ត**របស់ឪពុកម្តាយ

កូនល្អពិត ត្រូវចិញ្ចឹមកាយ របស់ឪពុកម្តាយ ដោយ :

- ឧស្សាហ៍ធ្វើកិច្ចការផ្ទាល់ខ្លួនឱ្យបានល្អ ដូចជា រៀបចំបន្ទប់ដេក បោកសំអាតសំលៀកបំពាក់ រៀបចំទុកដាក់សៀវភៅនិងសម្ភារនិងបន្ទប់សិក្សាឱ្យមានរបៀបរៀបរយល្អ រៀបចំបន្ទប់ញ៉ាំបាយនិងលាងសំអាតចានស្លាបព្រា..ដើម្បីកុំឱ្យលោកទាំងពីរលំបាកកាយដោយសារធ្វើកិច្ចការទាំងនេះឱ្យកូន ។

- ឧស្សាហ៍ក្នុងកិច្ចការយកអាសាបងប្អូនប្រុសស្រីនិងញាតិក្នុងផ្ទះ ដែលមានទុក្ខធុរៈត្រូវការអ្នកមកជួយក្នុងគ្រាចាំបាច់ ព្រោះនេះក៏ជាចំណែកនៃកិច្ចការរបស់លោកដែរ ។
- ជូនឪពុកម្ដាយនូវបច្ច័យ៤ ឬ ចតុបច្ច័យមាន *ចីវរបច្ច័យ* គឺគ្រឿងស្លៀកដណ្ដប់ ដូចជា សំលៀកបំពាក់ មុង ភួយ ក្រមា ក្រណាត់ជូតដៃជើង, *បិណ្ឌបាតបច្ច័យ* គឺម្ហូបអាហារ ទឹក ភេសជ្ជៈ លុយ, *សេនាសនបច្ច័យ* គឺកន្លែងស្នាក់អាស្រ័យនៅ កន្លែងសម្រាកសម្រាន្ត កៅអី គ្រែ, និង *គិលានភេសជ្ជបច្ច័យ* គឺថ្នាំរំងាប់ជំងឺ ឱសថកែរោគ ប្រេងខ្យល់ ប្រេកូឡា កៅអៀក មិនឱ្យលោកទាំងពីរខ្វះប្រើប្រាស់ឡើយ ។ កូនល្អ ត្រូវពិនិត្យមើលជាប្រចាំថ្ងៃ ឬ ប្រចាំសប្ដាហ៍ ឬ ប្រចាំខែ ក្រែងលោពួកគាត់ខ្វះនៅគ្រាណាមួយ ពិសេសត្រូវជូនលុយដល់ពួកគាត់ជាប្រចាំដើម្បីលោកទាំងពីរប្រើប្រាស់តាមតម្រូវការផ្ទាល់ខ្លួន ។
- ជូនពេលវេលានិងការសំរាកកាយចិត្តពីការងារដល់ព្រះរស់ គឺកូនល្អ ត្រូវមានលទ្ធភាពចិញ្ចឹមលោកទាំងពីរវិញដោយមិនឱ្យពួកគាត់បន្តធ្វើការរកលុយតទៅទៀត ពេលដែលពួកគាត់ឈានចូលដល់បច្ឆិមវ័យ ។

- កូនល្អ មិនត្រូវឱ្យព្រះរស់មើលថៃទាំចៅឡើយ ព្រោះធ្វើឱ្យលោកទាំងពីរហត់នឿយកាយ ហើយកើតទោសៈ គឺខឹងក្រោធ និងសេចក្ដីប្រកាន់មាំក្នុងចិត្តសន្ដាន ដែលមិនញ៉ាំងឱ្យពួកគាត់សុខកាយ និងសុខចិត្តសោះឡើយ ។
- កូនល្អ ត្រូវតប់ធ្វើសរសៃ យកទឹកក្ដៅឧណ្ហៗមកត្រាំជើងជូនលោករួចម៉ាស្សាជូនផង ដោយភាពប៉ិនប្រសប់និងយកចិត្តទុកដាក់ ។



កូនល្អពិត ត្រូវចិញ្ចឹមចិត្ត របស់ឪពុកម្ដាយដោយ :

- កូនល្អ ត្រូវនាំឪពុកម្ដាយដែលមិនទាន់មាន សទ្ធា សីល ចាគៈ បញ្ញា និង បុណ្យ ឱ្យមានដោយកាយសុចរិត វាចាសុចរិត និង ចិត្តសុចរិត បើលោកទាំងពីរមានធម្មកិច្ចទាំង ៥ នេះហើយ តែមិនទាន់បរិសុទ្ធ គប្បីកូនល្អរកមធ្យោបាយសមរម្យដែលអាចញ៉ាំងលោក ឱ្យប្រសើរឡើងៗរហូតដល់មានកុសលធម៌ទាំងនេះដ៏បរិសុទ្ធ ។ (សូមលោកអ្នកអានសិក្សាឡើងវិញនៃចំនុចនេះ ត្រង់ "ធម្មកិច្ច ៥ យ៉ាងនៃកូនល្អពិតរបស់ឪពុកម្ដាយ" នៅទំព័រខាងដើម ដើម្បីចងចាំនិងយល់ចំនុចនេះ ឱ្យបានកាន់តែច្បាស់ឡើង) ។

## សិក្ខាបទទី២: កូនល្អ ត្រូវជួយធ្វើការងាររបស់ព្រះរស់

កិច្ចការដែលកូនល្អគប្បីបម្រើ គប្បីរំលែកពីព្រះទាំងពីរ មាន :

- កិច្ចការផ្ទាល់ខ្លួនរបស់ព្រះទាំងពីរ ដូចជា បោកសំលៀក បំពាក់សំអាតទ្រនាប់ជើងជូនលោក រៀបចំសំអាតបន្ទប់សម្រាន្តរបស់លោក កាត់ក្រចកដៃក្រចកជើងជូនលោក...។
- កិច្ចការក្នុងមុខនាទីក្នុងការងាររបស់ព្រះទាំងពីរ ដោយចេះទៅជម្រាបសុំការងារធ្វើពីលោក "ពុកម៉ែ, តើមានការងារអ្វីឱ្យកូនបម្រើ/ធ្វើជូនទេ?" បើមិនចេះធ្វើការងារដែលលោកដាក់ឱ្យធ្វើ កូនល្អត្រូវចេះជំរាបសួរពីវិធីធ្វើ កុំធ្វើទាំងល្ងីល្ងើ "ពុក, សូមពុកមានប្រសាសន៍ប្រាប់កូនពីរបៀបធ្វើកិច្ចការនេះផង កូនមិនសូវយល់ច្បាស់ពីរបៀបធ្វើវាទេ?" បើធ្វើទៅមានកំហុស កូនល្អត្រូវស្មោះត្រង់ កុំលាក់បាំងកំហុសនាំកើតជាចរិតអាក្រក់ខូចកេរ្តិ៍ឈ្មោះល្អ ដោយសំពះសារភាពទោសកំហុស (ឬលុតជង្គង់ថ្វាយបង្គំសុំទោស) ហើយសុំឱ្យពុកម៉ែអភ័យទោស ដោយបណ្ដាលមកពីការប្រហែស ហើយត្រូវសុំការអប់រំបន្ថែមពីលោក និងប្រុងប្រយ័ត្នប្រឹងធ្វើកុំឱ្យខុសជាលើកទីពីរឱ្យសោះ ។

- កិច្ចការគ្រប់គ្រងផ្ទះ ដូចជា កិច្ចការសុវត្ថិភាពផ្ទះ កិច្ចការផ្គត់ផ្គង់ទឹកនិងអគ្គិសនី កិច្ចការមើលថែដាំដំណាំហូបផ្លែឬច្បារដំណាំ កិច្ចការលំអផ្ទះ កិច្ចការបង់លុយទឹកភ្លើង កិច្ចការផ្គត់ផ្គង់សម្ភារនិងឧបករណ៍ចាំបាច់ប្រើប្រាស់ក្នុងផ្ទះ កិច្ចការដោះស្រាយបញ្ហាក្នុងគ្រួសារ ជាដើម ។
- ធ្វើទង្វើវាងវៃទាំងឡាយដែលនាំឱ្យលោកបានសប្បាយចិត្ត កូនល្អ រមែងជាកូនឆ្លាតវៃ ចេះលេងសម្ដី ឬ ប្រលែងលេង ឬ ល្បែងល្បងប្រាជ្ញា ដើម្បីបង្កើតបរិយាកាសរីករាយចំពោះមុខលោកទាំងពីរ ត្រូវចៀសវាងកិរិយាប្រមាទទាំងឡាយ ។

កូនល្អ រមែងជៀសឆ្ងាយពីសេចក្ដីខ្ជិលច្រអូស ត្រូវខិតខំព្យាយាមធ្វើកិច្ចការងារសំខាន់ៗទាំងឡាយ សម្ដែងនូវសេចក្ដីល្អ របស់ខ្លួនផង ដើម្បីរៀនសូត្រដកពិសោធន៍ពីការងារទាំងនោះផង ដើម្បីបម្រើឬជួយយកអាសាបងប្អូនសាច់ញាតិនិងតបគុណព្រះទាំងពីរផង ។ "សេចក្ដីខ្ជិលច្រអូស ជាឫសគល់នៃអំពើអាក្រក់ទាំងឡាយទាំងពួង រមែងនាំមកនូវបរាជ័យក្នុងជីវិត សេចក្ដីវិនាស ការធ្លាក់ខ្លួនតិះដៀល ការម្រាថមើលងាយ ការមិនរាប់អាន ពីមនុស្សល្អទាំងជិតឆ្ងាយ" រីឯ "សេចក្ដីឧស្សាហ៍ព្យាយាម ជាពន្លកនៃអំពើល្អ រមែងនាំមកនូវជោគជ័យក្នុងជីវិត សេចក្ដីគោរពស្រឡាញ់រាប់អាន ការគាំទ្រ និងសេចក្ដីសុខ សេចក្ដីចម្រើន" ។

## សិក្ខាបទទី៣: កូនល្អ ត្រូវលើកតម្កើងវង្សត្រកូលឱ្យល្អ

កិច្ចប្រតិបត្តិល្អទី៣ ដែលកូនល្អត្រូវធ្វើឱ្យបាននោះ គឺលើកតម្កើងវង្សត្រកូលឱ្យថ្លៃថ្នូរ ដោយកិច្ចប្រតិបត្តិ ៤ យ៉ាង :

- កូនល្អ រក្សាកល្យាណធម៌ ៥ និងរក្សាសីល ៥ ឬ សីល ៨ : វង្សត្រកូលថ្កុំថ្កើងថ្លៃថ្នូរដោយសារកូន លុះត្រាកូនជាអ្នកមានគុណធម៌ខ្ពស់ មានចរិយាមារយាទល្អប្រពៃ មានសុជីវធម៌ល្អនៅគ្រប់កាលៈទេសៈទាំងនៅចំពោះមុខនិងនៅទីកំបាំងមុខ មានសេចក្ដីទៀងត្រង់ ព្រោះកូនល្អ តែងរក្សាកល្យាណធម៌ ៥ និងយកសីល ៥ ឬ សីល ៨ ធ្វើជាខ្យល់ដង្ហើមដកចេញចូលប្រចាំថ្ងៃ។ (ដើម្បីរំលឹក ឬ សិក្សាឡើងវិញអំពីកល្យាណធម៌ទាំង ៥ និងសីល ៥ ឬ សីល ៨ សូមបើកទំព័រខាងដើមអានឡើងវិញឱ្យចាំយល់ច្បាស់) ។ កូនដែលលំអខ្លួនដោយគុណធម៌ទាំងនេះ តែងធ្វើឱ្យគ្រួសារទទួលបាននូវសេចក្ដីថ្លៃថ្នូរ ការស្វាគមន៍ សរសើរ រាក់ទាក់ចូលចិត្ត ពីមនុស្សផងទាំងពួង ។
- កូនល្អ ជាពហុស្សុត : ពហុស្សូត ជាអ្នកសិក្សារៀនសូត្រល្អចេះដឹងច្បាស់ក្នុងផ្លូវលោកនិងផ្លូវធម៌ ដែលជាមនុស្សមាន

លក្ខណៈសម្បត្តិ ៥ យ៉ាងគឺ ចេះចាំល្អ, ព្យាយាមត្រូវ, ចេះត្រិះរិះពិចារណាតាមហេតុផល, សុំសីល, និងមានលទ្ធផលល្អ ទើបហៅថាជាអ្នកចេះដឹងច្រើនពិតប្រាកដ ។ កូនល្អដែលមានសមត្ថភាពទាំងនេះ តែងលើកតម្កើងសេដ្ឋកិច្ចគ្រួសារឱ្យរុងរឿង នាំឱ្យអ្នកដទៃគោរពស្ញប់ស្ញែង ។

- កូនល្អ សេពគប់តែមិត្តល្អ និងសប្បុរស : ទាំងមិត្តល្អ និងបណ្ឌិតធមិ (ឬសប្បុរស) ជាមនុស្សល្អ តែងតែចូលចិត្តគិតល្អ និយាយល្អ និងធ្វើល្អ ដែលនាំប្រយោជន៍និងសេចក្ដីថ្លៃថ្នូរដល់ខ្លួនឯងផង ដល់អ្នកដទៃទាំងឡាយផង ។ ការគប់ជាមួយមនុស្សល្អ មនុស្សត្រូវ រមែងនាំកេរ្តិ៍ឈ្មោះល្អដល់វង្សត្រកូល ។ ការគប់បុគ្គលពាលនិងអសប្បុរសជាមិត្ត រមែងនាំឱ្យខូចអនាគត និងខូចវង្សត្រកូល ។
- កូនល្អ សង្គ្រោះបងប្អូនញាតិសន្ដាន : សង្គមល្អ លុះត្រាតែមានមេដឹកនាំល្អ ហើយសមាជិកក៏ល្អ បងប្អូនញាតិសន្ដានគឺជាសមាជិកក្នុងគ្រួសារក្នុងវង្សត្រកូល ដូចនេះ ក្នុងនាមជាកូនល្អ ត្រូវមានសមត្ថភាពនិងលទ្ធភាពជួយសង្គ្រោះបងប្អូនសាច់ញាតិរួមត្រកូល ឱ្យមានសីលធមិល្អ សុខភាពល្អ សេដ្ឋកិច្ចគ្រួសាររុងរឿងផងដែរ ។

ខ្ញុំ ជា កូនល្អ ពិត

## សិក្ខាបទទី៤: កូនល្អ ត្រូវទទួលមរតកដោយបដិបត្តិឱ្យសមគួរ

ឪពុកម្ដាយបានឱ្យទ្រព្យមរតកជាច្រើនអនេក គ្មានទ្រព្យឯណាប្រៀបផ្ទឹមស្មើបាន ដល់កូនតាំងពីលោកបានបង្កើតកូន រហូតដល់លោកធ្វើកាលកិរិយាទៅកាន់លោកខាងមុខ ហើយបានបន្សល់ទ្រព្យមរតក ៣ ប្រភេទ ដល់កូនៗ នេះហៅថា លោកបានឱ្យកូនគ្រប់បែបគ្រប់យ៉ាង សូម្បីតែជីវិតរបស់លោក :

- **អដ្ឋិគុណមរតក** : ជាមរតកទី១ដែលគ្មាននរណា ទេវតាណា ព្រះអង្គណា មានទ្រព្យនេះដូចឪពុកម្ដាយមានឱ្យកូនឡើយ ។ អដ្ឋិគុណមរតក គឺ**កាយ** ដែលឪពុកម្ដាយបានឱ្យកូន ដែលកើតពីមេធម្មជាតិ ៤ មាន ដី ទឹក ភ្លើង ខ្យល់ ក្នុងធាតុផ្សំទាំងនេះ បង្កើតបានជាអវយវៈរបស់កូន មានធាតុផ្សំចំនួន ៤២ ធាតុ ។ កាយ ជាជម្រករបស់វិញ្ញាណ មានកាយ មានវិញ្ញាណ ទាំងពីរនេះបង្កើតបានជាជីវិត ដូចនេះ ឪពុកម្ដាយឱ្យជីវិតដល់កូន ។ **ជីវិត ជាដើមទុនធំជាងគេបំផុត ប្រសើរជាងគេបំផុតក្នុងលោក ដើម្បីសម្រេចមគ្គផលគ្រប់បែបយ៉ាងក្នុងលោក** ។ តើនៅក្នុងលោកនេះ

មាននរណាអាចឱ្យជីវិតបាន ក្រៅអំពីឪពុកម្ដាយឬទេ ? តើនេះជាមរតកល្អឯកឬទេ ? បើកូនយល់ច្បាស់ថា នេះជាមរតកល្អបំផុតគ្មានពីរ គប្បីប្រើប្រាស់មរតកនេះ ដើមទុននេះ ឱ្យជាប្រយោជន៍ដ៏អស្ចារ្យឱ្យបានក្នុងជីវិត ពោលគឺប្រើមរតកនេះ ដើមទុននេះ សម្រេចនូវគោលបំណងពិតទាំង ៣ របស់លោកអ្នកឱ្យទ្រព្យនេះគឺព្រះទាំងពីរ ទើបមានឈ្មោះថា អ្នកទទួលទ្រព្យមរតកដ៏សមគួរ ។

- **វិសេសគុណមរតក** : បន្ទាប់ពីឪពុកម្ដាយបានឱ្យអដ្ឋិគុណមរតកដល់កូនហើយ (បង្កើតកូន) លោកឱ្យវិសេសគុណមរតក ជាទ្រព្យទី២ដល់កូនទៀត ។ ឪពុកម្ដាយ អាចឱ្យវិសេសគុណមរតកនេះដល់កូនបាន ព្រោះលោកមានងារមានឈ្មោះ ៤ យ៉ាង ដែលគ្មានបុគ្គលណាមានឈ្មោះទាំងនេះឡើយគឺ (១) **ឪពុកម្ដាយជាគ្រូដើមរបស់កូន**: ក្នុងងារនេះ លោកបានឱ្យទ្រព្យមរតក ៤ យ៉ាងតូចៗទៀតគឺ ទី១ លោកបានបង្រៀនកូនឱ្យចេះ ដេក ដើរ ឈរ អង្គុយ ប្រកបដោយចរិយាមារយាទល្អ ទី២ លោកបានបង្រៀនកូនឱ្យចេះនិយាយយ៉ាងពីរោះ ប្រកបដោយសេចក្ដីទៀង

ត្រង់ ទី៣ លោកបានបង្រៀនកូននូវបំណិនជីវិត គឺកូនចេះធ្វើកិច្ចការផ្ទះ និងវិជ្ជាការបន្តវេនពីលោក និង ទី៤ លោកបានអប់រំទូន្មានកូនឱ្យសាងនូវកុសលកម្មបថ ១០ មាន កាយសុចរិត ៣ វចីសុចរិត ៤ មនោសុចរិត ៣ ។ (២) **ឪពុកម្តាយជាទេវតាដើមរបស់កូន** : ក្នុងងារនេះ លោកបានឱ្យទាន ៤ យ៉ាងជាទ្រព្យមរតកដល់កូន ទី១ **អាមិសទាន** គឺលោកបានឱ្យបច្ច័យ៤ ដើម្បីចិញ្ចឹមបីបាច់ថែរក្សាការពារកូនឱ្យធំធាត់ ឱ្យពេញវ័យ ទី២ **ធម្មទាន** គឺលោកបានឱ្យការអប់រំ ការលើកទឹកចិត្ត ការលួងលោម ការធ្វើជាមិត្តល្អ បទពិសោធន៍ល្អៗដល់កូន ទី៣ **អភ័យទាន** គឺលោកបានឱ្យការមិនប្រកាន់ទោសកំហុសតូចធំគ្រប់បែបយ៉ាង ដែលកូនបានប្រព្រឹត្តិខុសជាច្រើនមកលើលោក និង ទី៤ **សុខទាន** គឺលោកបានឱ្យសេចក្តីសុខដល់កូនតាំងពីកូនកើតរហូតដល់កូនពេញវ័យ ពេញសេចក្តី ។ តើនៅក្នុងលោកនេះ មានបុគ្គលណាមានទ្រព្យទាំង ៤ នេះជាទេវតាដើមឱ្យកូនបានក្រៅពីឪពុកម្តាយ ? ដូចនេះ កូនល្អ រមែងតបគុណដល់ទេវតាដើមរបស់ខ្លួន ដោយប្រើប្រាស់ទ្រព្យមរតកនេះឱ្យបង្កើតបានជាប្រយោជន៍ល្អទាំងឡាយដោយសមគួរ ។

**(៣) ឪពុកម្ដាយជាព្រះព្រហ្មរបស់កូន:** ក្នុងងារនេះ លោកបានឱ្យទ្រព្យមរតកដល់កូននូវធម៌ ៤ ជាជម្រកសុខសាន្តគឺ មេត្តា ករុណា មុទិតា និង ឧបេក្ខា ។ កូនល្អ រមែងទទួលនូវព្រហ្មវិហារធម៌ទាំង ៤ នេះហើយ ផ្សព្វផ្សាយនូវមេត្តា ករុណា មុទិតា និង ឧបេក្ខា ដល់គ្រប់មនុស្សទាំងអស់ ទើប ឈ្មោះថា កូនទទួលមរតករបស់ឪពុកម្ដាយដ៏សមគួរហើយ ។ ដើម្បីយល់អំពីខ្លឹមសារនៃជម្រកសុខទាំង ៤ សូមរកជាវអានសៀវភៅ "ឪពុកម្ដាយល្អពិតរបស់កូន" ។

**(៤) ឪពុកម្ដាយជាព្រះអរហន្តរបស់កូន** : លោកទាំងពីរគ្មានកិលេស គឺគ្រឿងសៅហ្មងនៃចិត្តចំពោះកូនឡើយ ផ្ទុយទៅវិញ មានតែឱ្យអភ័យ ឱ្យសុខ ឱ្យការសង្គ្រោះ ឱ្យការខ្វាយខ្វល់នឹកគិតដល់កូន ឱ្យកូនមានសេចក្ដីល្អ ឱ្យទាំងជីវិតរបស់លោកដល់កូនទៀត ។

- **គុណូបការគុណមរតក** : អរិយមរតកទី៤ ដែលឪពុកម្ដាយឱ្យកូនគឺ គុណូបការគុណមរតក មាន ៤ ចំណែកគឺ (១) លោកបានទំនុកបម្រុង ឱ្យកូនបន្តការសិក្សារៀនសូត្រនៅតាមសាលា រហូតដល់ឧត្តមសិក្សា ដើម្បីក្រេបយកវិជ្ជា



ទី១៥- ជាកូនល្អពិត

តាមនិស្ស័យស្រឡាញ់របស់កូន; (២) លោកបានទំនុកបម្រុងកូន ដោយរៀបចំគូស្រករឱ្យកូនមានស្វាមីល្អ ឬភរិយាល្អយ៉ាងសមរម្យ ដើម្បីបង្កើតគ្រួសារផ្ទាល់ខ្លួន, (៣) លោកបានទំនុកបម្រុងកូន ដោយចែកមរតក ចែកកេរដំណែល ជាផ្ទះ ដីធ្លី លុយកាក់ ឬ ភាគហ៊ុនអាជីវកម្មឱ្យដល់កូន, និង (៤) លោកនៅតាមទំនុកបម្រុងកូនដោយតាមមើលថែ គាំពារ ឱ្យគ្រួសាររបស់កូនមានសេចក្ដីសុខសេចក្ដីចម្រើន សុភមង្គល ។ កូនល្អដែលយល់ច្បាស់អំពីតម្លៃដែលមិនអាចកាត់ថ្លៃបាននៃ គុណូបការគុណមរតកដែលលោកបានឱ្យ តែងចេះប្រើប្រាស់ទ្រព្យទាំងនេះធ្វើជាដើមទុនបង្កើតឱ្យមាន សុភមង្គលក្នុងគ្រួសារ ហើយខិតខំសន្សំបុណ្យឧទ្ទិសជូនលោកទាំងពីរជានិច្ចនិរន្តរ៍ ទើបកូននោះមានឈ្មោះថា កូនទទួលមរតកដោយសមគួរ ។

---

ម៉ែឪឱ្យកូននូវអ្វីទាំងអស់
ចំណែកកូនវិញឱ្យលោកព្រួយគិត
លោកមិនស្រណោះសូម្បីជីវិត
ភិតភ័យភ័យពិតដោយសារតែកូន ។

*ស៊ាន វិត*

---

## សិក្ខាបទទី៥: កូនល្អ ត្រូវធ្វើបុណ្យឧទ្ទិសទក្ខិណាទាន ជូនមាតាបិតា

បើឪពុកម្ដាយបានធ្វើមរណកាលទៅកាន់បរលោកហើយ កូនល្អគប្បីខំធ្វើបុណ្យទក្ខិណាទានឱ្យបានច្រើន តាមរយៈព្រះសង្ឃ និងអ្នកមានសីល ហើយឧទ្ទិសកុសលជូនដល់លោក ព្រមទាំងសូមលោកអនុមោទនាទទួលផលផង ក្រែងតែ លោកបានធ្វេសប្រហែសសាងអកុសលកម្មដែលនាំលោកទៅចាប់កំណើតថ្មីនៅអបាយភូមិ ជាទីដ៏ថោកទាប ។ ដោយសារចំណែកនៃទក្ខិណានុប្បទានដែលកូនបានធ្វើជាច្រើនជារាល់ខែឆ្នាំជូនលោក ទើបអាចនាំឱ្យលោកផុតអស់កម្មពៀរនៅក្នុងអបាយភូមិណា១មាន នរក តិរច្ឆាន ប្រេត អសុរកាយ បាន។ ការធ្វើទក្ខិណានុប្បទានឧទ្ទិសផលជូនទៅឪពុកម្ដាយដែលបានចែកឋានហើយ មាន ៣ កាលដូចខាងក្រោម :

- **កូនល្អ ត្រូវធ្វើបុណ្យក្នុងជីវិតប្រចាំថ្ងៃ** : កូនកតញ្ញូ តែងស្រឡាញ់អំពើល្អ ចូលចិត្តសន្សំបុណ្យដោយកាយវាចាចិត្តជារៀងរាល់ថ្ងៃ តាមរយៈបុញ្ញកិរិយាវត្ថុទាំង ១០ យ៉ាង។ ពេលធ្វើបុណ្យ ចូរកូនឧទ្ទិសបុណ្យដល់ឪពុកម្ដាយដែលស្លាប់ទៅ ឱ្យចំៗឈ្មោះរបស់លោក ឧទាហរណ៍ "ខ្ញុំសូមឧទ្ទិសបុណ្យកុសលទាំងឡាយដែលខ្ញុំបានសាងហើយ ជូន

ដល់លោកពុក ហ៊ូ ស៊ាន ហើយសូមលោកពុក ហ៊ូ ស៊ាន អនុមោទនាទទួលយកបុណ្យ ដែលកូនបានឧទ្ទិសជូន កុំបីខាន ហើយបើលោកពុក ខកខានមិនបានទទួលដោយប្រការណា ខ្ញុំសូមពឹងទេវតា មេត្តានាំបុណ្យទាំងនេះជូនដល់លោកពុក ហ៊ូ ស៊ាន ផង" ។

- **កូនល្អ ត្រូវធ្វើបុណ្យតាមរដូវកាល** : ក្នុងព្រះពុទ្ធសាសនាខ្មែរ កូនមានឱកាសច្រើនក្នុង១ឆ្នាំៗ ក្នុងការធ្វើបុណ្យឧទ្ទិសជូនឪពុកម្តាយដែលបានស្លាប់ទៅហើយ ដូចជា បុណ្យភ្ជុំបិណ្ឌ បុណ្យកឋិនទាន បុណ្យចូលឆ្នាំ បុណ្យវិសាខបូជា បុណ្យមាឃបូជា ជាដើម ។ ឧទាហរណ៍ "ខ្ញុំសូមឧទ្ទិសផលានិសង្សបុណ្យមាឃបូជា ជូនដល់លោកពុក ហ៊ូ ស៊ាន សូមលោកពុក បានរួចរដោះចាកទុក្ខ ដែលលោកកំពុងទទួលកុំបីខាន" ។

- **កូនល្អ ត្រូវធ្វើបុណ្យខួបប្រចាំឆ្នាំ** : កូនកតញ្ញូកតវេទីរមែងមានសមត្ថភាពនិងមានចិត្តធ្វើបុណ្យ មិនឱ្យខកខានជារៀងរាល់ឆ្នាំ ដើម្បីសន្សំបុណ្យជូនលោកពុកអ្នកម៉ែដែលបានចែកឋានទៅ ហើយឧទ្ទិសបុណ្យនោះជូនលោកដែលជាទក្ខិនេយ្យបុគ្គល ឱ្យចំៗឈ្មោះរបស់លោកផង ។

ចំ-ជា កូនល្អ ពិត

## [២]. កូនល្អពិតបំពេញ "សិក្ខាបទ ៤ ចំពោះបងប្អូនបង្កើត"

កូនល្អពិត តែងបំពេញសិក្ខាបទទាំង ៤ ចំពោះបងប្អូនបង្កើត ព្រោះបងប្អូនបង្កើតជាសាវ័ករបស់ឪពុកម្តាយ ហើយឪពុកម្តាយសុខកាយសប្បាយចិត្ត លុះត្រាតែកូនទាំងអស់គ្នាមានសេចក្តីសុខនឹងគ្នា ។ សិក្ខាបទ ៤ ដែលកូនល្អពិត ត្រូវបំពេញចំពោះបងប្អូនបង្កើតមាន :

- កូនល្អពិត មានឧបការៈចំពោះបងប្អូនបង្កើត
- កូនល្អពិត រួមសុខទុក្ខជាមួយបងប្អូនបង្កើត
- កូនល្អពិត ប្រាប់ប្រយោជន៍ដល់បងប្អូនបង្កើត
- កូនល្អពិត មានសេចក្តីឈឺឆ្អាលចំពោះបងប្អូនបង្កើត

ខ្ញុំបាទសូមអភ័យពីលោកអ្នកអាន ដោយមិនបានធ្វើការបកស្រាយខ្លឹមសារនៃសិក្ខាបទ ៤ ខាងលើនេះទេ ដើម្បីចៀសវាងសៀវភៅនេះមានទំព័រច្រើនពេក ។ សូមលោកអ្នកអាន រកជាវសៀវភៅដែលមានចំណងជើងថា "មិត្តល្អពិត" ដើម្បីយល់សិក្ខាបទទាំង ៤ នេះ ។

---

**"ការមានទំនាស់ជាមួយបងប្អូនបង្កើត ដូចជាកំពុងសម្លាប់អវយវៈរបស់ឪពុកម្តាយ ។"**

*ស៊ាន វ៉ិត*

---

## [៣]. កូនល្អពិតបំពេញ "សិក្ខាបទ ៥ ចំពោះ ញាតិមិត្ត"

កូនល្អពិត មិនត្រឹមតែមានសេចក្តីល្អចំពោះឪពុកម្តាយ និងបងប្អូនបង្កើតប៉ុណ្ណោះទេ ថែមទាំងល្អចំពោះញាតិឆ្ងាយ និងមិត្តភ័ក្តិផងទាំងពួងដែរ ។ ការប្រតិបត្តិល្អរបស់កូនល្អពិត ចំពោះញាតិមិត្ត ត្រូវប្រកបដោយសិក្ខាបទ ៥ ដូចខាងក្រោម :

- រក្សាញាតិមិត្តដែលធ្វេសប្រហែស
- ជួយថែរក្សាទ្រព្យរបស់ញាតិមិត្តដែលធ្វេសប្រហែស
- ជាទីពឹងរបស់ញាតិមិត្តដែលមានភ័យ
- មិនបោះបង់ញាតិមិត្តដែលស្ថិតក្នុងគ្រាមានវិបត្តិ
- រាប់អានរហូតដល់ផៅពង្សរបស់ញាតិមិត្ត

សូមលោកអ្នកអាន រកជាវសៀវភៅដែលមានចំណងជើងថា "មិត្តល្អពិត" ដើម្បីសិក្សាស្វែងយល់ខ្លឹមសារខាងលើនេះឱ្យច្បាស់លាស់ ។

"បងប្អូនបង្កើត ជាសរសៃឈាម ញាតិមិត្ត ជាស្បែកដណ្តប់សរសៃ ។"

*ស៊ាន វ៉ិត*

ទី១ ជា កូនល្អ ពិត

# ខ. កូនល្អមានសមត្ថភាពកសាង "អនាគតល្អពិត"

កូនដែលល្អពិត រមែងធ្វើឱ្យផលល្អកើតឡើងជាប្រាកដ គឺកូនមាន "អនាគតល្អពិត" ដោយប្រការ ៥ យ៉ាងដូចខាងក្រោម :

(១). កូនជា "ស្វាមីល្អពិត ឬ ភរិយាល្អពិត"

(២). កូនជា "ឪពុកល្អពិត ឬ ម្ដាយល្អពិត"

(៣). កូនជា "ញាតិមិត្តល្អពិត"

(៤). កូនមាន "សេចក្ដីកិច្ចគ្រួសាររុងរឿងពិត"

(៥). កូនមាន "សុភមង្គលក្នុងគ្រួសារពិត"

ចំពោះខ្លឹមសារពិស្ដារ ចូរលោកអ្នក រកជាវសៀវភៅដូចដែលបង្ហាញមកអាន សំរាប់(១) ចូររកជាវសៀវភៅ "ស្វាមីភរិយាល្អពិត", សំរាប់(២) ចូររកជាវសៀវភៅ "ឪពុកម្ដាយល្អពិត របស់កូន", សំរាប់(៣) ចូររកជាវសៀវភៅ "មិត្តល្អពិត", សំរាប់(៤) សូមរកជាវសៀវភៅ "វិធីធ្វើឱ្យគ្រួសារមានសេដ្ឋកិច្ចរុងរឿង", និង (៥)ចូររកជាវសៀវភៅ "គ្រួសារមានសុភមង្គលពិត" ។

---

**"អនាគតល្អ ជាផលនៃទង្វើត្រូវ រក្សាអនាគតល្អបាន ជាចេតនាចិត្តល្អពិត ។"**

*ស៊ាន វិត*

---

# គ. កូនល្អមានសមត្ថភាពធ្វើជា "មនុស្សល្អពិត"

មនុស្សល្អពិត ជាមនុស្សមនុស្សោ ឬ ជាមនុស្សទេវោ ដែលប្រកបដោយគុណធម៌យ៉ាងវិសេសរបស់មនុស្ស ឬ របស់ទេវតា ។ ចូរលោកអ្នកអានរកជាវសៀវភៅ "មនុស្សល្អពិត" ទើបយល់ខ្លឹមសារទាំងនេះបានច្បាស់លាស់ល្អ ។ កូនល្អ ត្រូវតែជា មនុស្សល្អពិត មាននូវលក្ខណៈសម្បត្តិល្អ ៥ យ៉ាងដូចខាងក្រោម :

(១). មនុស្សល្អពិត ជា "កូនល្អពិត"

(២). មនុស្សល្អពិត ជា "សិស្សល្អពិត"

(៣). មនុស្សល្អពិត ជា "មិត្តល្អពិត"

(៤). មនុស្សល្អពិត ជា "អ្នកធ្វើការល្អពិត"

(៥). មនុស្សល្អពិត ជា "ពុទ្ធសាសនិកល្អពិត"

សំរាប់(១) ចូរយកចិត្តទុកដាក់អានសៀវភៅនេះ, សំរាប់(២) ចូររកជាវអានសៀវភៅ "សិស្សល្អពិត", សំរាប់(៣) ចូររកជាវអានសៀវភៅ "មិត្តល្អពិត", ឯទី(៤) ចូររកជាវអានសៀវភៅ "អ្នកធ្វើការល្អពិត", និង (៥) ចូររកជាវអានសៀវភៅ "ពុទ្ធសាសនិកល្អពិត" ។

# ដំណោះស្រាយសម្រាប់កូនដែលចង់កែខ្លួនឱ្យល្អពិត

ជាធម្មតាមនុស្សគ្រប់រូប កើតមកតែងនាំអវិជ្ជា (សេចក្តីល្ងង់ខ្លៅ) មក ជាមួយ ទើបបណ្តាលឱ្យមនុស្សប្រព្រឹត្តទង្វើខុសពីតួនាទីរបស់ផងខ្លួន ដើរលើផ្លូវ ខុសគោលដៅ ថ្វីត្បិតតែ កំណើតជាមនុស្ស មានដោយកម្រ ហើយមានដោយ អំណាចនៃបុណ្យគឺ សេចក្តីល្អ ។ ជាក់ស្តែង នៅក្នុងសង្គមបច្ចុប្បន្ននេះ កូនដែល ល្អពិត រកបានដោយកម្របំផុត សំបូរតែកូនធ្វើឱ្យ ឪពុកម្តាយស្រក់ទឹកភ្នែកដល់ ជង្គង់ ចំពោះមកពីហេតុអ្វីនោះ សូមលោកអ្នកអានពិចារណាដោយខ្លួនឯងចុះ ខ្ញុំបាទសូមតែបកស្រាយអំពីដំណោះស្រាយជាយោបល់ផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ។

**១.** ជាដំបូង សូមយល់ឱ្យច្បាស់អំពី តម្លៃរបស់មនុស្ស ។ **ភាពសំខាន់បំផុតរបស់មនុស្សគឺ ជីវិត** ភាពសំខាន់បំផុតរបស់ជីវិតគឺ **ចិត្ត** ភាពសំខាន់បំផុតរបស់ចិត្តគឺ **ធម៌** (ព្រះធម៌ ឬ ធម្មជាតិ គឺឱវាទរបស់ព្រះពុទ្ធ នាំឱ្យមនុស្សមានបញ្ញាត្រូវ) ភាពសំខាន់បំផុតរបស់ធម៌គឺ **សីល** (ការប្រតិបត្តិត្រូវតាមព្រះធម៌) ធម៌សំខាន់របស់ សីល គឺ *ការតបគុណ, មេត្តា-ករុណា,* និង *ទំនួលខុសត្រូវ* ហើយ ភាពសំខាន់បំផុតរបស់សីលគឺ **លទ្ធផលល្អ** ។ សម័យបច្ចុប្បន្ននេះ មនុស្សភាគច្រើនបំផុត កំពុងរស់នៅក្នុងភពវង្វេង ថ្វីត្បិតតែម្នាក់ៗ ប្រាថ្នារស់នៅសុខ បែរជាវរវល់សឹងមួយជីវិតតែទៅលើដើម្បីបាន *លុយ អំណាច កាមគុណ* និង *ភាពហ៊ឺហា* ដែលទាំង ៤ តម្រូវការនេះមិនអាច បង្កើតសុខបានឡើយ គ្រាន់តែជាសុខសំបកក្រៅ ឬ សុខលើគំនរទុក្ខ ប៉ុណ្ណោះ ព្រោះទាំងនេះ ជាតម្រេក បើមនុស្សណាមិនចេះប្រមាណ មិនចេះព្រមល្មម មិនចេះសន្តោស តម្រេកទាំង

នេះ ញ៉ាំងឱ្យមនុស្សនោះ កាន់តែស្រេកឃ្លានឡើងៗ រកទីបញ្ចប់គ្មាន រកសុខមិនមានឡើយ ។ សុខ មាន ២ យ៉ាងគឺ **សុខក្នុងគ្នា** បានដល់ **សុភមង្គល** គឺការរស់នៅជាមួយគ្នាប្រកបដោយភាតរភាព និង **សុខក្នុងចិត្ត** បានដល់ **សេចក្ដីសុខស្ងប់** គឺ រស់នៅព្រមដោយ ចិត្តមានធម៌ត្រូវ ចិត្តមានសីលត្រូវ ចិត្តមានសមាធិត្រូវ ។ គ្រឿងសំខាន់បំផុតរបស់សុខទាំង២នេះគឺ ធម៌ និង សីល មានន័យថា មនុស្សអាចនឹងរកសេចក្ដីសុខឃើញ លុះត្រាតែមាន ធម៌ និង សីល ក្នុងន័យថា មនុស្សល្អស្វែងរកសុខគឺ**ត្រូវខិតខំរៀនសូត្រព្រះធម៌** ដើម្បីមានប្រាជ្ញាត្រូវ ចៀសវាងមានមោហៈ គឺសេចក្ដីវង្វេង យកខ្មៅជាស ប្រមាថសជាខ្មៅ យកសត្រូវជាមិត្តនៃបនិត្យតែជាមួយគ្រឿងនាំទុក្ខ តែស្រេកចង់បានសុខ ។ ប្រាជ្ញាត្រូវ ឬ បញ្ញាត្រូវ នាំឱ្យមានការបដិបត្តិត្រូវ ហៅថា សីលត្រូវ ហើយមានតែការបដិបត្តិត្រូវ (សីលត្រូវ) ទេ ទើបនាំឱ្យមានសុខក្នុងចិត្ត សុខក្នុងគ្រួសារ សុខក្នុងសង្គម ។ អវត្តមាននៃសីលក្នុងបុគ្គលម្នាក់ៗ គឺនាំឱ្យមានវត្តមាននៃ សង្គ្រាមនៅក្នុងបុគ្គល សង្គ្រាមក្នុងគ្រួសារ សង្គ្រាមក្នុងសង្គមនិងក្នុងពិភពលោក ។ ដូច្នេះ ការរស់នៅត្រូវ ឬ ការមានជីវិតត្រូវ ឬ មនុស្សត្រូវ គឺគប្បីខិតខំសិក្សាព្រះធម៌នានា ដែលញ៉ាំងឱ្យលោកអ្នកប្រព្រឹត្តិត្រូវពិតគឺ (១) ការតបគុណពិតដល់ឪពុកម្ដាយនិងដល់គុណូបការជនទាំងឡាយ (២) ផ្សព្វផ្សាយមេត្តាករុណាធម៌ដល់សត្វលោក និង (៣) ខិតខំព្យាយាមបំពេញទំនួលខុសត្រូវក្នុងការងារនិងតួនាទីទាំងឡាយដោយសុចរិត ដោយបញ្ញា ។ ទង្វើត្រូវទាំង ៣ នេះ ទើបនាំឱ្យលោកអ្នករស់នៅដោយសុភមង្គល សេចក្ដីសុខ និង សេចក្ដីចម្រើន ពិតប្រាកដ ។

**២.** កូនល្អ គប្បីប្រតិបត្តិតាមព្រះពុទ្ធឱវាទ ត្រាស់សម្ដែងថា "**ធម៌ពីរ ដែលជាចំណែកនៃសេចក្ដីចម្រើនគឺ ភាវៈជាអ្នកដែលគេស្ដីប្រដៅបានដោយងាយ ១, ភាវៈជាអ្នកសេពគប់មិត្តល្អ១**" ។ កូនល្អ ត្រូវចេះរៀបចំខ្លួនឱ្យជាអ្នកដែលគេស្ដីប្រដៅបានដោយងាយ បានដល់ សប្បុរស បណ្ឌិត ពហុស្សូត ពុទ្ធបរិស័ទ គ្រូអាចារ្យ ឪពុកម្ដាយ កល្យាណមិត្ត និង បុគ្គលប្រកបដោយសេចក្ដីចម្រើននានា។ ចូរអានឡើងវិញត្រង់ទំព័រ ២៤ នៃសៀវភៅនេះ អំពីកិរិយា ៦ យ៉ាងនៃមនុស្សដែលគេប្រដៅងាយ ហើយចូរហ្វឹកហាត់ធ្វើតាមកិរិយាទាំងនេះឱ្យបានល្អបំផុត។ មួយវិញទៀត កូនល្អ ត្រូវសេពគប់តែជាមួយមិត្តល្អពិតៗ តែប៉ុណ្ណោះ ត្រូវជៀសចេញឱ្យឆ្ងាយពីបុគ្គលពាលទាំងឡាយ ដើម្បីចៀសវាងពី សេចក្ដីវិនាស និង គ្រោះថ្នាក់នានា ។ តាមព្រះពុទ្ធឱវាទ មិត្តល្អពិត ឬ កល្យាណមិត្តពិត មាន ៤ ពួកគឺ (១)មិត្តមានឧបការៈ (២)មិត្តរួមសុខទុក្ខ (៣)មិត្តប្រាប់ប្រយោជន៍ និង (៤)មិត្តមានសេចក្ដីឈឺឆ្អាល សូមរកជាវអាន សៀវភៅ "មិត្តល្អពិត" ដើម្បីយល់ខ្លឹមសារទាំង ៤ នេះឱ្យបានច្បាស់លាស់ ។ មានតែបុគ្គលប្រសើរខ្ពង់ខ្ពស់ដូចជា សប្បុរស ពហុស្សូត មនុស្សជោគជ័យ បណ្ឌិតល្អ កល្យាណមិត្តពិត ទើបអាចជួយអ្នកឱ្យមានអនាគតត្រចះត្រចង់ ខ្ពស់ត្រដែតបាន ដើម្បីលើកមុខមាត់វង្សត្រកូល និងតបគុណព្រះម្ចាស់ថ្លៃនានាបាន។

ព្រះពុទ្ធ បានត្រាស់សម្ដែងថា "**អ្នកមានប្រាជ្ញា មិនគួរគប់មិត្រអាក្រក់ មិនគួរគប់បុរសថោកទាប, គួរគប់រកតែមិត្រដែលល្អប្រសើរ គួរគប់រកតែបុរសខ្ពង់ខ្ពស់**" ។

**៣.** កត្តាដ៏សំខាន់បំផុត១ទៀតក្នុងការកសាងនិងជំរុញឱ្យមានការផ្លាស់ប្ដូរ ការគិតខុស ការនិយាយខុស ចរិតអាក្រក់ និងទម្លាប់ខុសរបស់លោកអ្នកគឺ ត្រូវមានអ្នកអប់រំទូន្មានជារៀងរាល់ថ្ងៃ មានន័យថា លោកត្រូវទទួលការអប់រំពីសាលារៀនដែលល្អពិតល្អពេញលេញពិត ។ មនុស្សទាំងឡាយតែងចង់ល្អពិត ចង់ចេះពិត ចង់ជោគជ័យពិត ចុះហេតុអ្វីមានអ្នកសិក្សាជាច្រើនមិនអាចសម្រេចបំណងទាំងនេះបាន? បាទ, មូលហេតុចម្បងនោះគឺជ្រើសរើសសាលារៀនដែលល្អមិនពេញលេញ ល្អមិនពិតមែន ។ សាលារៀនដែលល្អពិត ល្អពេញលេញពិត ត្រូវអប់រំ លត់ដំ បង្រៀន និងដឹកនាំសិស្សឱ្យទទួលបាន **បញ្ញា គុណធម៌ ជំនាញការងារ** និង **ជំនាញជោគជ័យ** ទើបជាសាលាដែលលោកអ្នកគួរចំណាយលុយកាក់ ពេលវេលា ការព្យាយាមខំប្រឹងប្រែង រួមទាំងត្រូវចំណាយជីវិតជាមួយ ។ ខ្ញុំបាទសូមណែនាំ សាលាល្អពិតដែលលោកអ្នកគួរផ្ញើជីវិតនោះគឺ **សាលារៀន សុខៈ** (សូមមើលគំរបមុខទី៣នៃសៀវភៅនេះ) ។

**៤.** សៀវភៅនេះ នឹងក្លាយជាដៃគូរជីវិតដ៏សំខាន់សម្រាប់កូនៗទាំងឡាយឱ្យយល់ច្បាស់ និងផ្លាស់ប្ដូរ គំនិតខុស ទង្វើខុស ទម្លាប់ខុស ចំពោះឪពុកម្ដាយនិងអ្នកមានគុណឯទៀត ព្រមទាំងញាតិមិត្តផងទាំងពួង ។ គប្បីយកចិត្តទុកដាក់ អាន កត់ចំណាំ ទន្ទេញឱ្យចាំ និង ព្យាយាមអនុវត្តតាមខ្លឹមសារនានាដែលលោកអ្នកជាកូន គិតថាគប្បីត្រូវប្រណិប័តន៍តាម ដើម្បីជាប្រយោជន៍សម្រាប់បច្ចុប្បន្ន និងអនាគត តាមរយៈការធ្វើតែសេចក្ដីល្អគឺ ការខំតបគុណ ការផ្ដល់មេត្តា-ករុណា និងមានទំនួលខុសត្រូវពេញលេញ ។ បើលោកអ្នកអាន ត្រូវការគំនិតយោបល់បន្ថែមរបស់ខ្ញុំបាទៗ រីករាយបម្រើជូនដោយស្មោះត្រង់ ។

## ៥. រូបមន្តសង្ខេបដើម្បីក្លាយទៅជាកូនល្អពិតគឺ :

(១). ជ្រើសរើសសាលារៀនល្អពិត ដែលអប់រំនិងបង្រៀនសិស្សឱ្យមានសមត្ថភាពពេញលេញជាមនុស្ស ពោលគឺសមត្ថភាព៤យ៉ាងមាន "**បញ្ញា គុណធម៌ ជំនាញការងារ** និង **ជំនាញជោគជ័យ**" ។ សមត្ថភាពទាំងនេះ មានតែនៅសាលារៀន សុខៈ ប៉ុណ្ណោះ ដែលជាសាលាល្អពេញលេញពិតប្រាកដ ។

(២). ស្វែងរកកន្លែងអប់រំនិងកន្លែងលត់ដំខ្លួនឱ្យបានទៀងទាត់ជាប្រចាំអំពី "**អត្តចរិតជាកូនល្អពិត**" ដែលមានអ្នកប្រឹក្សាយោបល់ស្មោះត្រង់ ដើម្បីដឹកនាំអ្នកឱ្យក្លាយជាកូនល្អពិត ។ ខ្ញុំបាទសូមណែនាំ **សាលារៀន សុខៈ** មានកម្មវិធីអប់រំជារៀងរាល់ចុងសប្តាហ៍ដោយឥតបង់ថ្លៃឡើយ (**Workshops for Family Happiness**) ដល់អ្នកទាំងឡាយដែលជាកូន ឱ្យយល់ច្បាស់អំពីតួនាទីរបស់ផងខ្លួន និងឱ្យមានសេចក្តីក្លាហានប្រតិបត្តិតួនាទីជាកូនល្អពិតចំពោះឪពុកម្តាយ ។

(៣). នាំឪពុកម្តាយបន្តរៀនសូត្រអំពី "**អត្តចរិតជាឪពុកម្តាយល្អពិត**" នៅកន្លែងអប់រំល្អពេញលេញណា១ ដើម្បីឱ្យលោកទាំងពីរយល់ដឹងច្បាស់អំពីតួនាទីរបស់លោក និងអំពីវិធីត្រូវក្នុងការទូន្មានកូនៗឱ្យល្អពិត ។ **សាលារៀន សុខៈ** មានកម្មវិធីបង្រៀនឪពុកម្តាយគ្រប់រូប នៅរៀងរាល់ចុងសប្តាហ៍ដោយឥតបង់ថ្លៃសិក្សា ដើម្បីឱ្យឪពុកម្តាយទទួលបានសមត្ថភាពល្អក្នុងការអប់រំទូន្មានកូនដោយប្រើមធ្យោបាយត្រូវ ទើបធ្វើឱ្យកូនគោរពលោកពិត និងកូនកែខ្លួនល្អពិត ។

---

ស៊ាន វិតថា "**ងងឹតភ្នែក មិនស្មើងងឹតគំនិត, សាលារៀនល្អ១០ មិនស្មើសាលារៀនល្អពេញលេញ១** ។"

---

**ចប់**

សូមអរគុណ!

| ថ្ងៃខែសង Due Date | លេខបណ្ណអាន Card Number | បណ្ណារក្ស Librarian |
|---|---|---|
| 10 MAY 2012 | 000770 | |
| 03 DEC 2012 | 004510 | |
| 09 JAN 2013 | 005702 | |
| 20 MAY 2013 | 003430 | |
| 28 APR 2014 | | |
| 17 MAY 2014 | | |
| 23 MAY 2014 | | |
| 23 MAY 2014 | | |
| 05 JUN 2014 | | |
| 09 MAR 2016 | | |
| 17 MAR 2016 | | |
| 08 APR 2016 | | |
| 04 JUN 2016 | | |

CATALOGED IN NGL
No: 1543
Date: 06/07/11

Hun Sen Library
K021609

CATALOGED IN ALEPH
No : 31215
Date : 07-08-13

២- អាចពន្យារបានពីរ រឺបីដងប៉ុន្តែត្រូវមកបំពេញបែបបទថ្មីជាមួយ

បណ្ណារក្សផ្នែកខ្ចី ។ 0008021609

៣- ផាកពិន័យចំពោះសៀវភៅដែលសងលើសថ្ងៃកំនត់ ១ថ្ងៃ

៥០០រៀល ចំពោះសៀវភៅ១ក្បាល ។

៤- ក្រៅពីនិស្សិត បុគ្គលិកសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទ

ភ្នំពេញ បណ្ណាល័យតំរូវអោយកក់លុយ២០ដុល្លារអាមេរិកក្នុង

ករណើខ្ចីសៀវភៅចេញ ។

៥- សូមជួយថែរក្សាសៀវភៅអោយបានល្អ ។



# កត្តញ្ញូតាធម៌

ខ្ញុំបាទជូននំខួបកំណើតដល់ព្រះទាំងពីររបស់ខ្ញុំបាទ នៅថ្ងៃទី ២០ មេសា ២០០៣ ដើម្បីរំលឹកគុណ របស់ព្រះទាំងពីរដែលបានផ្តល់កំណើតដ៏ប្រពៃដល់ខ្ញុំបាទ និងដើម្បីសុំពរពីព្រះទាំងពីរ ។

"គ្មានអ្វីថ្លៃវិសេស ស្មើនឹង **គុណ** គឺគុណនៃឪពុកម្តាយ
ហៅថា **គុណមាតាបិតា** និង គុណនៃធម៌ ហៅថា **គុណធម៌** ។"

"**មនុស្សមានគុណធម៌** ជាមនុស្សសង្គ្រោះខ្លួនឯងពិត
និងជួយសង្គ្រោះអ្នកដទៃ នាមថា **មនុស្សល្អពិត** ។"

"ជនណាប្រតិបត្តិត្រូវក្នុងមាតា ១ ក្នុងបិតា ១ ក្នុងព្រះតថាគតជាសម្ពុទ្ធ ១ ក្នុងសាវ័ករបស់ព្រះតថាគតនោះ ១ ជនដូច្នោះនោះ រមែងបាននូវបុណ្យដ៏ច្រើន។ ក្នុងលោកនេះបណ្ឌិតទាំងឡាយ រមែងសរសើរជននោះ លុះជននោះទៅកាន់លោកខាងមុខហើយ រមែងរីករាយក្នុងស្ថានសួគ៌ ព្រោះការប្រតិបត្តិត្រូវតាមធម៌នោះ ចំពោះមាតានិងបិតាទាំងឡាយ ។" (ព្រះបិដកលេខ ៤២ ទំព័រ ១១)